សមាគមភោជនីយដ្ឋានកម្ពុជា
CAMBODIA RESTAURANT ASSOCIATION

## សមាគមភោជនីយដ្ឋានកម្ពុជា


អាសយដ្ឋាន៖  វិទ្យាស្ថានម្ហូបអាហារកម្ពុជា ជាន់ទី៣ អគារលេខ២៣ ( ACAC ) ផ្លូវ១៣៩ សង្កាត់វាលវង់
ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីមែល៖ manager@cambodiarestaurantassociation.com.kh
ទូរស័ព្ទ៖ +៨៥៥ ៧៦ ២២២ ៨៨៨៦
គេហទំព័រ៖ cambodiarestaurantassociation.org.kh


ក្រោមការដឹកនាំរបស់ ប្រធានសមាគមភោជនីយដ្ឋានកម្ពុជា
លោក ARNAUD DARC


រៀបរៀងដោយ៖

លោកស្រី ស៊ុន វ៉ាសី ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រុមហ៊ុនបដិសណ្ឋារកិច្ចថាលាស
កញ្ញា Annabelle COURAGIER
កញ្ញា Julia DESVIGNES



ប្រែសម្រួលជាភាសាខ្មែរដោយ ៖

លោកស្រី ស៊ុន វ៉ាសី ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រុមហ៊ុនបដិសណ្ឋារកិច្ចថាលាស
កញ្ញា ពិន ច័ន្ទណាត  អ្នកប្រឹក្សាច្បាប់ ក្រុមហ៊ុនបដិសណ្ឋារកិច្ចថាលាស



9 789924 978800


# ចុះបញ្ជីអាជីវកម្មភោជនីយដ្ឋាន
# ត្រឹមរយៈពេល៨ថ្ងៃ !

## សៀវភៅណែនាំស្តីពីកាតព្វកិច្ចចុះបញ្ជីអាជីវកម្មភោជនីយដ្ឋាន







បោះពុម្ពដោយ
សមាគមភោជនីយដ្ឋានកម្ពុជា

បោះពុម្ពផ្សាយលើកទី១ ខែមីនា ឆ្នាំ២០២៣

# © រក្សាសិទ្ធិអ្នករៀបរៀង

សៀវភៅណែនាំស្តីពីកាតព្វកិច្ចក្នុងការចុះបញ្ជីអាជីវកម្មសម្រាប់អាជីវកម្មភោជនីយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានចំណងជើងថា "ចុះបញ្ជីអាជីវកម្មភោជនីយដ្ឋានត្រឹមរយៈពេល៨ថ្ងៃ!" គឺជាកម្មសិទ្ធិរបស់សមាគមភោជនីយដ្ឋានកម្ពុជា។

រាល់ការផលិត ឬការថតចម្លងឡើងវិញនូវស្នាដៃនេះ ទោះបីទាំងស្រុងក្តី ឬជាភាគក្តី និង ឬតាមរយៈការប្រើមធ្យោបាយណាក៏ដោយ ត្រូវបានហាមឃាត់ជាដាច់ខាត កាលបើពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសំណាក់អ្នករៀបរៀងទេនោះ។

ការបំពានលើសិទ្ធិអ្នករៀបរៀង គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវទទួលការផ្តន្ទាទោសពិន័យជាប្រាក់ និងដាក់ពន្ធនាគារ ដោយអនុលោមតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣។



លោកអ្នកអាចស្នើសុំការអនុញ្ញាតពីសមាគម តាមរយៈ៖

- សមាគមភោជនីយដ្ឋានកម្ពុជា
- អាសយដ្ឋាន៖ វិទ្យាស្ថានម្ហូបអាហារកម្ពុជា ជាន់ទី៣ អគារលេខ២៣ (ACAC) ផ្លូវ១៣៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- អ៊ីមែល៖ manager@cambodiarestaurantassociation.com.kh
- ទូរស័ព្ទ៖ +៨៥៥ ៧៦ ២២២ ៨៨៨៦
- គេហទំព័រ៖ https://cambodiarestaurantassociation.org.kh



បោះពុម្ពដោយ សមាគមភោជនីយដ្ឋានកម្ពុជា

បោះពុម្ពផ្សាយលើកទី១

ខែមីនា ឆ្នាំ២០២៣


ខ្លឹមសារទាំងអស់នៃសៀវភៅណែនាំនេះ ត្រូវបានផ្អែកទៅលើមូលដ្ឋានច្បាប់ដែលមានសុពលភាពនៅត្រឹមពេលដែលសមាគមបោះពុម្ពសៀវភៅនេះ។ សមាគមព្យាយាមធ្វើបច្ចុប្បន្នភាពសៀវភៅរបស់យើង ក៏ប៉ុន្តែច្បាប់តែងមានការផ្លាស់ប្តូរជាប្រចាំ ដូចនេះលោកអ្នកចាំបាច់ត្រូវតាមដានបច្ចុប្បន្នភាពច្បាប់ពាក់ព័ន្ធជាទៀងទាត់។

សៀវភៅនេះ មិនមានបំណងបង្កើតជាដំបូន្មានផ្នែកច្បាប់នោះទេ។ ព័ត៌មាន និងខ្លឹមសារទាំងអស់ដែលមាននៅក្នុងសៀវភៅណែនាំនេះ គឺសម្រាប់គោលបំណងផ្តល់ព័ត៌មានទូទៅតែប៉ុណ្ណោះ។

ដើម្បីទទួលបានដំបូន្មានជាក់លាក់ពាក់ព័ន្ធនឹងការចុះបញ្ជី សូមទាក់ទងក្រសួងស្ថាប័នដែលមានសមត្ថកិច្ច។

# អំពីសាវតារសមាគមភោជនីយដ្ឋានកម្ពុជា

## សមាគមភោជនីយដ្ឋានកម្ពុជា

ត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ២០១០ ដោយមានកិច្ចសហការពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (The International Finance Corporation) និងគាំទ្រជ្រោមជ្រែងពី ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍។ សមាគមភោជនីយដ្ឋានកម្ពុជា គឺជាសមាគមមិនស្វែងរកប្រាក់ចំណេញដែលបានចុះបញ្ជីស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ សមាគមភោជនីយដ្ឋានកម្ពុជា គឺជាការចងសម្ព័ន្ធគ្នារវាងនីតិបុគ្គលជាក្រុមហ៊ុនចុះបញ្ជីស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរូបវន្តបុគ្គលដែលមានគោលបំណង និងទស្សនៈវិស័យលើកស្ទួយវិស័យភោជនីយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយសុឆន្ទៈរវាងគ្នាទៅវិញទៅមក និងមានគោលដៅរួមតែមួយ។



**ដើម្បីសម្រេចគោលបំណងខាងលើ សមាគមកំណត់គោលដៅសកម្មភាពដូចខាងក្រោម៖**

១- បង្កើនកិច្ចសហការល្អរវាងសមាជិកសមាគមភោជនីយដ្ឋានកម្ពុជា និងលើកទឹកចិត្តសមាជិកទាំងអស់ឱ្យចូលរួមផុសផុលក្នុងការអភិវឌ្ឍវិស័យភោជនីយដ្ឋានកម្ពុជាប្រកបដោយនិរន្តភាព

២- រៀបចំបង្កើតជាវគ្គបណ្តុះបណ្តាលសម្រាប់សាធារណៈជនទូទៅ និងប្រតិបត្តិករក្នុងវិស័យភោជនីយដ្ឋានដែលពួកគេនឹងទទួលបានសញ្ញាបត្របញ្ជាក់សមត្ថភាពទទួលស្គាល់ថ្នាក់ជាតិ និងអន្តរជាតិដោយឆ្លងកាត់ការប្រឡងសមត្ថភាព

៣- ចូលរួមជាយុទ្ធសាស្ត្រ និងគោលនយោបាយសំដៅជំរុញភាពជាដៃគូរវាងរដ្ឋ និងឯកជន

៤- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ សប្បុរសជន សមាគមអាជីវកម្មជាតិ និងអន្តរជាតិដទៃផ្សេងទៀតដែលមានគោលដៅស្រដៀងគ្នាដើម្បីទ្រទ្រង់វិស័យភោជនីយដ្ឋាននៅកម្ពុជា

៥- ផ្សព្វផ្សាយ ផ្តល់ជាព័ត៌មានរួមទាំងផ្តល់បច្ចុប្បន្នភាពបទដ្ឋានគតិយុត្តិពាក់ព័ន្ធដល់សមាជិករបស់សមាគមសំដៅជំរុញការអនុវត្តល្អបំផុតនៅក្នុងផ្នែកគ្រប់គ្រង និងស្តង់ដារគុណភាព សុវត្ថិភាព អនាម័យ និងអភិបាលកិច្ចល្អ ក្នុងនាមជាប្រតិបត្តិករភោជនីយដ្ឋាន

៦- រៀបចំបាឋកថាកិច្ចប្រជុំសាធារណៈ ការបណ្តុះបណ្តាល និងសន្និសីទសាធារណៈទាក់ទងនឹងការជំរុញការអប់រំមានលក្ខណៈទូទៅ វិជ្ជាជីវៈ ឬបច្ចេកទេស ជំនាញថ្មីៗពាក់ព័ន្ធនឹងឧស្សាហកម្មភោជនីយដ្ឋាន និងឧស្សាហកម្មទេសចរណ៍ដើម្បីបង្កើនធនធានមនុស្សដែលមានគុណវុឌ្ឍិ ចំណេះ ជំនាញតាមតម្រូវការក្នុងបរិបទនៃសកលភាវូបនីយកម្ម

៧- បំពេញសកម្មភាព ឬរៀបចំព្រឹត្តិការណ៍ទាំងឡាយណាដែលពាក់ព័ន្ធនឹងគោលបំណងរបស់សមាគមភោជនីយដ្ឋានកម្ពុជា។

# ចំណាប់អារម្មណ៍របស់ប្រធានសមាគមភោជនីយដ្ឋានកម្ពុជា



**សមាជិក និងសហគ្រិនទាំងអស់ជាទីគោរព!**

សៀវភៅនេះ ត្រូវបានរៀបចំឡើងដោយក្រុមការងារនៃសមាគមភោជនីយដ្ឋានកម្ពុជាក្នុងឆ្នាំ២០២៣ ក្នុងគោលបំណងបញ្ជ្រាបនូវចំណេះដឹងពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្មភោជនីយដ្ឋាននៅកម្ពុជា។ សៀវភៅណែនាំនេះរៀបរាប់យ៉ាងក្បោះក្បាយតាមដំណាក់កាលនីមួយៗ អំពីនីតិវិធីនៃការចុះបញ្ជីអាជីវកម្មភោជនីយដ្ឋាន និងបែបបទនៃការស្នើសុំវិញ្ញាបនបត្រ អាជ្ញាបណ្ណ ឬ/និង លិខិតអនុញ្ញាត ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច រួមមានក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ (អគ្គស្នងការដ្ឋាននគរបាលជាតិ) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង ក្រសួង/អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ក៏ដូចជាផ្សព្វផ្សាយបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធដើម្បីធានាបាននូវការប្រកបអាជីវកម្មភោជនីយដ្ឋាន អនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ សមាគមជឿជាក់ថា ស្នាដៃមួយនេះនឹងចូលរួមចំណែកលើកកម្ពស់អនុលោមភាពច្បាប់ ជាពិសេសវប្បធម៌ចុះបញ្ជីអាជីវកម្មក្នុងសង្គមកម្ពុជាដើម្បីធានាបរិស្ថានធុរកិច្ចសមធម៌មួយដែលជាផ្នែកមិនអាចខ្វះបានក្នុងការអនុវត្តកំណែទម្រង់ស៊ីជម្រៅនៃយុទ្ធសាស្ត្រចតុ- កោណ របស់រាជរដ្ឋាភិបាល។

សៀវភៅណែនាំនេះ ត្រូវបានរៀបចំជាពិសេសសម្រាប់សហគ្រិន ពាណិជ្ជករ ម្ចាស់អាជីវកម្ម ឬសហគ្រាស ដែលចង់ចាប់ផ្តើមអាជីវកម្មភោជនីយដ្ឋានលើកដំបូង និងម្ចាស់សហគ្រាសភោជនីយដ្ឋានដែលកំពុងដំណើរការស្រាប់ អាចទទួលបាននូវចំណេះដឹងបន្ថែម ក៏ដូចជាជ្រួតជ្រាបអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលបានធ្វើវិសោធនកម្មជាបន្តបន្ទាប់។ សៀវភៅនេះត្រូវបានរៀបរៀងជាពីរភាសាគឺ ភាសាខ្មែរ និងភាសាអង់គ្លេស។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងទេសចរណ៍ អគ្គនាយកដ្ឋានពន្ធដារ ក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងមហាផ្ទៃ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ការណែនាំបច្ចេកទេស ការផ្តល់ជាមតិយោបល់ក្នុងន័យស្ថាបនាជាការគាំទ្រចំពោះក្រុមការងាររបស់សមាគមភោជនីយដ្ឋានកម្ពុជា ក្នុងអំឡុងពេលតាក់តែងសៀវភៅណែនាំនេះ។

ទន្ទឹមនេះផងដែរ សមាគមពិតជាអរគុណនូវទឹកចិត្តសប្បុរសចូលរួមគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនបដិសណ្ឋារកិច្ចថាលាស ក្រុមហ៊ុន ខូហ្វី ខូអិលធីឌី ក្រុមហ៊ុន ប្រោន ខហ្វហ្វី ក្រុមហ៊ុន ខហ្វហ្វី ខនសិប (ខេមបូឌា)លីមីតធីត ឯ.ក ក្រុមហ៊ុន វង្ស& មាស រេសថឺរេន ក្រុមហ៊ុន រៀល ហ៊្វូដ & បេវើរីច ក្រុមហ៊ុន កាវ៉ាណាក កយ កាហ្វេ ក្រុមហ៊ុន ហ្គូមេ បេវើរីច សឺលូសិន ឯ.ក ក្រុមហ៊ុន ប៉ែកយ៉ាដ កាហ្វេ ក្រុមហ៊ុន អ៊ី អេហ្វ ជី(អិចប្រេសហ្វ៊ូដគ្រុប) ភីធីអ៊ី អិលធីឌី ភោជនីយដ្ឋាន ផ្ទះទាហាងនំប៉ុង ឡឺប៉ុងប៉ាតេ និង ភោជនីយដ្ឋាន វាយោនរា ដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការលើកកម្ពស់អនុលោមភាពច្បាប់។

សមាគមភោជនីយដ្ឋានកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា សៀវភៅមគ្គុទ្ទេសក៏នេះ ជាឧបករណ៍មួយដ៏សំខាន់ រួមចំណែកក្នុងការជំរុញការអនុវត្តច្បាប់ សម្រាប់ឧស្សាហកម្មភោជនីយដ្ឋាននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ យើងខ្ញុំសង្ឃឹមជឿជាក់ថាសៀវភៅណែនាំនេះនឹងទទួលបានការគាំទ្រពីរាជរដ្ឋាភិបាល និងក្រសួងស្ថានប័នពាក់ព័ន្ធទាំងអស់។

សមាគមភោជនីយដ្ឋានកម្ពុជា សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ក្រុមការងារនៃសមាគមភោជនីយដ្ឋានកម្ពុជាចំពោះការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការតាក់តែង និងអ្នកទាំងអស់គ្នាដែលបានចូលរួមចំណែកសម្រេចនូវសមិទ្ធិផលដ៏ត្រចះត្រចង់មួយនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣

ប្រធានសមាគម

**ARNAUD DARC**

តើសហគ្រិនត្រូវបំពេញនីតិវិធីដូចម្តេចខ្លះ ដើម្បីអាចប្រតិបត្តិការអាជីវកម្ម ភោជនីយដ្ឋាននៅកម្ពុជាដោយស្របច្បាប់ ?

នេះជាមគ្គុទ្ទេសក៏ដែលអ្នកបានទន្ទឹងរង់ចាំ !

រៀបចំដោយ

សមាគមភោជនីយដ្ឋានកម្ពុជា

# មាតិកា


អំពីសារតារសមាគមភោជនីយដ្ឋានកម្ពុជា........................................................................ ....i
ចំណាប់អារម្មណ៍របស់ ប្រធានសមាគមភោជនីយដ្ឋានកម្ពុជា.................................................... ..ii
តើសហគ្រិនត្រូវបំពេញនីតិវិធីដូចម្តេចខ្លះ ដើម្បីអាចប្រតិបត្តិការអាជីវកម្មភោជនីយដ្ឋាននៅកម្ពុជាដោយស្របច្បាប់ ?...iii
ហេតុអ្វីបានជាអ្នកចាំបាច់ត្រូវចុះបញ្ជីអាជីវកម្មភោជនីយដ្ឋានរបស់អ្នក ?............................................vii
ជំពូកទី១ គំនូសបំព្រួញ វិហ្វូរនីតិវិធីនៃការចុះបញ្ជីអាជីវកម្មនៅក្រសួងពាក់ព័ន្ធ.................................. ...១
ជំពូកទី២ ទ្រង់ទ្រាយនៃសហគ្រាសពាណិជ្ជកម្ម......... ...............................................................៦

១. សហគ្រាសឯកបុគ្គល...............................................................................................៧
២. ក្រុមហ៊ុនមូលធន.....................................................................................................៨

ជំពូកទី៣ អនុលោមតាពជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ................... .........................................១០

១. ដំណើរការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន..............................................................១២
២. អនុលោមតាពជាមួយក្រសួងពាណិជ្ជកម្ម ...................................................................................១៤
២.១ ការបម្រុងទុកនាមករណ៍សហគ្រាស........................................................................................១៤
២.២ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ................................................................................................១៤
២.៣ ការចុះបញ្ជីកែប្រែ ផ្លាស់ប្តូរព័ត៌មានរបស់ក្រុមហ៊ុន.....................................................................១៤
២.៤ ការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទ................................................................១៥
២.៥ ការចុះបញ្ជីម៉ាក នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម.................................................១៥
៣. អនុលោមតាពសម្រាប់ការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក..................................................១៦
៣.១ ការស្នើសុំវិញ្ញាបនបត្រសេវាអនឡាញ ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍..................................១៦
៣.២ ការស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ឈ្មោះដែនជាតិពីនិយ័តករទូរគមនាគមន៍កម្ពុជា នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍..................................................................................................................១៦
៣.៣ ការស្នើសុំលិខិតអនុញ្ញាត/អាជ្ញាបណ្ណប្រកបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពីក្រសួងពាណិជ្ជកម្ម..............១៧
៣.៤ ពិន័យអន្តរការណ៍.................................................................................................................១៨
៤. អនុលោមតាពជាមួយ អគ្គនាយកដ្ឋានពន្ធដារ..............................................................................១៩
៤.១. ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មាន....................................................................១៩
៤.២. ពន្ធប៉ាតង់........................................................................................................................១៩
៤.៣. ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ.................................................................................................២០
៤.៤. ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ...................................................................................២០
៤.៥. ពន្ធអប្បបរមា....................................................................................................................២០
៤.៦. អាករលើតម្លៃបន្ថែម...........................................................................................................២១
៤.៦.១ អាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) ចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ..........................................................................................២១
៤.៧. ពន្ធលើចំណេញមូលធន.....................................................................................................២២
៤.៨. អាករបំភ្លឺសាធារណៈ:.........................................................................................................២២
៤.៩. ពន្ធកាត់ទុក.......................................................................................................................២២
៤.១០. ពន្ធលើប្រាក់បៀវត្សប្រចាំខែ................................................................................................២៣
៤.១១. ពន្ធតែមប្រើសារពើពន្ធ.....................................................................................................២៣
៤.១២. ពន្ធលើអត្ថប្រយោជន៍បន្ថែម..............................................................................................២៥
៤.១៣. អាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក............................................................២៦

៨.១៤. ការប្រកាសបិទអាជីវកម្ម........................................២៦
៨.១៥. កាតព្វកិច្ចអនុលោមតាពសារពើពន្ធ សម្រាប់អ្នកជាប់ពន្ធតូច........................................២៧
៨.១៦. ការពិន័យ និងទោសទណ្ឌ ចំពោះការដាក់លិខិតប្រកាស និងបង់ពន្ធយឺតយ៉ាវ........................................២៩
៨.១៧. សវនកម្មពន្ធដារ........................................៣០
៨.១៧.១ កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុ ឱ្យរងសវនកម្មឯករាជ្យ និងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យរួចមកនិយ័តករគណនេយ្យ និងសវនកម្ម........................................៣២
៨.១៧.២ ការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត........................................៣៣
៨.១៨. ការដាក់តាំងឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារ នៅទីកន្លែងធ្វើសកម្មភាពសេដ្ឋកិច្ច........................................៣៤
៩. អនុលោមតាពជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ........................................៣៥
៩.១. ការចុះបញ្ជិកាសេចក្តីជូនដំណឹងប្រកាសបើកសហគ្រាស........................................៣៦
៩.២. ការចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន........................................៣៦
៩.៣. ការចុះបញ្ជិកាសៀវភៅបើកប្រាក់/ផ្តល់លិខិតអនុញ្ញាតបើកប្រាក់តាមប្រព័ន្ធកុំព្យូទ័រ........................................៣៦
៩.៤. ការស្នើសុំចុះទិដ្ឋាការបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស........................................៣៦
៩.៥. ការបញ្ជាក់វិញ្ញាបនបត្រពិនិត្យកាយសម្បទានិយោជិតខ្មែរ........................................៣៦
៩.៦. ការផ្តល់សៀវភៅការងារ និងប័ណ្ណសម្គាល់កម្មករនិយោជិតខ្មែរ........................................៣៧
៩.៧. បច្ចុប្បន្នភាពទិដ្ឋាការ "ចូល" ឬ "ចេញ" លើសៀវភៅការងារ........................................៣៧
៩.៨. ការផ្តល់ទុតិយតាសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ........................................៣៧
៩.៩. ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក........................................៣៧
៩.១០. ការប្រើប្រាស់កម្មករនិយោជិតវ័យក្មេង........................................៣៨
៩.១១. ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាសធ្វើការបន្ថែមម៉ោង /ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ /ថ្ងៃឈប់សម្រាកបុណ្យដែលមានប្រាក់ឈ្នួល........................................៣៨
៩.១២. ការហ្វឹកហ្វឺនកូនជាង/កម្មសិក្សា........................................៣៨
៩.១៣. កាតព្វកិច្ចរបស់ក្រុមហ៊ុន សហគ្រាស ក្នុងការរៀបចំបន្ទប់សម្រាប់បំបៅដោះកូន និងទារកដ្ឋាននៅក្នុងសហគ្រាស ឬនៅជិតនោះ........................................៣៩
៩.១៤. ការបង្កើតតិលានដ្ឋានសហគ្រាស........................................៣៩
៩.១៥. ការងារសម្រាប់ជនមានពិការភាព........................................៣៩
៩.១៦. ការបង្កើតគណៈកម្មការអេដស៍........................................៤០
៩.១៧. ការប្រើប្រាស់ហត្ថពលកម្មបរទេស........................................៤០
៩.១៧.១ ការផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស........................................៤០
៩.១៧.២ ការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស........................................៤០
៩.១៧.៣ ការផ្តល់បណ្ណការងារ សៀវភៅការងាររបស់ជនបរទេស........................................៤១
៩.១៨. កាតព្វកិច្ចស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម........................................៤១
៩.១៩. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន/ កម្មករនិយោជិត ជាមួយបេឡាជាតិរបបសន្តិសុខសង្គម........................................៤៣
៩.១៩.១. ផ្នែកហានិភ័យការងារ........................................៤៣
៩.១៩.២ ផ្នែកថែទាំសុខភាព........................................៤៣
៩.១៩.៣ ផ្នែកប្រាក់សោធន........................................៤៤
៩.១៩.៤ ការចុះបញ្ជីសហគ្រាស/គ្រឹះស្ថាននៅក្នុងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន........................................៤៤

៦. អនុលោមតាពជាមួយក្រសួងសុខាភិបាល ( នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង )....................៤៦
    ៦.១. កាតព្វកិច្ចដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់អនាម័យ........................................................៤៦
    ៦.២. កាតព្វកិច្ចដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ........................................៤៧
៧. អនុលោមតាពជាមួយក្រសួងទេសចរណ៍........................................................................................៤៨
    ៧.១. ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន................................................៤៨
    ៧.២. ចំណាត់ថ្នាក់ភោជនីយដ្ឋាន និងអាហារដ្ឋាន..........................................................................៤៩
    ៧.៣. ការដាក់តាំងស្លាកយីហោអាជីវកម្មដ្ឋានទេសចរណ៍...................................................................៤៩
    ៧.៤. ស្តង់ដារចលនាប្រឡងប្រណាំងធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍...............................................៥០
៨. អនុលោមតាពជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬ ការិយាល័យច្រកចេញចូលតែមួយ..៥២
    ៨.១. ប័ណ្ណអនុញ្ញាតវិស័យវប្បធម៌ និងវិចិត្រសិល្ប: (លើកផ្ទាំងយីហោអាជីវកម្ម).........................................៥២
៩. អនុលោមតាពជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ..........................................................៥៣
    ៩.១. ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យចេញដោយអគ្គស្នងការដ្ឋាននគរបាលជាតិ........................................................................................៥៣
    ៩.២ កាតព្វកិច្ចរបស់ម្ចាស់សំណង់ ឬម្ចាស់គោលដៅ........................................................................៥៤
    ៩.៣ ទោសប្បញ្ញត្តិ.........................................................................................................៥៤
១០. អនុលោមតាពជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.....................................................................៥៥
    ១០.១. ការចុះឈ្មោះប្រើប្រាស់ឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធើណិត..........................................................៥៥
    ១០.២. នីតិវិធីស្តីពី ដំណើរការស្នើសុំចុះឈ្មោះដែនជាតិ .kh តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (សម្រាប់សហគ្រាសពាណិជ្ជកម្ម ឬសហគ្រាសសាធារណ:)........................................................................................៥៦
    ១០.៣ ដំណើរការក្នុងការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ/អាជ្ញាបណ្ណសេវាអនឡាញ..................................................៥៧
១១. អនុលោមតាពជាមួយក្រសួងបរិស្ថាន......................................................................................៥៨
    ១១.១.សមត្ថកិច្ចនៅរដ្ឋបាលថ្នាក់ជាតិ..........................................................................................៥៨
        ១១.១.១. កិច្ចសន្យាការពារបរិស្ថាន..........................................................................................៥៨
        ១១.១.២. ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន..............................................................៥៨
    ១១.២ សមត្ថកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ.....................................................................................៥៩
        ១១.២.១. កិច្ចសន្យាការពារបរិស្ថាន..........................................................................................៥៩
        ១១.២.២. ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន..............................................................៥៩
១២. អនុលោមតាពជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍..............................................៦១
    ១២.១. កាតព្វកិច្ចក្នុងការស្នើសុំបង្កើតសិប្បកម្ម..................................................................................៦១
    ១២.២. កាតព្វកិច្ចក្នុងការស្នើសុំអនុញ្ញាតដំណើរការសិប្បកម្ម.......................................................................៦១
    ១២.៣. កាតព្វកិច្ចក្នុងការស្នើសុំអាជ្ញាបណ្ណប្រើសញ្ញាចុះបញ្ជីផលិតផល ចេញដោយវិទ្យាស្ថានស្តង់ដារកម្ពុជា..................៦២
១៣. អធិការកិច្ចដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច......................................................................................៦៣

# ហេតុអ្វីបានជាអ្នកចាំបាច់ត្រូវចុះបញ្ជីអាជីវកម្មភោជនីយដ្ឋានរបស់អ្នក ?

ដោយអនុលោមតាមច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលបានអនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩៥ ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ដែលបានអនុម័តដោយរដ្ឋសភា កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយដែលមានគ្រឹះស្ថានរបស់ខ្លួន សាខាបុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួន នៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅកន្លែងដែលខ្លួនធ្វើអាជីវកម្មយ៉ាងតិចបំផុត ១៥(ដប់ប្រាំ)ថ្ងៃ មុនពេលចាប់ផ្ដើមធ្វើពាណិជ្ជកម្មរបស់ខ្លួន។ ជាមួយគ្នានេះ អនុលោមតាមច្បាប់ស្ដីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់ បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល១៥(ដប់ប្រាំ) ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្ដើមធ្វើសកម្មភាពសេដ្ឋកិច្ច។ យោងតាមអនុក្រឹត្យលេខ៨៤ អនក្រ.បក របស់រាជរដ្ឋាភិបាល ស្ដីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ក្នុងគោលបំណងសម្រួល និងបង្កបរិយាកាសល្អដល់ការបង្កើតអាជីវកម្មតាមរយៈការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលតាមរយៈប្រព័ន្ធនេះបុគ្គលស្នើសុំអាចជារូបវន្តបុគ្គល ឬនីតិបុគ្គលអាចដាក់ពាក្យស្នើសុំចុះបញ្ជីដូចខាងក្រោម៖

- ស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ជាមួយក្រសួងពាណិជ្ជកម្ម
- ស្នើសុំចុះបញ្ជីពន្ធដារ ជាមួយអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ស្នើសុំការពិនិត្យ និងទទួលសេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស ពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ស្នើសុំចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍នៃកម្ពុជា
- ស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍
- ស្នើសុំប្រកាសបង្កើតសហគ្រាសធុនតូច និងមធ្យម ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ស្នើសុំផ្ដល់សេវាសាធារណៈសម្រាប់អាជីវកម្មបញ្ចាំពីនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ អាជ្ញាបណ្ណ ប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង
- ស្នើសុំប្រើប្រាស់ឈ្មោះដែនជាតិ ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

លោកអ្នកដឹងទេ ការសម្រេចចិត្តចុះបញ្ជីអាជីវកម្ម ជាជម្រើសដ៏ឆ្លាតវៃនៅពេលដែលលោកអ្នកក្លាយជាម្ចាស់អាជីវកម្មដំបូង។ ការចុះបញ្ជីអាជីវកម្មផ្ដល់នូវអត្ថប្រយោជន៍ទាំងផ្នែកច្បាប់ និងផ្នែកសេដ្ឋកិច្ច ដូចខាងក្រោម៖

- ការចុះបញ្ជី ផ្ដល់ឱ្យនូវភាពប្រាកដប្រជា និងការការពារដោយច្បាប់នៅក្នុងអំឡុងពេលប្រតិបត្តិការសកម្មភាពអាជីវកម្ម។
- ការចុះបញ្ជី គឺធ្វើឱ្យអាជីវកម្មលោកអ្នកទទួលបាននូវនីតិបុគ្គលិកលក្ខណៈ អត្តសញ្ញាណស្របច្បាប់ សិទ្ធិជាភ្នាក់ងារកាត់ទុក និងប្រមូលពន្ធអាករពីអតិថិជនសម្រាប់ប្រកាសបង់ពន្ធមករដ្ឋបាលសារពើពន្ធ តាមរយៈការទទួលបាននូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម វិញ្ញាបនបត្រសម្គាល់ការចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម - អតប)
- នៅពេលដែលអាជីវកម្មរបស់អ្នកត្រូវបានចុះបញ្ជីនាមករណ៍របស់ក្រុមហ៊ុន ទទួលបានការការពារប្រឆាំងនឹងទង្វើមិនស្របច្បាប់របស់ភាគីទីបី ការប្រកួតប្រជែងមិនស្មោះត្រង់
- ការធ្វើអាជីវកម្មស្របច្បាប់ អនុលោមតាមច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាន
- ជៀសវាងការផាកពិន័យ និងការបិទអាជីវកម្ម ដោយមូលហេតុប្រកបអាជីវកម្មដោយគ្មានការអនុញ្ញាត
- ទទួលបាននូវកេរ្តិ៍ឈ្មោះ ទាក់ទាញការវិនិយោគ និងទំនុកចិត្តលើអាជីវកម្ម (ជំនឿទុកចិត្តពីនិយោជិត អ្នកផ្គត់ផ្គង់ អ្នកប្រើប្រាស់ អតិថិជន និងដៃគូសហការ) ធ្វើឱ្យអាជីវកម្មអាចរីកលូតលាស់ប្រកបដោយនិរន្តរភាព
- ការចុះបញ្ជីនឹងផ្ដល់ឱកាសសម្រាប់ក្រុមហ៊ុនអាចស្នើសុំហិរញ្ញប្បទានពីធនាគារ អ្នកវិនិយោគ និងស្ថាប័នកម្ចីផ្សេងៗ ដើម្បីពង្រីកអាជីវកម្ម និងទីផ្សាររបស់ខ្លួនឱ្យកាន់តែឆាប់រហ័ស។ ក្រុមហ៊ុនក៏អាចបន្ថែមម្ចាស់ភាគហ៊ុនថ្មីអាចទាក់ទាញវិនិយោគិនដើម្បីពង្រីកដើមទុនអាជីវកម្ម។
- កម្មករនិយោជិតរបស់សហគ្រាសដែលបានចុះបញ្ជី មានសិទ្ធិទទួលបានអត្ថប្រយោជន៍ស្របច្បាប់ (ក្រុមហ៊ុនគោរពច្បាប់ការងារ និងមានលក្ខខណ្ឌការងារល្អប្រសើរ ជាលក្ខខណ្ឌទាក់ទាញនិយោជិតដែលមានជំនាញឲ្យចូលបម្រើការងារ និងមានសិទ្ធិទទួលផលប្រយោជន៍ដែលច្បាប់ផ្ដល់ឱ្យ រួមមានការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកប្រាក់សោធន)។

ផ្ទុយទៅវិញ ការខកខានមិនបានចុះបញ្ជីពាណិជ្ជកម្ម ជាគោលការណ៍ ម្ចាស់អាជីវកម្មត្រូវបានសន្មតថាកំពុងតែធ្វើអាជីវកម្មមិនស្របច្បាប់ និងត្រូវបានចាត់ទុកជាអំពើរាំងស្ទះចំពោះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ហើយអាជីវកម្មរបស់លោកអ្នកនឹងតម្រូវឲ្យចុះបញ្ជី និងកំណត់ពន្ធឡើងវិញជាឯកតោភាគី។ ជាផលវិបាក ម្ចាស់អាជីវកម្មត្រូវបញ្ឈប់សកម្មភាពអាជីវកម្មរបស់ខ្លួនជាបន្ទាន់ ហើយ/ឬ នឹងប្រឈមការពិន័យដោយអនុលោមតាមមាត្រា៤០កថាខណ្ឌទី១នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។ មិនត្រឹមតែប៉ុណ្ណោះ ម្ចាស់អាជីវកម្មអាចប្រឈមមុខទៅនឹងការប្តឹង ឬការដាក់វិធានការវិន័យផ្សេងៗចំពោះសកម្មភាពអាជីវកម្មខុសច្បាប់។

ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មដែលមិនបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមបទបញ្ញត្តិ នឹងត្រូវប្តឹងទៅតុលាការពីបទប្រកបសកម្មភាពពាណិជ្ជកម្មមិនស្របច្បាប់ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី៥០,០០០(ប្រាំម៉ឺន)រៀល ទៅ ៥០០,០០០ (ប្រាំសែន) រៀល ៖

១) ចំពោះរាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែលមិនបានចុះបញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិ

២) រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មហើយតែមិនបានចុះនៅលើវិក្កយបត្រ លិខិតស្នាមកំណត់បញ្ជាទិញ តារាងតម្លៃ និងឯកសារក្រុមហ៊ុនផ្សេងទៀត នូវអាសយដ្ឋាន ទីស្នាក់ការ និង លេខចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន។



សួស្តី! ខ្ញុំឈ្មោះឪណា និងមិត្តភិក្តរបស់ខ្ញុំឈ្មោះ សំ
ពួកយើងមានបំណងចង់បើកភោជនីយដ្ឋានមួយ
កន្លែងរួមគ្នា នៅរាជធានីភ្នំពេញ។
តើអ្នកអាចណែនាំពួកយើង អំពីនីតិវិធីនៃការ
ចុះបញ្ជីអាជីវកម្ម បានដែរឬទេ?

សួស្តី ឪណា!
ខ្ញុំនឹងបង្ហាញអ្នកនូវនីតិវិធីនៃការ
ចុះបញ្ជីអាជីវកម្ម ដូចតទៅនេះ!









ជាដំបូង សូមពិនិត្យមើលនីតិវិធីនៃការចុះបញ្ជីអាជីវកម្ម
តាមដំណាក់កាលដូចតទៅ៖

# គំនូសបំព្រួញ រំហូរនីតិវិធីនៃការចុះបញ្ជីអាជីវកម្ម នៅក្រសួងពាក់ព័ន្ធ

ភោជនីយដ្ឋាន/ អាហារដ្ឋាន

ភោជនីយដ្ឋាន

កំណត់ទ្រង់ទ្រាយ

បង្កើតឡើង និងជាកម្មសិទ្ធិ ១០០% របស់បុគ្គលតែម្នាក់

បង្កើតឡើង និងជាកម្មសិទ្ធិរបស់ម្ចាស់ភាគហ៊ុនទាំងអស់

តើអ្នកចង់ចាប់ផ្ដើមអាជីវកម្ម តែម្នាក់ឯង ឬជាការសហការ បណ្ដាក់ទុនរួមគ្នា ដោយមានរចនាសម្ព័ន្ធដឹកនាំ គ្រប់គ្រងក្រុមហ៊ុន ច្បាស់លាស់?

បុគ្គលតែម្នាក់ ដែលមានដើមទុនផ្ទាល់ខ្លួន

- ម្ចាស់ភាគហ៊ុនចាប់ពី ២ (ពីរ) នាក់ឡើងទៅ
- ក្រុមហ៊ុនមានរចនាសម្ព័ន្ធច្បាស់លាស់ចែងដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន

តើជម្រើសទាំងពីរខាងលើនេះ មានភាពខុសគ្នាយ៉ាងដូចម្ដេចទៅ?

ទ្រង់ទ្រាយនៃសហគ្រាសពាណិជ្ជកម្ម

ក្រុមហ៊ុនមូលធន

សហគ្រាសឯកបុគ្គល

- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ប្រាកដណាស់ជម្រើសទាំងពីរខាងលើមានភាពខុសគ្នាត្រង់ថា៖
នៅក្នុងជម្រើសទី១ អ្នកត្រូវជ្រើសរើសចុះបញ្ជីពាណិជ្ជកម្មក្រោមទ្រង់ទ្រាយជា សហគ្រាសឯកបុគ្គល ឬជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត។

នៅក្នុងជម្រើសទី២ អ្នកត្រូវជ្រើសរើសចុះបញ្ជីពាណិជ្ជកម្ម ក្រោមទ្រង់ទ្រាយជា ក្រុមហ៊ុនមូលធន។

## ចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

https://www.registrationservices.gov.kh

ជាដំបូង លោកអ្នកត្រូវបង្កើតគណនីលើកម្មវិធី CamdigiKey។ បន្ទាប់ពីទទួលបាន CamdigiKey លោកអ្នកអាចចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានជាមួយ ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រយៈពេលត្រឹម៨ (ប្រាំបី) ថ្ងៃ។



**ក្រសួងពាណិជ្ជកម្ម**

- **សហគ្រាសអាចបម្រុងទុកនាមករណ៍ក្រុមហ៊ុន/ សហគ្រាស (មិនមែនជាកាតព្វកិច្ច)**
- ចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន/ សហគ្រាស

**អគ្គនាយកដ្ឋានពន្ធដារ**

- កំណត់ឆ្នាំជាប់ពន្ធ និងកាលបរិច្ឆេទផ្គត់ផ្គង់ទំនិញ និងសេវាដំបូង
- ប៉ាន់ស្មានផលរបរប្រចាំឆ្នាំ ដើម្បីកំណត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធ និងបង់ពន្ធប៉ាតង់សម្រាប់សកម្មភាពអាជីវកម្ម

**ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស

បន្ទាប់ពីដាក់បញ្ជូនឯកសារនៅក្នុងប្រព័ន្ធរួចរាល់ លោកអ្នកត្រូវរង់ចាំរយៈពេល៨ថ្ងៃ ដើម្បីទទួលបានអាជ្ញាបណ្ណ និងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថលតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដូចខាងក្រោម៖

១. វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មចេញដោយក្រសួងពាណិជ្ជកម្ម
២. វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ប័ណ្ណពន្ធប៉ាតង់ ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ និងលិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ
៣. សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អំឡុងពេលដែលលោកអ្នកបានចុះបញ្ជីដោយជោគជ័យនៅក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោកអ្នកនឹងទទួលបានសារជូនដំណឹងអំពី**អាជ្ញាបណ្ណជំនាញ**ដែលលោកអ្នកនឹងត្រូវស្នើសុំនៅជំហ៊ានបន្ទាប់

**ក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង)**

- ភោជនីយដ្ឋាន និងអាហារដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ត្រូវតែមានវិញ្ញាបនបត្របញ្ជាក់អនាម័យ
- ភោជនីយដ្ឋានខ្នាតធំ និងអាហារដ្ឋានខ្នាតធំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អនិងត្រូវដាក់ពាក្យសុំនៅក្រសួងសុខាភិបាល។ ចំពោះភោជនីយដ្ឋានខ្នាតធំ និងអាហារដ្ឋានខ្នាតធំ ដែលមានវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អហើយ ពុំតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់អនាម័យទេ។

GUIDE

តម្លៃសេវាចុះបញ្ជីអាជិវកម្ម
អាស្រ័យលើទ្រង់ទ្រាយសហគ្រាស។

អ្នកអាចស្វែងរកព័ត៌មានលម្អិតទាំងអស់នៅក្នុងសៀវភៅណែនាំនេះ។

អស្ចារ្យណាស់!



**ក្រសួងទេសចរណ៍**

- នៅពេលទទួលបានវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អពីក្រសួងសុខាភិបាលរួចមក ភោជនីយដ្ឋានចាប់ពី១០០កៅអីឡើងទៅ ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណទេសចរណ៍ តាមថ្នាលបច្ចេកវិទ្យាព័ត៌មានដដែល registrationservices.gov.kh
- សម្រាប់អាជីវកម្មភោជនីយដ្ឋានមានតិចជាង ១០០កៅអី ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណទេសចរណ៍ សម្រាប់ភោជនីយដ្ឋានពីការិយាល័យច្រកចេញចូលតែមួយនៃខណ្ឌដែលអាជីវកម្មស្ថិតនៅ ឬនៅសាលារាជធានីភ្នំពេញ អាស្រ័យដោយចំនួនកៅអី និងសញ្ជាតិរបស់អ្នកគ្រប់គ្រងភោជនីយដ្ឋាន។

អាជ្ញាបណ្ណជំនាញដែលអ្នកត្រូវស្នើសុំ
បន្ទាប់ពីទទួលបានវិញ្ញាបនបត្រចុះបញ្ជី
ពាណិជ្ជកម្ម។ ការស្នើសុំនេះ គឺអាស្រ័យ
ទៅលើសកម្មភាពអាជីវកម្មរបស់លោកអ្នក។

**ការិយាល័យច្រកចេញចូលតែមួយ**

- អាជីវកម្មភោជនីយដ្ឋាន ត្រូវដាក់ពាក្យស្នើសុំប័ណ្ណអនុញ្ញាតវិស័យវប្បធម៌ និងវិចិត្រសិល្បៈ (លើកស្លាកយីហោអាជីវកម្ម) នៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលខណ្ឌ ដែលអាជីវកម្មស្ថិតនៅ។
- សម្រាប់អាជីវកម្មស្ថិតនៅតាមបណ្តាខេត្ត ត្រូវដាក់ពាក្យស្នើសុំនៅរដ្ឋបាលខណ្ឌ/ស្រុក/ក្រុង ដែលអាជីវកម្មស្ថិតនៅ។



**ក្រសួងមហាផ្ទៃ (អគ្គស្នងការដ្ឋាននគរបាលជាតិ)**

- អនុលោមតាមច្បាប់ស្តីពីសុវត្ថិភាពអគ្គិភ័យរបស់ក្រសួងមហាផ្ទៃ អាជីវកម្មភោជនីយដ្ឋានត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៅអគ្គស្នងការដ្ឋាននគរបាលជាតិ។
- ម្ចាស់អាជីវកម្មត្រូវមានវិញ្ញាបនបត្រ បញ្ជាក់អំពីការហ្វឹកហ្វឺនជំនាញបង្ការ និងពន្លត់អគ្គីភ័យចេញដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានីខេត្ត។

ល្អណាស់! នីតិវិធីច្បាស់
លាស់ និងងាយស្រួលយល់

**ក្រសួងបរិស្ថាន**

- ភោជនីយដ្ឋានដែលមានកៅអីចាប់ពី១០០ រហូតដល់ ៥០០ កៅអី មានកាតព្វកិច្ចស្នើសុំចុះកិច្ចសន្យាការពារបរិស្ថាន ជាមួយក្រសួងបរិស្ថាន និងត្រូវបង់មូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំ។
- ភោជនីយដ្ឋានដែលមានចំនួន ក្រោម១០០ កៅអី មានកាតព្វកិច្ចស្នើសុំចុះកិច្ចសន្យាការពារបរិស្ថាន ជាមួយមន្ទីរបរិស្ថាន។
- ភោជនីយដ្ឋាន/អាហារដ្ឋាន ត្រូវបង់មូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំ។



### ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (និយ័តករទូរគមនាគមន៍កម្ពុជា)

- ប្រសិនបើអាជីវកម្មភោនីយដ្ឋានរបស់លោកអ្នកប្រើប្រាស់គេហទំព័រ លោកអ្នកត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់ឈ្មោះដែនជាតិ .com.kh នៅនិយ័តករទូរគមនាគមន៍កម្ពុជា
- ស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ អាជ្ញាបណ្ណ សេវាអនឡាញ សម្រាប់ការធ្វើអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក

### ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍

- ប្រសិនបើអាជីវកម្មភោជនីយដ្ឋានរបស់លោកអ្នកមានផលិត កែច្នៃ វេចខ្ចប់ ចែកចាយ និងដាក់លក់ផលិតផលចំណីអាហារ លោកអ្នកត្រូវស្នើសុំចុះបញ្ជីបង្កើតសិប្បកម្ម
- ស្នើសុំលិខិតអនុញ្ញាតដំណើរការសិប្បកម្មនៅច្រកចេញចូលតែមួយនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង
- ស្នើសុំអាជ្ញាបណ្ណចុះបញ្ជីផលិតផល នៅវិទ្យាស្ថានស្តង់ដារកម្ពុជា






ឥឡូវអ្នកបានដឹងហើយថា ជំហ៊ានដំបូងមុនឈានដល់ការចុះបញ្ជីអាជីវកម្ម
គឺអ្នកត្រូវជ្រើសរើសទ្រង់ទ្រាយសហគ្រាសដែលអ្នកចង់ចុះបញ្ជីអាជីវកម្មជាមុនសិនៗ

នៅក្នុងទំព័រខាងក្រោម អ្នកនឹងបានអានខ្លឹមសារលម្អិតអំពី
សហគ្រាសឯកបុគ្គល និងក្រុមហ៊ុនមូលធនៗ




## ទ្រង់ទ្រាយនៃសហគ្រាសពាណិជ្ជកម្ម

១. សហគ្រាសឯកបុគ្គល

២. ក្រុមហ៊ុនមូលធន

# ១ សហគ្រាសឯកបុគ្គល

ប្រសិនបើអ្នកចង់បើកភោជនីយដ្ឋានមួយ ដែលអ្នកជាម្ចាស់សហគ្រាសមានដើមទុនផ្ទាល់ខ្លួន តែម្នាក់ឯង ហើយមានផលរបរស្ថិតក្នុងចំណាត់ថ្នាក់ជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស នោះអ្នកត្រូវជ្រើសរើសការចុះបញ្ជីអាជីវកម្មរបស់អ្នកជាសហគ្រាសឯកបុគ្គល។

**សហគ្រាសឯកបុគ្គល** គឺជាសហគ្រាសដែលបានបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ ហើយទ្រព្យសម្បត្តិរបស់ម្ចាស់សហគ្រាសឯកបុគ្គលជាដើមទុនរបស់សហគ្រាសឯកបុគ្គល។ ម្ចាស់សហគ្រាសឯកបុគ្គល គឺជា "ពាណិជ្ជករ"។
សហគ្រាសឯកបុគ្គល ដែលស្ថិតក្នុងចំណាត់ថ្នាក់ជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។
កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សហគ្រាសឯកបុគ្គល គឺជាការទទួលខុសត្រូវដោយផ្ទាល់ និងដោយគ្មានកម្រិតលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់សហគ្រាសនោះទេ។ សហគ្រាសឯកបុគ្គលមិនតម្រូវឲ្យមានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសទេ។
សហគ្រាសឯកបុគ្គល មិនមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីម្ចាស់សហគ្រាសឡើយ។

### ប្រសិនបើអាជីវកម្មខ្ញុំ មានផលរបរតិចជាងកម្រិតផលរបរអ្នកជាប់ពន្ធតូច តើខ្ញុំត្រូវជាប់កាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធថ្នាលបច្ចេកវិទ្យាព័ត៌មាន https://www.registrationservices.gov.kh/ ដែរឬទេ?

យោងតាមប្រកាសលេខ០៨០ ពណ ចបព.ប្រក របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការគ្រប់គ្រង និងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មសេវាកម្ម ពាណិជ្ជកម្ម គ្រប់ពាណិជ្ជករ អាជីវករ សេវាករ ដែលមានសញ្ជាតិខ្មែរ និងដែលមានផលរបរប្រចាំឆ្នាំតិចជាង ២៥០ លានរៀល ពុំជាប់កាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្មតាមថ្នាលបច្ចេកវិទ្យានោះទេ។ ប៉ុន្តែពាណិជ្ជករ អាជីវករ សេវាករ ត្រូវមានកាតព្វកិច្ច ស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មសេវាកម្ម ពាណិជ្ជកម្ម ពីការិយាល័យច្រកចេញចូលតែមួយនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលភោជនីយដ្ឋានលោកអ្នកស្ថិតនៅ និងត្រូវចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធជាអ្នកជាប់ពន្ធមានផលរបរប្រចាំឆ្នាំតិចជាង ២៥០លានរៀល។
សំណុំឯកសារតម្រូវសម្រាប់ស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម រួមមាន៖ ពាក្យស្នើសុំប្រកបអាជីវកម្មសេវាកម្ម ពាណិជ្ជកម្ម ភ្ជាប់ជាមួយប្រវត្តិរូបសង្ខេបរបស់ម្ចាស់អាជីវកម្ម និងកិច្ចសន្យាប្រកបអាជីវកម្មចំនួន១ច្បាប់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លង) ១ច្បាប់ ឯកសារបញ្ជាក់ពីទីតាំងអាជីវកម្ម ឬឯកសារសមមូល (ច្បាប់ថតចម្លង) ចំនួន១ច្បាប់ រូបថត (៤x៦) ចំនួន៣ សន្លឹក។
លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម មានសុពលភាពរយៈពេល១(មួយ)ឆ្នាំ។ គ្រប់អាជីវករ សេវាករ ពាណិជ្ជករ ដែលស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ឬស្នើសុំបន្តត្រូវមានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈជូនរដ្ឋចំនួន២៥ ០០០ (ពីរម៉ឺនប្រាំពាន់) រៀល។

ដូច្នេះ ប្រសិនបើអាជីវកម្មភោជនីយដ្ឋានរបស់លោកអ្នកមានផលរបរដល់កម្រិតជាអ្នកជាប់ពន្ធដូចមានកំណត់ក្នុងប្រកាសលេខ០០៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នោះលោកអ្នកចាំបាច់ត្រូវចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន។
ការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា តម្រូវឱ្យដាក់ជូនឯកសារ ដូចខាងក្រោម៖

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងដែលមានព័ត៌មានចំណុចនិយាមការទីតាំងទីស្នាក់ការ ឬទីចាត់ការសហគ្រាស
- រូបថតបច្ចុប្បន្នរបស់ម្ចាស់សហគ្រាសមិនលើសពីរយៈពេល ០៣ ខែ ដែលមានទំហំ3x4mm និងមានផ្ទៃខាងក្រោយពណ៌សរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង
- ឯកសារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនដែលមានសុពលភាពរបស់កម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង
- ឯកសារយោង(អាចជាលិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍ របស់ក្រុមហ៊ុនចាស់ អាជ្ញាបណ្ណផ្សេងៗចេញដោយក្រសួង-ស្ថាប័នជំនាញ និងឯកសារពាក់ព័ន្ធផ្សេងទៀត)
- លិខិតប្រគល់សិទ្ធិករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ
- លិខិតបញ្ជាក់អំពីព័ត៌មានគណនីធនាគាររបស់សហគ្រាសដែលចេញដោយធនាគារ (លិខិតបញ្ជាក់គណនីធនាគារ ឬរបាយការណ៍ធនាគារ ឬសៀវភៅធនាគារ) ដែលត្រូវផ្តល់ក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះ ការផ្តល់ការចុះបញ្ជីពន្ធដារត្រូវបានដកហូតដោយស្វ័យប្រវត្តិ។)

# ២ ក្រុមហ៊ុនមូលធន

**ក្រុមហ៊ុនមូលធនមានពីរទ្រង់ទ្រាយ គឺក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។**

ប្រសិនបើអ្នកចង់បង្កើតក្រុមហ៊ុនមួយ ដោយមានអ្នកចូលរួមដើមទុនចាប់ពី២នាក់ឡើងទៅ អ្នកអាចជ្រើសរើសចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។ ម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវបានគេស្គាល់ថាជាភាគហ៊ុននិក។

→ **ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត**

- អាចមានសមាជិកភាគហ៊ុនចាប់ពី ២(ពីរ)នាក់ រហូតដល់ ៣០(សាមសិប)នាក់។
- មិនអាចលក់ភាគហ៊ុន ឬមូលប័ត្រជាសាធារណៈបានឡើយ និងមានការរឹតត្បិតមួយ ឬច្រើនទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់
- ម្ចាស់ភាគហ៊ុនទទួលខុសត្រូវត្រឹមចំនួនភាគហ៊ុនដែលខ្លួនបានទិញ
- ត្រូវដាក់បញ្ចូលនូវពាក្យថា "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឬសរសេរអក្សរកាត់ (ឯ.ក) ដាក់ខាងចុង ឬខាងក្រោមឈ្មោះក្រុមហ៊ុន។

→ **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**

- អាចមានសមាជិកហ៊ុនយ៉ាងតិចចាប់ពី ២ រូបឡើងទៅ និងតម្រូវឲ្យមានអភិបាល យ៉ាងតិច៣រូប ឡើងទៅ។
- អាចបង្កើតឡើងក្នុងគោលដៅអាជីវកម្ម ក្នុងទម្រង់ដូចជា៖ ធនាគារ ធានារ៉ាប់រង និងក្រុមហ៊ុនឥណទាន លក់មូលបត្រ ឬគោលដៅអាជីវកម្មផ្សេងទៀត ដែលច្បាប់អនុញ្ញាត។
- អាចបោះចេញនូវមូលបត្រដែល អាចដាក់លក់ជាសាធារណៈបាន។
- ត្រូវដាក់បញ្ចូលនូវពាក្យថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" ឬសរសេរអក្សរកាត់ (ម.ក) ដាក់ខាងចុង ឬខាងក្រោមឈ្មោះក្រុមហ៊ុន

**ការចុះបញ្ជីពាណិជ្ជកម្មត្រូវការឯកសារដូចខាងក្រោម៖**

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ ខែ និងមានផ្ទៃខាងក្រោយពណ៌ ស របស់អភិបាល ម្ចាស់ភាគហ៊ុន (ករណីម្ចាស់ហ៊ុនជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីម្ចាស់ហ៊ុនជានីតិបុគ្គល)
- ឯកសារអត្តសញ្ញាណប័ណ្ណរបស់អភិបាល ម្ចាស់ហ៊ុន (ករណីម្ចាស់ហ៊ុនជារូបវន្តបុគ្គល) និង/ឬ អ្នកតំណាង (ករណីម្ចាស់ហ៊ុនជានីតិបុគ្គល)
- លក្ខន្តិកៈក្រុមហ៊ុន
- ឯកសារយោង (អាចជាលិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់ អាជ្ញាបណ្ណផ្សេងៗចេញដោយក្រសួង-ស្ថាប័នជំនាញ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត)
- ករណីម្ចាស់ហ៊ុនជានីតិបុគ្គល
  - លិខិតប្រគល់សិទ្ធិពីក្រុមហ៊ុនមេ
  - វិញ្ញាបនបត្រក្រុមហ៊ុនមេ
  - លក្ខន្តិកៈក្រុមហ៊ុនមេ
- លិខិតប្រគល់សិទ្ធិ ករណីអ្នកតំណាងជាអ្នកបំពេញពាក្យស្នើសុំ

**ការចុះបញ្ជីពន្ធដារត្រូវការឯកសារដូចខាងក្រោម៖**

- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យរបស់សហគ្រាស
- ព័ត៌មានអំពីគណនីធនាគារ(ត្រូវផ្តល់ក្នុងរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល។ក្នុងករណីខកខានមិនបានផ្តល់ព័ត៌មាននេះ ការផ្តល់ការចុះបញ្ជីពន្ធដារ ត្រូវបានដកហូតដោយស្វ័យប្រវត្តិ។)




ធុរជនដែលបានចុះបញ្ជីអាជីវកម្មបានសម្រេច មានកាតព្វកិច្ចបង្កើតគណនីធនាគារក្រុមហ៊ុនសម្រាប់ធ្វើប្រតិបត្តិការចំណូលចំណាយ និងស្នើសុំអាជ្ញាបណ្ណជំនាញសម្រាប់អាជីវកម្មពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ដើម្បីឱ្យធុរជនរៀបចំឱ្យបានត្រឹមត្រូវ អ្នកត្រូវមានគណនីធនាគាររបស់ក្រុមហ៊ុន។ ម្ចាស់អាជីវកម្ម មានកាតព្វកិច្ចបញ្ចូលព័ត៌មានគណនីក្រុមហ៊ុនចូលក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការអនុម័តពីអគ្គនាយកដ្ឋានពន្ធដារ។

ដំណាក់កាលទី ២ នៃការចុះបញ្ជីអាជីវកម្ម គឺជាដំណាក់កាល ដែលត្រូវស្នើសុំអាជ្ញាបណ្ណឯកទេសពីក្រសួងពាក់ព័ន្ធ ដោយផ្អែកលើសកម្មភាពអាជីវកម្មរបស់លោកអ្នក។ ការសុំអាជ្ញាបណ្ណនេះទាមទារឲ្យធុរជនប្រកបអាជីវកម្មស្របតាមស្តង់ដាររបស់រាជរដ្ឋាភិបាល។ សូមអានការណែនាំខាងក្រោមជាបន្តបន្ទាប់ពាក់ព័ន្ធនឹងការស្នើសុំអាជ្ញាបណ្ណជំនាញពីក្រសួងនីមួយៗ។

# អនុលោមភាពជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ




# ជំពូកទី ៣



១ ដំណើរការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន CAMDX

២ អនុលោមភាពជាមួយក្រសួងពាណិជ្ជកម្ម



៣ អនុលោមភាពសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក




៤ អនុលោមភាពពន្ធជាមួយអគ្គនាយកដ្ឋានពន្ធដារ

៥ អនុលោមភាពជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**អនុលោមភាព ជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ**

៦ អនុលោមភាពជាមួយក្រសួងសុខាភិបាល

៧ អនុលោមភាពជាមួយក្រសួងទេសចរណ៍



៨ អនុលោមភាពជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៩ អនុលោមភាពជាមួយក្រសួងមហាផ្ទៃ



១០ អនុលោមភាពជាមួយក្រសួងបរិស្ថាន



១១ អនុលោមភាពជាមួយស្ថាប័នថ្នាក់ក្រោមជាតិ

១២ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

# ១ ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

registrationservices.gov.kh គឺជាថ្នាលបច្ចេកវិទ្យាព័ត៌មានសម្រាប់ការចុះបញ្ជីអាជីវកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការលើកដំបូងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ក្នុងគោលបំណងធ្វើឱ្យការចុះបញ្ជីអាជីវកម្មកាន់តែមានភាពងាយស្រួល ចំណេញពេលវេលា និងថវិកា។ សម្រាប់ការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាននេះ អ្នកអាចចុះបញ្ជីអាជីវកម្ម ចុះបញ្ជីពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ក្នុងពេលតែមួយបាននៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតែមួយ។ លោកអ្នកត្រូវមានគណនី CamDigiKey ដើម្បីចូលទៅកាន់ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន។ សូមអានសៀវភៅមគ្គុទ្ទេសក៍ដែលមាននៅលើគេហទំព័រ registrationservices.gov.kh ដើម្បីស្វែងយល់ពីជំហ៊ាននៃការបង្កើតគណនី។




តាមរយៈដំណើរការចុះបញ្ជីថ្មីនេះ ការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលយ៉ាងយូរបំផុតត្រឹមតែរយៈពេល ៨ថ្ងៃនៃថ្ងៃធ្វើការ អ្នកនឹងទទួលបានវិញ្ញាបនបត្រចុះបញ្ជីឌីជីថល។
អ្នកក៏អាចទូទាត់បង់ថ្លៃសេវាក្នុងការចុះបញ្ជីអាជីវកម្មទាំងអស់តាមអនឡាញដោយប្រើប្រាស់សេវាABA Pay សម្រាប់អតិថិជនធនាគារវឌ្ឍនៈអាស៊ីចំកាត់(ABA) និងតាមប្រព័ន្ធធនាគារដទៃទៀតដែលមានកិច្ចព្រមព្រៀងជាដៃគូ។
ក្រោយការចុះបញ្ជីអាជីវកម្មជោគជ័យ អ្នកនឹងទទួលបានអាជ្ញាបណ្ណនិងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថលតាមរយៈប្រព័ន្ធថ្នាលបច្ចេកវិទ្យាព័ត៌មានដូចខាងក្រោម៖
១. វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មចេញដោយក្រសួងពាណិជ្ជកម្ម
២. វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ(អាករលើតម្លៃបន្ថែម-អតប) ប័ណ្ណពន្ធប៉ាតង់ ប័ណ្ណសម្គាល់ចុះបញ្ជីពន្ធដារ និង លិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ
៣. សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មាន ២ ដំណាក់កាល៖**

- **ដំណាក់កាលទី១** គឺជានីតិវិធីនៃការចុះបញ្ជីអាជីវកម្ម ជាមួយក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- **ដំណាក់កាលទី ២** គឺផ្តោតសំខាន់ទៅលើការស្នើសុំអាជ្ញាបណ្ណជំនាញសម្រាប់អាជីវកម្ម។

**អាជ្ញាបណ្ណជំនាញ** សំដៅលើអាជ្ញាបណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាត ឬប្រកាសដែលត្រូវស្នើសុំផ្អែកលើសកម្មភាពអាជីវកម្មរបស់ អាជីវកម្មនីមួយៗ ក្រោយពេលការចុះបញ្ជីអាជីវកម្មជាមួយក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរួចរាល់។

**ឧទាហរណ៍៖**
ប្រសិនបើលោកអ្នកបើកសណ្ឋាគារ និងមានផ្តល់សេវាកម្មភោជនីយដ្ឋានក្នុងសណ្ឋាគារនោះលោកអ្នកនឹងតម្រូវឱ្យស្នើសុំអាជ្ញាបណ្ណជំនាញសម្រាប់សណ្ឋាគារ និងអាជ្ញាបណ្ណជំនាញសម្រាប់ភោជនីយដ្ឋាន ពីក្រសួងទេសចរណ៍។
នៅពេលលោកអ្នកចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសបានជោគជ័យ លោកអ្នកនឹងទទួលបានអ៊ីម៉ែលបញ្ជាក់ពីអាជ្ញាបណ្ណជំនាញដែលអាជីវកម្មលោកអ្នកត្រូវស្នើសុំបន្ទាប់។ លោកអ្នកអាចចូលមើលសៀវភៅមគ្គុទេសក៍ដែលមាននៅលើគេហទំព័រ registrationservices.gov.kh.

1

ទាញយកកម្មវិធី CamDigiKey ពី App Store ឬ PlayStore លើទូរស័ព្ទដៃរបស់អ្នក។
បន្ទាប់ពីទាញយកបានជោគជ័យ សូមចូលទៅកាន់កម្មវិធី CamDigiKey រួចចុចប៊ូតុង “ចុះឈ្មោះ”រួច បំពេញព័ត៌មានផ្ទាល់ខ្លួនតាមការតម្រូវរបស់ប្រព័ន្ធ។




2

សូមចូលទៅតំណភ្ជាប់នេះ
https://www.registrationservices.gov.kh/
រួចជ្រើសរើសយក “ចុះបញ្ជីអាជីវកម្ម”




3

ចុចប៊ូតុង “ទាញយក QR Code” ហើយស្កេន QR Code ដែលអ្នកឃើញជាមួយនឹងកម្មវិធី CamDigiKey នៅលើទូរស័ព្ទដៃរបស់អ្នក សូមបញ្ចូលលេខកូដផ្ទាល់ខ្លួនចំនួន ៦ខ្ទង់ដែលអ្នកបានបង្កើតក្នុង CamDigiKey App ទៅក្នុង CamDigiKey App នោះ អ្នកនឹងអាចចូលទៅកាន់ទំព័រ Portal ចុះបញ្ជីអាជីវកម្មក្នុងកុំព្យូទ័របានដោយស្វ័យប្រវត្តិ។

4

ជ្រើសរើសទម្រង់សហគ្រាសដែលសមស្របទៅនឹងសហគ្រាសរបស់អ្នក រួចបំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ “ចុះបញ្ជីពាណិជ្ជកម្ម” រួចចុច “បន្ទាប់”

5

**ការទូទាត់បង់ប្រាក់**
ជម្រើសនៃការទូទាត់ប្រាក់មានដូចជា ABA Pay និងតាមប្រព័ន្ធធនាគារដទៃទៀតដែលមានកិច្ចព្រមព្រៀងជាដៃគូ។

# ២ អនុលោមតាមជាមួយក្រសួងពាណិជ្ជកម្ម

## ២.១ ការបម្រុងទុកនាមករណ៍សហគ្រាសអាចធ្វើបាននៅលើប្រព័ន្ធថ្នាលបច្ចេកវិទ្យាព័ត៌មាន (តែមិនមែនជាកាតព្វកិច្ចនោះទេ)

ម្ចាស់អាជីវកម្ម អាចបម្រុងទុកនាមករណ៍សហគ្រាស មុនពេលចុះបញ្ជីអាជីវកម្មថ្មី ឬមុនពេលផ្លាស់ប្តូរនាមករណ៍អាជីវកម្ម។ អ្នកអាចចាប់ផ្តើមដោយជ្រើសរើសទម្រង់សហគ្រាស ហើយចាប់ផ្តើមបម្រុងទុកនាមករណ៍។ ក្នុងទំព័របម្រុងទុកនាមករណ៍ អ្នកត្រូវបំពេញនាមករណ៍បម្រុងទុកជាភាសាខ្មែរ និងភាសាអង់គ្លេស និងប្រភេទក្រុមហ៊ុន/អង្គភាព (លោកអ្នកត្រូវបង់ថ្លៃសេវាបម្រុងទុកនាមករណ៍)។ ក្នុងករណីចង់បម្រុងទុកនាមករណ៍ស្រដៀងគ្នាទៅនឹងនាមករណ៍របស់ក្រុមហ៊ុន ដែលបានចុះបញ្ជីរួចហើយ អ្នកត្រូវភ្ជាប់លិខិតអនុញ្ញាតប្រើប្រាស់នាមករណ៍របស់ក្រុមហ៊ុនចាស់។

បុគ្គលស្នើសុំចុះបញ្ជីក្រុមហ៊ុន មានបំណងចង់បម្រុងទុកនាមករណ៍ជាមុន យោងតាមសេចក្តីជូនដំណឹងលេខ២៩៩៣ ចុះថ្ងៃទី០១ ខែតុលា បុគ្គលម្នាក់អាចស្នើសុំបម្រុងទុកនាមករណ៍បានតែចំនួន០៣នាមករណ៍ប៉ុណ្ណោះ ដែលនាមករណ៍នីមួយៗមានសុពលភាពត្រឹមតែ ២សប្តាហ៍ប៉ុណ្ណោះ។

ករណីដែលនាមករណ៍ណាមួយហួសសុពលភាព បុគ្គលអាចធ្វើការស្នើសុំបម្រុងទុកនាមករណ៍ដដែលនោះបន្តសារឡើងវិញយ៉ាងតិចបំផុតឲ្យបាន០១ថ្ងៃមុនកាលបរិច្ឆេទហួសសុពលភាព។ ការស្នើសុំបម្រុងទុកនាមករណ៍បន្តនេះ អាចធ្វើបានតែម្តងប៉ុណ្ណោះ។

ការស្នើសុំបម្រុងទុកនាមករណ៍ គឺត្រូវបង់សេវាសាធារណៈចំនួន ២៥.០០០ (ពីរម៉ឺនប្រាំពាន់)រៀល។ នាមករណ៍ នឹងត្រូវបានបម្រុងទុកសម្រាប់ការចុះបញ្ជីសហគ្រាស ហើយគ្មានក្រុមហ៊ុនណាផ្សេងទៀត អាចប្រើនាមករណ៍ដែលអ្នកបានស្នើសុំបម្រុងទុកនោះទេ។

## ២.២ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ

យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងប្រកាសលេខ១០៧ ព.ណ ចបព.ប្រក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម បានកំណត់ថាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មរួច ត្រូវមានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំជារៀងរាល់ឆ្នាំ។ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ គឺជាការពិនិត្យ និងផ្ទៀងផ្ទាត់ក៏ដូចជាធ្វើបច្ចុប្បន្នភាពព័ត៌មានចុះបញ្ជីពាណិជ្ជកម្ម និងឯកសារផ្សេងៗរបស់ក្រុមហ៊ុនដែលមាននៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្មតាមរយៈគេហទំព័រ www.businessregistration.moc.gov.kh។

ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ តម្រូវឱ្យបង់កម្រៃសេវាសាធារណៈចំនួន ៨០.០០០ (ប្រាំបីម៉ឺន)រៀល។ កាលបរិច្ឆេទ អំពីកាតព្វកិច្ចត្រូវតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ នឹងត្រូវបានជូនដំណឹងតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ទៅកាន់អ៊ីម៉ែលរបស់ក្រុមហ៊ុនដែលបានផ្តល់មកក្រសួងពាណិជ្ជកម្ម ក្នុងពេលចុះបញ្ជី។ ជាទូទៅ ក្រុមហ៊ុនត្រូវតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ក្នុងរយៈពេល ៣(បី)ខែបន្ទាប់ពីចុះបញ្ជីពាណិជ្ជកម្ម។

ហើយក្នុងករណីក្រុមហ៊ុនមានបញ្ហាណាមួយដែលមិនអាចធ្វើការតម្កល់ប្រតិវេទន៍តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មបានទេ ក្រុមហ៊ុនក៏អាចធ្វើការស្នើសុំតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំដោយផ្ទាល់ទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដោយត្រូវធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុដែលមិនអាចតម្កល់ប្រតិវេទន៍តាមប្រព័ន្ធស្វ័យប្រវត្តិកម្មបាន ប៉ុន្តែត្រូវឆ្លងកាត់ការពិនិត្យ និងទទួលការយល់ព្រមពីមន្ត្រីក្រសួងពាណិជ្ជកម្ម ផ្ទុយទៅវិញ ប្រសិនបើក្រុមហ៊ុនណាមួយខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមកាលកំណត់ទេក្រុមហ៊ុននោះ នឹងត្រូវទទួលពិន័យជាប្រាក់ ចំនួន២.០០០.០០០(ពីរលាន)រៀល ដូចមានកំណត់នៅក្នុងប្រកាសអន្តរក្រសួងលេខ៣១៦ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្មស្តីពីការពិន័យជាប្រាក់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មចុះថ្ងៃទី ១២ ឧសភា ២០២១។

## ២.៣ ការចុះបញ្ជីកែប្រែ ផ្លាស់ប្តូរព័ត៌មានរបស់ក្រុមហ៊ុន

យោងតាមប្រកាសលេខ១៤២ ពណ.ចបព.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីបែបបទ និងនីតិវិធីចុះក្នុងបញ្ជីពាណិជ្ជកម្ម នូវរាល់ការផ្លាស់ប្តូរ និងកែប្រែ របស់សហគ្រាស-ក្រុមហ៊ុន ពាណិជ្ជករ ស្ថាបនិក ឬអភិបាលម្នាក់ៗ ត្រូវតែជាអ្នកចុះហត្ថលេខាលើពាក្យស្នើសុំ ចុះក្នុងបញ្ជីពាណិជ្ជកម្មនូវការកែប្រែក្រោយចុះបញ្ជី និងផ្តល់ឯកសារតម្រូវសម្រាប់តម្កល់ទៅឲ្យនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នូវការកែប្រែដូចខាងក្រោម៖

- ការកែប្រែ ផ្លាស់ប្តូរភាគហ៊ុន ការបន្ថយដើមទុន ការបង្កើនដើមទុន
- ការកែប្រែផ្សេងៗ (នាមករណ៍ ព័ត៌មានក្នុងលក្ខន្តិកៈ ទីស្នាក់ការ ការផ្ទេរ ឬការលក់ភាគហ៊ុន អភិបាល ការស្នើសុំបន្ថែមកម្មវត្ថុអាជីវកម្ម ។ល។)

## ប្រកាសអន្តរក្រសួងលេខ ៣១៥ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១

| តម្លៃសេវាសាធារណៈសម្រាប់ក្រុមហ៊ុនមូលធន | តម្លៃ (គិតជាលុយរៀល) |
|---|---|
| ការបម្រុងទុកនាមករណ៍ក្រុមហ៊ុន | ២៥.០០០ |
| ការចុះបញ្ជីពាណិជ្ជកម្ម | ក្រុមហ៊ុនពាណិជ្ជកម្ម ១.០១០.០០០ |
| | សហគ្រាសឯកបុគ្គល ១៨០.០០០ |
| ការតម្កល់ប្រតិវេទ៍ប្រចាំឆ្នាំ | ៨០.០០០ |
| ការកែប្រែ ផ្លាស់ប្តូរ បច្ចុប្បន្នភាព ភាគហ៊ុន ដើមទុន | ៨០០.០០០ |
| ការកែប្រែ ទីស្នាក់ការ អភិបាល កម្មវត្ថុអាជីវកម្ម នាមករណ៍ក្រុមហ៊ុន និង តម្កល់ទុកលក្ខន្តិកៈ | ២៤០.០០០ |
| ការចុះបញ្ជីសាខាក្រុមហ៊ុនក្នុងស្រុក | ៤៨០.០០០ |

### ការពិន័យអន្តរការណ៍

- ការខកខានមិនបានចុះបញ្ជីកែប្រែ ផ្លាស់ប្តូរព័ត៌មានរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម នឹងត្រូវរងការផាកពិន័យជាប្រាក់ចំនួន ១,០០០,០០០ (មួយលាន)រៀល
- ការខកខានមិនបានតម្កល់ប្រតិវេទន៍ នឹងត្រូវរងការផាកពិន័យជាប្រាក់ចំនួន ២,០០០,០០០ (ពីរលាន) រៀល
- ការក្លែងបន្លំឯកសារ ឬប្រគល់ឯកសារមិនត្រឹមត្រូវជូនមន្ត្រីចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម នឹងត្រូវរងការផាកពិន័យជាប្រាក់ចំនួន ១,០០០,០០០ (មួយលាន) រៀល។

### ២.៤ ការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទជាប្រាក់រៀល

យោងតាមសេចក្តីជូនដំណឹងលេខ១០២០ ព.ណ.អវ.ឯ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ស្តីពីការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទ ពាណិជ្ជករ អាជីវករ សេវាករទាំងអស់ ដែលកំពុងធ្វើសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្ម ត្រូវតែបិទស្លាកថ្លៃលើគ្រប់មុខទំនិញ និងសេវាដែលតាំងលក់ក្នុងហាង ឬអគារលក់ទំនិញរបស់ខ្លួនជាប្រាក់រៀល។

ចំពោះអាជីវកម្មដែលត្រូវការបិទស្លាកថ្លៃលើគ្រប់មុខទំនិញ និងសេវាកម្មជារូបិយបណ្ណបរទេស ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតពីអង្គភាពប្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

លិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយបណ្ណបរទេស មានសុពលភាពរយៈពេល០១ ឆ្នាំ។

### ២.៥ ការចុះបញ្ជីម៉ាក នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម

យោងតាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ម៉ាក គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។ ម៉ាកដែលប្រើប្រាស់សម្រាប់ទំនិញហៅថាពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់សម្រាប់សេវាហៅថាសេវាសញ្ញា។

ពាណិជ្ជនាម គឺជាឈ្មោះឬសញ្ញាសំគាល់ ឬជាឈ្មោះនិងសញ្ញាសម្គាល់សម្រាប់បញ្ជាក់និងសម្គាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ។

ម្ចាស់អាជីវកម្ម អាចស្នើសុំចុះឈ្មោះម៉ាករបស់ខ្លួននៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម។

សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់ តាមរយៈការចុះបញ្ជីដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

ម៉ាកដែលបានចុះបញ្ជីហើយ មានសុពលភាព១០ (ដប់) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជី។

តាមការស្នើសុំការចុះបញ្ជីម៉ាកមួយ អាចធ្វើសាជាថ្មីសម្រាប់រយៈពេល១០ (ដប់) ឆ្នាំម្តងជាបន្តបន្ទាប់ក្នុងលក្ខខណ្ឌដែលម្ចាស់ម៉ាកបានបង់ថ្លៃសេវាស្នើសុំបន្តសុពលភាពចុះបញ្ជីម៉ាកតាមការកំណត់។

ចំពោះម៉ាកដែលទាក់ទងនឹងទំនិញឬសេវាដែលបានចុះបញ្ជីរួចហើយ ការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើមត្រូវមានការយល់ព្រមពីម្ចាស់ម៉ាកដើមជាមុនសិន។

សិទ្ធិជាម្ចាស់ម៉ាក ដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកមានដូចខាងក្រោម៖

ក- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញឬសេវាដែលបានចុះបញ្ជីរួចហើយ ការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើមត្រូវមានការយល់ព្រមពីម្ចាស់ម៉ាកដើមជាមុនសិន។

ខ- ម្ចាស់ដើមនៃម៉ាក មានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ ដែលប្រើប្រាស់ដោយរំលោភម៉ាករបស់ខ្លួនដោយគ្មានការយល់ព្រមពីម្ចាស់ដើម។ ម្ចាស់ដើមក៏មានសិទ្ធិប្តឹងផងដែរ ចំពោះការប្រើប្រាស់សញ្ញាដែលប្រហាក់ប្រហែលនឹងម៉ាកដែលខ្លួនបានចុះបញ្ជីរួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវាដែលប្រហាក់ប្រហែលទៅនឹងទំនិញឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយ ដែលអាចបណ្តាលឱ្យមានការភ័ន្តច្រឡំជាសាធារណៈ។

# ៣ អនុលោមតាពសម្រាប់ការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក

- ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/RKM/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
- អនុក្រឹត្យលេខ១១០ អនក្រ.បក ស្តីពីការផ្តល់លិខិតអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧
- អនុក្រឹត្យលេខ១៣៤ អនក្រ.បក ស្តីពីការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត អាជ្ញាបណ្ណ ដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០
- ប្រកាសលេខ២៩០ ពណ.ចបព ប្រក របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០

រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខារបស់ក្រុមហ៊ុនបរទេស ដែលធ្វើប្រតិបត្តិការ និងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែមានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ដើម្បីអាចដាក់ពាក្យសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីក្រសួងពាណិជ្ជកម្មបាន នីតិបុគ្គល និងរូបវន្តបុគ្គលត្រូវមានវិញ្ញាបនបត្រសេវាអនឡាញ និងត្រូវមានលិខិតអនុញ្ញាតប្រើប្រាស់ឈ្មោះដែនជាតិ(.KH)ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ជំហ៊ានទី១៖**

**៣.១ ការស្នើសុំវិញ្ញាបនបត្រសេវាអនឡាញ ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈ** service.mptc.gov.kh.

- អនុក្រឹត្យលេខ១១០ អនក្រ.បក ស្តីពីការផ្តល់លិខិតអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧

រូបវន្តបុគ្គល និងនីតិបុគ្គលដែលមានបំណងធ្វើប្រតិបត្តិការលើវិស័យអនឡាញ ត្រូវស្នើសុំទៅអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានទៅតាមទម្រង់បែបបទ និងលក្ខខណ្ឌដែលកំណត់ដោយ ក.ប.ទ ព្រមទាំងភ្ជាប់នូវឯកសារដូចខាងក្រោម៖

- ពាក្យស្នើសុំវិញ្ញាបនបត្រ ដែលកំណត់ដោយ ក.ប.ទ
- ឯកសារថតចម្លងដែលមានការបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើមពីអាជ្ញាធរមានសមត្ថកិច្ច និងមានបោះត្រាក្រុមហ៊ុនដូចជា៖
  - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
  - ប័ណ្ណពន្ធប៉ាតង់ឆ្នាំចុងក្រោយ
  - វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
  - លក្ខន្តិកៈក្រុមហ៊ុន និង
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

វិញ្ញាបនបត្រសេវាអនឡាញមានសុពលភាពរយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។

***សូមមើលអំពីនីតិវិធីនៃការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រសេវាអនឡាញ ដែលមានរៀបរាប់លម្អិតក្នុងចំណុចអនុលោមភាពជាមួយក្រសួងប្រៃសណីយ៍ និងគមនាគមន៍។

**ជំហ៊ានទី២៖**

**៣.២ ការស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ឈ្មោះដែនជាតិពីនិយ័តករទូរគមនាគមន៍កម្ពុជា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

- អនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត
- សេចក្តីជូនដំណឹងលេខ ០៨៣៧ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ស្តីពីការតម្រូវឱ្យប្រើប្រាស់ឈ្មោះដែនជាតិ .com.kh និងការផ្តល់អាសយដ្ឋានអេឡិចត្រូនិកឈ្មោះដែនជាតិ នៅពេលប្រកាសប្រតិវេទន៍ប្រចាំឆ្នាំ
- សេចក្តីណែនាំលេខ១៥៦៨ ស្តីពីការស្នើសុំលិខិតអនុញ្ញាតចុះឈ្មោះគេហទំព័រ .KH ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨

ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម ហើយពុំទាន់បានប្រើប្រាស់អាសយដ្ឋានអេឡិចត្រូនិកដែលមានឈ្មោះដែនជាតិកម្រិតទី២ ប្រភេទ .com.kh នៅឡើយ ត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់ឈ្មោះដែនជាតិនៅនិយ័តករទូរគមនាគមន៍កម្ពុជា។ លិខិតអនុញ្ញាតប្រើប្រាស់ឈ្មោះដែនជាតិ.com.kh មានសុពលភាពយ៉ាងតិចរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជីនឹងអាចបន្តសុពលភាពសម្រាប់ឆ្នាំបន្តបន្ទាប់ក្នុងលក្ខខណ្ឌដែលម្ចាស់ឈ្មោះដែនជាតិបង់កម្រៃសេវាប្រចាំឆ្នាំចំនួន ១២០.០០០ (ដប់ពីរម៉ឺន) រៀល ក្នុងមួយឆ្នាំ។

**ជំហ៊ានទី៣៖**

**៣.៣ ការស្នើសុំលិខិតអនុញ្ញាត/អាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពីក្រសួងពាណិជ្ជកម្ម**

- អនុក្រឹត្យលេខ១៣៤ អនក្រ.បក ស្តីពីការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត អាជ្ញាបណ្ណ ដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០
- ប្រកាសលេខ២៩០ ពណ.ចបព ប្រក របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០

ម្ចាស់អាជីវកម្មដែលប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមទ្រង់ទ្រាយអាជីវកម្មដូចខាងក្រោម៖

| ទ្រង់ទ្រាយអាជីវកម្ម | ប្រភេទនៃអាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ឯកសារតម្រូវ |
|---|---|---|
| នីតិបុគ្គលដែលប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមតំណរភ្ជាប់ ecommercelicensing.moc.gov.kh<br><br>អាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានសុពលភាពរយៈពេល២ឆ្នាំ | • លក្ខន្តិកៈក្រុមហ៊ុន ដែលមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• វិញ្ញាបនបត្រសេវាអនទ្បាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>• បណ្ណពន្ធប៉ាតង់ (សម្រាប់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក)<br>• ឯកសារអំពីមធ្យោបាយទូទាត់ប្រាក់ផ្តល់ដោយបុគ្គលសេវាទូទាត់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា<br>• ឯកសារគំរូអាជីវកម្ម និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់សម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |
| រូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គល ដែលប្រតិបត្តិការអាជីវកម្ម ឬប្រើប្រាស់មធ្យោបាយអេឡិចត្រូនិក ដើម្បីផ្គត់ផ្គង់ទំនិញ និង/ឬសេវា | ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមតំណរភ្ជាប់ ecommercelicensing.moc.gov.kh<br>លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានសុពលភាពរយៈពេល២ឆ្នាំ | • វិញ្ញាបនបត្រសេវាអនទ្បាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>• បណ្ណពន្ធប៉ាតង់ (សម្រាប់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក)<br>• ឯកសារអំពីមធ្យោបាយទូទាត់ប្រាក់ផ្តល់ដោយបុគ្គលសេវាទូទាត់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា<br>• ឯកសារគំរូអាជីវកម្ម និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់សម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក |

## ៣.៤ ពិន័យអន្តរការណ៍

រូបវន្តបុគ្គលដែលមានផលរបរស្ថិតក្នុងកម្រិតផលរបរជាអ្នកជាប់ពន្ធតូច នីតិបុគ្គល សាខាក្រុមហ៊ុនបរទេស និងសហគ្រាសឯកបុគ្គល ដែលបានធ្វើប្រតិបត្តិការអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយមិនបានដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីក្រសួងពាណិជ្ជកម្ម ត្រូវទទួលរងប្រាក់ពិន័យចំនួន១០,០០០,០០០ (ដប់លាន) រៀល។

**ករណីលើកលែង**

អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្តីពីការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង

សកម្មភាពឬប្រតិបត្តិការដូចខាងក្រោមត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖

- ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីទំនិញឬ សេវារបស់ខ្លួន រួមបញ្ចូលទាំងការផ្សព្វផ្សាយលក់ទំនិញ ឬសេវាដែលមិនមែនជាសេវាបង្កើតកិច្ចសន្យា
- ការបម្រុងទុកសេវាដែលមិនមានការកក់ប្រាក់ ឬ ទូទាត់កម្រៃដោយអតិថិជន ឬអ្នកប្រើប្រាស់
- ការលក់ទំនិញ ឬសេវារបស់រូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គលដែលមានផលរបរនៅក្រោមកម្រិតផលរបរជាអ្នកជាប់ពន្ធតូច
- ការលក់ទំនិញ ឬសេវាដែលមានលក្ខណៈគ្រួសារ ឬតាមរដូវកាលប្រមូលផល
- ការលក់ទំនិញ ឬសេវាដែលជាស្នាដៃសិល្បៈផ្ទាល់ខ្លួនសុទ្ធសាធ
- ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន
- ការបង្ហាត់បង្រៀន ឬអប់រំអំពីសាសនារបស់រដ្ឋ
- ការបង្ហាត់បង្រៀនដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមិនរកប្រាក់ចំណេញដោយផ្ទាល់ ឬប្រយោល និងសកម្មភាព ឬប្រតិបត្តិការដោយស្ថាប័នរដ្ឋក្នុងការផ្តល់សេវាសាធារណៈ ក៏ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតផងដែរ។

| តម្លៃសេវាសាធារណៈសម្រាប់ការស្នើសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>ប្រកាសអន្តរក្រសួងលេខ ៤៩៨ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ | |
|---|---|
| **ប្រភេទអាជ្ញាបណ្ណ** | **តម្លៃគិតជាប្រាក់រៀល** |
| វិញ្ញាបនបត្រសេវាអនឡាញ ចេញដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១ ០០០ ០០០ |
| **ប្រកាសអន្តរក្រសួងលេខ ៤៩៩ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈដោយនិយ័តករទូរគមនាគមន៍កម្ពុជា ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨** | |
| វិញ្ញាបនបត្រ ប្រើប្រាស់ឈ្មោះដែនជាតិចេញដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | (តម្លៃសេវាចុះបញ្ជី ៤០ ០០០)+ ១២០ ០០០ និងថ្លៃអាករលើតម្លៃបន្ថែម១០% (១២.០០០) (តម្លៃសេវាស្នើសុំបន្តសុពលភាពរៀងរាល់១ឆ្នាំម្តង) |
| **ប្រកាសអន្តរក្រសួងលេខ ៣១៥ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១** | |
| លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីក្រសួងពាណិជ្ជកម្ម | តម្លៃ ២០០.០០០ សម្រាប់រូបវន្តបុគ្គលតម្លៃ ៤០០.០០០ សម្រាប់សហគ្រាសឯកបុគ្គល |
| អាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីក្រសួងពាណិជ្ជកម្ម | ១.០០០.០០០ សម្រាប់ក្រុមហ៊ុនមូលធន |

# ៤ អនុលោមតាពជាមួយអគ្គនាយកដ្ឋានពន្ធដារ

## ៤.១ ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មាន

- ប្រកាសលេខ៧០១សហវ ប្រក ចុះថ្ងៃទី១៤ សីហា ២០២០ ស្តីពី ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

ការចុះបញ្ជីពន្ធដារសំដៅដល់ការចុះបញ្ជីរបស់អ្នកជាប់ពន្ធទាំងឡាយដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកការចុះបញ្ជីពន្ធដារត្រូវធ្វើឡើងដោយស្វ័យប្រវត្តិតាមរយៈប្រព័ន្ធថ្នាលបច្ចេកវិទ្យាព័ត៌មាន www.registrationservices.gov.kh។

បុគ្គលដែលបានបំពេញតាមលក្ខខណ្ឌតម្រូវ នៃប្រព័ន្ធថ្នាលបច្ចេកវិទ្យាព័ត៌មាននឹងទទួលបានឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារ ជាទម្រង់ឌីជីថលដែលអាចបោះពុម្ពបានតាមរយៈគេហទំព័រចុះបញ្ជីនេះ។

អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ មានកាតព្វកិច្ចជូនដំណឹងមករដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ថ្ងៃនៃថ្ងៃធ្វើការក្នុងករណីដែលព័ត៌មានណាមួយក្នុងចំណោមព័ត៌មានខាងក្រោមនេះត្រូវបានផ្លាស់ប្តូរៈ

- អាសយដ្ឋាន ទ្រង់ទ្រាយក្រុមហ៊ុន នាមករណ៍ក្រុមហ៊ុន កម្មវត្ថុអាជីវកម្ម ឬសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន លេខទូរស័ព្ទ សារអេឡិចត្រូនិក ព័ត៌មានទំនាក់ទំនង ទីស្នាក់ការ និងតម្កល់លក្ខន្តិកៈ ការផ្ទេរ ផ្លាស់ប្តូរម្ចាស់ភាគហ៊ុន សមាសភាពអ្នកគ្រប់គ្រងសហគ្រាស ឬសាខាអ្នកទទួលបន្ទុកកិច្ចការពន្ធដារ
- ការបញ្ឈប់អាជីវកម្ម និង ព័ត៌មានគណនីធនាគារ

នីតិវិធីជាដំបូងគឺ ម្ចាស់អាជីវកម្មត្រូវដាក់លិខិតស្នើសុំកែប្រែទៅក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីទទួលបានការឯកភាពសម្រេច ម្ចាស់អាជីវកម្មត្រូវទៅធ្វើបច្ចុប្បន្នភាពនៅអគ្គនាយកដ្ឋានពន្ធដារ។

## ៤.២ ពន្ធប៉ាតង់

- ប្រកាសលេខ១៩៣ សហវ ប្រ ក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់

ពន្ធប៉ាតង់ គឺជាពន្ធប្រចាំឆ្នាំដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មដោយផ្អែកលើប្រភេទ អ្នកជាប់ពន្ធនិងកម្រិតផលរបរ។

**បែបបទ នៃការបង់ពន្ធប៉ាតង់**

- អ្នកជាប់ពន្ធ ដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។
  **ឧទាហរណ៍៖** អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្ម អាហារដ្ឋានហារណៈ ដឹកជញ្ជូន និងសណ្ឋាគារត្រូវបង់ពន្ធប៉ាតង់សម្រាប់ ៣ សកម្មភាពអាជីវកម្មផ្សេងគ្នា។
- សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកជាសកម្មភាពអាជីវកម្មតែមួយ។
  **ឧទាហរណ៍៖** សណ្ឋាគារ១ដែលមានក្លឹបកម្សាន្ត ភោជនីយដ្ឋាន កន្លែងម៉ាស្សា ក្លឹបហាត់ប្រាណ ឬសកម្មភាពដទៃដែលជាឧបសម្ព័ន្ធនៃសកម្មភាពសណ្ឋាគារដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកជាប់ពន្ធតែមួយ និងស្ថិតក្នុងទីតាំងរួមជាមួយសណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់តែមួយ។
- អ្នកជាប់ពន្ធដែលមានទីកន្លែងអាជីវកម្មជាគោលដើមទីចាត់ការសហគ្រាស សាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយ នៅក្នុងរាជធានី ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។
- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី/ខេត្តផ្សេងគ្នាត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី/ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។
- ពន្ធប៉ាតង់ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ។
- អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់តាំងបង្ហាញពន្ធប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។ ក្នុងករណីមិនបានដាក់តាំងបង្ហាញពន្ធប៉ាតង់ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងត្រូវពិន័យជាប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល។
- អ្នកជាប់ពន្ធ ដែលចាប់ផ្តើមប្រកបសកម្មភាពអាជីវកម្មក្នុងរយៈពេល៦ខែដើមឆ្នាំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ពេញមួយឆ្នាំ ប៉ុន្តែប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦ខែចុងឆ្នាំ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធប៉ាតង់ពាក់កណ្តាល។

### ៤.៣ ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

- មាត្រា ៧ ថ្មី (១) នៃច្បាប់ស្តីពីសារពើពន្ធដែលធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- ប្រកាសលេខ ០៩៨ សហវ.ប្រក ស្តីពីពន្ធលើប្រាក់ចំណូល ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២០

ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលសុទ្ធដែលសម្រេចបានពីសកម្មភាពអាជីវកម្ម និងសកម្មភាពនានាក្រៅពីអាជីវកម្ម របស់នីតិបុគ្គល និងរូបវន្តបុគ្គល។ ប្រាក់ចំណូលជាប់ពន្ធរួមបញ្ចូលទាំងចំណេញមូលធន ការប្រាក់ ថ្លៃឈ្នួល សួយសារ ព្រមទាំងប្រាក់ចំណូលពីទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគដែលរូបវន្តបុគ្គល ឬនីតិបុគ្គលសម្រេចបានមកពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្មរួមទាំងអចលនទ្រព្យផង។

ចំពោះនីតិបុគ្គល ប្រាក់ចំណូលជាប់ពន្ធ គឺជាលទ្ធផលដែលកើតចេញពីការកាត់កងគ្នារវាងចំណូលដុល និងចំណាយទាំងអស់ដែលកើតចេញពីប្រតិបត្តិការគ្រប់ប្រភេទរបស់សហគ្រាសក្នុងរយៈពេលកំពុងដំណើរការឬ នៅពេលបញ្ចប់អាជីវកម្ម។

ចំពោះរូបវន្តបុគ្គល ប្រាក់ចំណូលជាប់ពន្ធ គឺជាលទ្ធផលដែលបានមកពីការយកចំនួនសរុបនៃប្រាក់ចំណូលក្នុងឆ្នាំជាប់ពន្ធកាត់កងនឹងចំណាយ និងទាយជ្ជទាននានា។

សូមមើលសេចក្តីណែនាំលេខ៤០៩១ អពដ របស់អគ្គនាយកដ្ឋានពន្ធដារ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

តាមអត្រាស្តង់ដារនៃពន្ធលើប្រាក់ចំណូលសម្រាប់នីតិបុគ្គលដែលមានចំណាត់ថ្នាក់ជាអ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំគឺត្រូវបង់ពន្ធលើប្រាក់ចំណូល២០%។

### ៤.៤ ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

- សេចក្តីជូនដំណឹងលេខ១២៦៥អពដ ចុះថ្ងៃទ២៤ ខែមករា ឆ្នាំ២០២២

**សម្រាប់អ្នកជាប់ពន្ធមធ្យម និងធំ**

អ្នកជាប់ពន្ធមធ្យម និងធំ ទាំងអស់ ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (ToI E-Filing) យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ។

**សម្រាប់អ្នកជាប់ពន្ធតូច**

អ្នកជាប់ពន្ធតូច អាចដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដោយប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) ក្នុងរយៈពេល៣ខែក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ។ ក្នុងករណីអ្នកជាប់ពន្ធតូច មិនទាន់អាចបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលតាមកម្មវិធីនេះបានអាចបំពេញលិខិតប្រកាសពន្ធដោយដៃនិងដាក់លិខិតប្រកាសពន្ធនៅរដ្ឋបាលសារពើពន្ធបាន។

សូមអនុវត្តតាមនីតិវិធីដូចមានក្នុងសេចក្តីណែនាំ លេខ៧៧០៥ អពដ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០។

ការយឺតយ៉ាវក្នុងការប្រកាសពន្ធលើប្រាក់ចំណូល ត្រូវរងការពិន័យទោសទណ្ឌដូចខាងក្រោម៖

- ប្រាក់ពិន័យចំពោះអំពើរាំងស្ទះ២ ០០០ ០០០ (ពីរលាន) រៀល
- ប្រាក់ពន្ធបន្ថែម ១០% និង
- អត្រាការប្រាក់ប្រចាំខែ ១.៥%។

### ៤.៥ ពន្ធអប្បបរមា

ពន្ធអប្បបរមា គឺជាពន្ធប្រចាំឆ្នាំតាមអត្រាពន្ធ១% លើផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានាលើកលែងតែអាករលើតម្លៃបន្ថែម។ ពន្ធអប្បបរមា ត្រូវបង់នៅពេលទូទាត់ប្រាក់ចំណេញប្រចាំឆ្នាំ ហើយវាក៏អាចត្រូវបានកាត់បន្ថយលើប្រាក់ចំណូលប្រចាំឆ្នាំ។

យោងតាមមាត្រា៣៩នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧ អ្នកជាប់ពន្ធ ត្រូវបង់ពន្ធអប្បបរមានៅពេលធ្វើការទូទាត់ពន្ធលើប្រាក់ចំណូល៖

១. ប្រសិនបើបំណុលពន្ធលើប្រាក់ចំណូលលើសពីបំណុលពន្ធអប្បបរមា៖ អ្នកជាប់ពន្ធត្រូវទូទាត់ពន្ធហើយត្រូវបង់នៅពេលដាក់ប្រកាសសារពើពន្ធ។ ប្រសិនបើចំនួនទឹកប្រាក់ដែលបានកាត់ទុកឬប្រាក់រំដោះពន្ធលើប្រាក់ចំណូលមានចំនួនលើសបំណុលពន្ធអប្បបរមាអ្នកជាប់ពន្ធអាចស្នើសុំឥណទានបាន។ ដូចនេះអ្នកជាប់ពន្ធនោះមិនជាប់ពន្ធអប្បបរមាទេ។

២. ប្រសិនបើបំណុលពន្ធលើប្រាក់ចំណូល តិចជាងបំណុលពន្ធអប្បបរមា ឥណទានពន្ធខាងលើរបស់អ្នកជាប់ពន្ធ ត្រូវបានកាត់បន្ថយដោយចំនួនទឹកប្រាក់លំអៀងខាងលើ។

៣. មានតែអ្នកជាប់ពន្ធដែលមិនបានកាន់កាប់បញ្ជីការគណនេយ្យបានត្រឹមត្រូវប៉ុណ្ណោះ ត្រូវមានកាតព្វកិច្ចបង់ពន្ធអប្បបរមា។

## ៤.៦ អាករលើតម្លៃបន្ថែម

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម និងប្រមូលអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញ ឬ សេវាឲ្យទៅអតិថិជន។

អាករលើតម្លៃបន្ថែម ត្រូវបានអនុវត្តសម្រាប់សហគ្រាសដែលជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវគិតអាករ១០% លើការផ្គត់ផ្គង់ទំនិញ និងសេវា។ ការប្រកាសអាករលើតម្លៃបន្ថែម និងបង់ពន្ធត្រូវកំណត់ក្នុងរយៈពេល២០ថ្ងៃនៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

### ៤.៦.១ អាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) ចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

- អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ ២០២១ ប្រកាសលេខ៥៤២ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- សេចក្តីជូនដំណឹងលេខ៧៧៦ អពដ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ ស្តីពីការពន្យារកាលបរិច្ឆេទកំណត់ដាក់ឱ្យអនុវត្ត
- ប្រកាសលេខ៥៤២ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- សេចក្តីណែនាំលេខ៦៩០០ អពដ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ ស្តីពី ការដាក់ឱ្យអនុវត្តការដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស)
- សេចក្តីណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ លេខ ២៥២០ អពដ ស្តីពី ការកែសម្រួលការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣។

រាល់អ្នកជាប់ពន្ធអនិវាសនជនដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចចុះបញ្ជីពន្ធដារដោយផ្អែកតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពីអ្នកជាប់ពន្ធអនិវាសនជន ត្រូវដាក់លិខិតប្រកាស អាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) សម្រាប់រយៈពេលជាប់ពន្ធខែមេសា ឆ្នាំ២០២២ តរៀងទៅដោយប្រើប្រាស់ប្រព័ន្ធ គ្រប់គ្រងការប្រកាសបង់ពន្ធអាជីវកម្មអនឡាញ(E-Filing)។

កាតព្វកិច្ចនៃការដាក់លិខិតប្រកាស និងបង់ប្រាក់អាករលើតម្លៃបន្ថែមប្រចាំខែ ត្រូវបង់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់ ចំពោះការដាក់លខិតប្រកាសដោយផ្ទាល់ ឬត្រឹមថ្ងៃទី ២៥ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់ចំពោះការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធតាមអនឡាញ E-filing និង E-payment. សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំទាំងអស់ ត្រូវដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែម (វិធីគិតអាករជំនួស) ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសបង់ពន្ធអាជីវកម្មអនឡាញ (E-Filing) យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥នៃខែបន្ទាប់ពីខែ ដែលប្រតិបត្តិការទាក់ទិននឹងអាករនោះបានកើតឡើង ដោយរួចផុតពីពន្ធបន្ថែម ១០% ពីការយឺតយាវក្នុងការដាក់លិខិតប្រកាស។

ដើម្បីស្វែងយល់បន្ថែមអំពីការប្រើប្រាស់មុខងារ វិធីគិតអាករជំនួស ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (E-Filing) អ្នកប្រើប្រាស់ អាចពិនិត្យមើលលម្អិតការណែនាំស្តីពី ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (E-Filing) របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមាននៅក្នុងគេហទំព័រ "www.tax.gov.kh"។ សេចក្តីណែនាំលេខ ២៥២០ អពដ រំលឹកពីវិសាលភាពនៃការអនុវត្តអនុក្រឹត្យលេខ ៦៥ អនក្រ.បក និងប្រកាសលេខ៥៤២ សហវ.ប្រក ដែលអនុវត្តចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយបុគ្គលជាប់អាករដែលជាអ្នកជាប់ពន្ធអនិវាសនជន រួមបញ្ចូលទាំងប្រតិបត្តិករថ្នាលអេឡិចត្រូនិក ដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ដល់និវាសនជនជាសហគ្រាសក្នុងរបបស្វ័យប្រកាស ឬ/និង រូបវន្តបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះប្រតិបត្តិការរវាងអាជីវកម្មនិងអាជីវកម្ម(B2B) អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលបានដាក់លិខិតប្រកាសពន្ធប្រចាំខែរួចហើយ អ្នកជាប់ពន្ធនោះ អាចធ្វើការកែតម្រូវទឹកប្រាក់អតប ឡើងវិញបាន ដោយប្រើប្រាស់លិខិតឥណទាន(credit note) ដែលចេញដោយអ្នកជាប់ពន្ធអនិវាសនជន ដើម្បីធ្វើការកែតម្រូវ។ ជាមួយគ្នានេះ ឥណទាន អតប ដែលកើតឡើងដោយសារការកែតម្រូវនេះត្រូវបានឱ្យកាត់កងតែ ជាមួយអាករលើតម្លៃបន្ថែម(វិធីគិតអាករជំនួសតែប៉ុណ្ណោះ)។

### ៤.៧ ពន្ធលើចំណេញមូលធន

- ប្រកាសលេខ៣៤៦សហវ.ប្រក ស្តីពីពន្ធលើចំណេញមូលធន ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ពន្ធនេះគឺត្រូវបង់ដោយផ្អែកលើភាពខុសគ្នារវាងប្រាក់ចំណូលជាក់ស្តែងពីការលក់ ការផ្ទេរទ្រព្យសម្បត្តិ (អចលនទ្រព្យ កម្មសិទ្ធបញ្ញា រូបិយវត្ថុបរទេស ភតិសន្យា កេរ្តិ៍ឈ្មោះអាជីវកម្ម និងទ្រព្យវិនិយោគ) និងចំណាយដែលអាចកាត់កងបាន។ ចំណាយដែលអាចកាត់កងបាន អាចកំណត់តាមវិធី២របៀប (១) ធ្វើការកាត់កងចំណាយ៨០% នៃប្រាក់ចំណូលដែលទទួលបានពីការលក់ ឬផ្ទេរទ្រព្យសម្បត្តិ ប្រសិនបើគ្មានវិក័យបត្រ ឬឯកសារគាំទ្រអំពីចំនួនទឹកប្រាក់ដែលបានចំណាយ ឬ (២) ធ្វើការកាត់កងចំណាយដែលបានកើតឡើងជាក់ស្តែង និងមានឯកសារគាំទ្រត្រឹមត្រូវ។ ចំពោះមូលធនដទៃទៀតត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយតែតាមវិធីកាត់កងចំណាយជាក់ស្តែងតែប៉ុណ្ណោះ។ ពន្ធលើចំណេញមូលធន ត្រូវបានគិតក្នុងអត្រា ២០% លើប្រាក់ចំណេញមូលធន ដែលបានពីដើមទុន និងការផ្ទេរ។

ការចាប់ផ្តើមអនុវត្តពន្ធលើចំណេញមូលធន សម្រាប់រូបវន្តបុគ្គល

យោងតាមសេចក្តីជូនដំណឹងលេខ៤៥៧៧ អពដ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ពន្ធលើចំណេញមូលធនសម្រាប់រូបវន្តបុគ្គលនឹងចាប់អនុវត្ត ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ តទៅ ហើយអ្នកជាប់ពន្ធ ត្រូវតាមដានបច្ចុប្បន្នភាពពាក់ព័ន្ធនឹងការអនុវត្តជាបន្តបន្ទាប់ទៀត។

### ៤.៨ អាករបំភ្លឺសាធារណៈ

- ប្រកាសលេខ៩៧៦សហវ.ប្រក ស្តីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អាករសម្រាប់បំភ្លឺសាធារណៈ គឺជាពន្ធប្រយោលដែលត្រូវបានកំណត់ តាមអត្រា៣%លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនៃសុរា និងបារី ដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិ សម្រាប់បំភ្លឺសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា។

អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

**មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈត្រូវបានកំណត់ដូចខាងក្រោម៖**

១. ចំពោះអ្នកផលិតនិងអ្នកនាំចូល មូលដ្ឋានគិតអាករ គឺថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក័យបត្រ រួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម(អ.ត.ប) និងអាករបំភ្លឺសាធារណៈខ្លួនឯង (អ.ប.ស)។

២. ចំពោះអ្នកផ្គត់ផ្គង់បន្ត មូលដ្ឋានគិតអាករស្មើនឹង ២០% នៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក័យបត្ររួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករបំភ្លឺសាធារណៈខ្លួនឯង។

### ៤.៩ ពន្ធកាត់ទុក

- មាត្រា២៥ថ្មី មាត្រា២៦ថ្មី និង៣១ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ
- ប្រកាសលេខ ០៩៨ សហវ.ប្រក ស្តីពីពន្ធលើប្រាក់ចំណូល ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០

ស្របតាមមាត្រា២៥ថ្មី មាត្រា២៦ថ្មី និង៣១ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ ឱ្យទៅនិវាសនជន ឬអនិវាសនជន ត្រូវធ្វើការកាត់ទុកប្រាក់ពន្ធបង់ជូនរដ្ឋបាលសារពើពន្ធ នាពេលទូទាត់។

ភ្នាក់ងារកាត់ទុកដែលធ្វើការទូទាត់ជាសាច់ប្រាក់ឬ ជាវត្ថុឱ្យទៅនិវាសនជនត្រូវកាត់ទុក និងបង់ប្រាក់ពន្ធទៅតាមអត្រាដូចខាងក្រោម៖

១. អត្រា១៥% ចំពោះការទូទាត់លើការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ឱ្យទៅនិវាសនជនដែលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស រួមមានកម្រៃជើងសារ ប្រាក់ចំណូលពីសកម្មភាពដឹកជញ្ជូន ជួសជុល សាងសង់ ប្រាក់ចំណូលពីសេវាបច្ចេកទេស វិទ្យាសាស្រ្ត សិល្បៈ វេជ្ជសាស្រ្ត ទន្តសាស្រ្ត នីតិសាស្រ្ត វិស្វកម្ម ស្ថាបត្យកម្ម ការសិក្សា ស្រាវជ្រាវ គណនេយ្យ។

២. អត្រា១០% ចំពោះការទូទាត់ប្រាក់ចំណូល ពីការជួលអចលនទ្រព្យ ឬចលនទ្រព្យ។

៣. អត្រា៦% ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់។

៤. អត្រា៤% ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីសន្សំគ្មានកាលកំណត់។

៥. អត្រា១៤% ចំពោះការទូទាត់ប្រាក់ប្រភពកម្ពុជា ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន។

ភ្នាក់ងារកាត់ទុក មានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក តាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ។

***និវាសនជន** សំដៅដល់រូបវន្តបុគ្គល(បុគ្គលម្នាក់ៗ) ដែលស្នាក់នៅ ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុង ព្រះរាជាណាចក្រ កម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី១៨២ថ្ងៃនៅក្នុងឆ្នាំប្រតិទិន។
***អនិវាសនជន** មានន័យថា មិនមែនជានិវាសនជនកម្ពុជា។ [ច្បាប់ស្តីពីសារពើពន្ធចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៧]

## ៤.១០ ពន្ធលើប្រាក់បៀវត្សប្រចាំខែ

- អនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២

អ្នកជាប់ពន្ធនិវាសនជន ត្រូវបង់ពន្ធលើប្រាក់បៀវត្សប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ តាមអត្រាកំណើនតាមថ្នាក់ដូចខាងក្រោម៖

| ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ (រៀល) | អត្រាពន្ធ |
|---|---|
| ពី ០ ដល់ ១ ៥០០ ០០០ | ០% |
| ពី ១ ៥០០ ០០១ ដល់ ២ ០០០ ០០០ | ៥% |
| ពី ២ ០០០ ០០១ ដល់ ៨ ៥០០ ០០០ | ១០% |
| ពី ៨ ៥០០ ០០១ ដល់ ១២ ៥០០ ០០០ | ១៥% |
| លើសពី ១២ ៥០០ ០០០ | ២០% |

**អ្នកជាប់ពន្ធត្រូវតាមដាននូវបច្ចុប្បន្នភាពតារាងនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ដែលអាចមានការកែសម្រួលក្នុងឆ្នាំបន្តបន្ទាប់។

## ៤.១១ ពន្ធតែមប្រើសារពើពន្ធ

- ប្រកាសលេខ៥៨២សហវ.ប្រក ស្តីពីការអនុវត្តអនុក្រឹត្យលេខ៤០អនក្រ.បកចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធចុះថ្ងៃទី១៨ខែសីហាឆ្នាំ ២០១៥

ពន្ធតែមប្រើសារពើពន្ធ ត្រូវបានកំណត់បង់ពន្ធទៅតាម៖

- ប្រភេទប័ណ្ណប្រកាស ដូចជាប្រកាសប័ណ្ណផ្សាយពាណិជ្ជកម្ម ស្លាកអាជីវកម្មដ្ឋាន ឬផ្ទាំងអក្សរ ឬផ្ទាំងគំនូរ រូបភាពផ្សាយពាណិជ្ជកម្ម
- ទំហំនៃប័ណ្ណប្រកាស (គិតជា dm2)
- តួអក្សរបរទេស និងកម្ពស់ (គិតជា dm2)
- ចល័ត ឬអចល័ត
- មានពន្លឺ ឬគ្មានពន្លឺ
- ទីតាំងផ្សព្វផ្សាយ កែងផ្លូវ ឬស្របផ្លូវ។

  ស្លាកអាជីវកម្មដ្ឋាន៖ សំដៅដល់ប័ណ្ណប្រកាសសម្រាប់សម្គាល់ឈ្មោះទីតាំង ចរិតលក្ខណៈអាជីវកម្ម អាសយដ្ឋាននៃសហគ្រាស ឬអាជីវកម្មដ្ឋាន ដែលស្ថិតនៅច្រកចូលអគារ ឬខ្លោងទ្វារនៃសហគ្រាស ឬអាជីវកម្មដ្ឋាននោះ។ សហគ្រាស ឬអាជីវកម្មដ្ឋានមួយត្រូវមានស្លាកអាជីវកម្មដ្ឋានតែមួយប៉ុណ្ណោះ។

ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម៖ សំដៅដល់ប័ណ្ណប្រកាស ដែលពុំមែនជាប្រភេទប័ណ្ណប្រកាសដូចបានរៀបរាប់ខាងលើហើយដែលផ្សាយពាណិជ្ជកម្មជាសាធារណៈ ដោយមធ្យោបាយចល័ត ឬអចល័ត។
កាលបរិច្ឆេទ នៃការដាក់លិខិតប្រកាសពន្ធតែមប្រើសារពើពន្ធ ចំពោះស្លាកអាជីវកម្មដ្ឋាន និងផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម ម្ចាស់ប័ណ្ណប្រកាសត្រូវដាក់លិខិតប្រកាសនិងបង់ពន្ធក្នុងរយៈពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា នៃឆ្នាំសារពើពន្ធ។

# តម្លៃប្រាក់ពន្ធតែមប្រើសារពើពន្ធដែលត្រូវបង់

<table>
<tr><th>លេខ<br>រៀង</th><th>ប្រភេទបណ្ណប្រកាស</th><th>អត្រាពន្ធ</th><th colspan="2">លក្ខខណ្ឌបន្ថែម</th></tr>
<tr><td colspan="5">ក១. បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រដាសធម្មតា</td></tr>
<tr><td>១</td><td>មានផ្ទៃមិនលើសពី៤០ ដម២</td><td>៥០០៛ /ទំព័រ</td><td colspan="2">បើមានអក្សរបរទេស ១ ៥០០៛ /ទំព័រ</td></tr>
<tr><td>២</td><td>មានផ្ទៃលើសពី៤០ ដម២</td><td>៧០០៛ /ទំព័រ</td><td colspan="2">បើមានអក្សរបរទេស ២ ១០០៛ /ទំព័រ</td></tr>
<tr><td colspan="5">ក២. បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រណាត់ ឬវត្ថុផ្សេងៗ</td></tr>
<tr><td>៣</td><td>មានផ្ទៃមិនលើសពី៤០ ដម២</td><td>៧០០៛ /ទំព័រ</td><td colspan="2">បើមានអក្សរបរទេស ២ ១០០៛ /ទំព័រ</td></tr>
<tr><td>៤</td><td>មានផ្ទៃលើសពី៤០ដល់១០០ ដម២<br>(បើលើសពីនេះ ត្រូវគិតជាផ្ទាំងអក្សរ)</td><td>១ ០០០៛ /ទំព័រ</td><td colspan="2">បើមានអក្សរបរទេស ៣ ០០០៛ /ទំព័រ</td></tr>
<tr><td colspan="5">ក៣. ស្លាកអាជីវកម្មដ្ឋាន</td></tr>
<tr><td>៥</td><td>គ្មានពន្លឺ ស្របដងផ្លូវសាធារណៈ</td><td>១០០៛/ដម២/ឆ្នាំ</td><td rowspan="4">បើមានអក្សរបរទេសត្រូវគិតបន្ថែម ក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត ឬប្រភាគ</td><td>២០០៛</td></tr>
<tr><td>៦</td><td>គ្មានពន្លឺ កែងដងផ្លូវសាធារណៈ</td><td>១៥០៛/ដម២/ឆ្នាំ</td><td>៣០០៛</td></tr>
<tr><td>៧</td><td>មានពន្លឺ ស្របដងផ្លូវសាធារណៈ</td><td>២០០៛/ដម២/ឆ្នាំ</td><td>៤០០៛</td></tr>
<tr><td>៨</td><td>មានពន្លឺ កែងដងផ្លូវសាធារណៈ</td><td>២៥០៛/ដម២/ឆ្នាំ</td><td>៥០០៛</td></tr>
<tr><td colspan="5">ខ. ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម</td></tr>
<tr><td>៩</td><td>គ្មានពន្លឺ ស្របដងផ្លូវសាធារណៈ</td><td>៥០០៛/ដម២/ឆ្នាំ</td><td rowspan="4">បើមានអក្សរបរទេសត្រូវគិតបន្ថែម ក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត ឬប្រភាគ</td><td>១ ០០០៛</td></tr>
<tr><td>១០</td><td>គ្មានពន្លឺ កែងដងផ្លូវសាធារណៈ</td><td>៧០០៛/ដម២/ឆ្នាំ</td><td>១ ៤០០៛</td></tr>
<tr><td>១១</td><td>មានពន្លឺ ស្របដងផ្លូវសាធារណៈ</td><td>៧០០៛/ដម២/ឆ្នាំ</td><td>១ ៤០០៛</td></tr>
<tr><td>១២</td><td>មានពន្លឺ កែងដងផ្លូវសាធារណៈ</td><td>១ ០០០៛/ដម២/ឆ្នាំ</td><td>២ ០០០៛</td></tr>
</table>

### ៤.១២ ពន្ធលើអត្ថប្រយោជន៍បន្ថែម

- មាត្រា៤២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧
- ប្រកាសលេខ៥៤៣សហវ.ប្រក ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីពន្ធលើប្រាក់បៀវត្សចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

អត្ថប្រយោជន៍បន្ថែមរួមមានទំនិញ សេវា ឬអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬវត្ថុផ្សេងទៀតដែលនិយោជកផ្តល់ឲ្យដោយផ្ទាល់ឬដោយប្រយោលដល់រូបវន្តបុគ្គលចំពោះសកម្មភាពបម្រើការងារដែលរូបវន្តបុគ្គលនោះបានបំពេញដើម្បីជាប្រយោជន៍ដល់និយោជក។ និយោជក ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា២០% នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឱ្យនិយោជិតទាំងអស់។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់។

អត្ថប្រយោជន៍បន្ថែម ដែលត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមដូចខាងក្រោម៖

- យានជំនិះគ្រប់ប្រភេទ
- ម្ហូបអាហារ
- លំនៅឋាន ការស្នាក់នៅ
- ទឹក ភ្លើង ទូរស័ព្ទ
- អ្នកបម្រើការងារក្នុងលំនៅឋាន
- ប្រាក់ឱ្យខ្ចីដោយគិតការប្រាក់ទាបជាងការប្រាក់ទីផ្សារ។ អត្រាការប្រាក់ទីផ្សារដែលត្រូវយកមកអនុវត្តត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុ
- ការលក់ទំនិញបញ្ចុះតម្លៃ
- ជំនួយផ្នែកអប់រំសម្រាប់និយោជិត ដែលមិនមែនជាចំណែកណាមួយនៃកម្មវិធីបណ្តុះបណ្តាលទាក់ទិនផ្ទាល់ទៅនឹងការបំពេញការងាររបស់និយោជិតនោះ។
- ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត
- បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាពលើកលែងតែមានការផ្តល់អត្ថប្រយោជន៍បន្ថែមដូចគ្នាឱ្យដល់និយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទី ឬមុខងារ
- ចំណែកនៃការឧបត្ថម្ភលើចំណាយដែលមិនសមហេតុផលនិងមិនចាំបាច់សម្រាប់អាជីវកម្មរបស់និយោជក
- ចំនួនប្រាក់បង់ចូលមូលនិធិសុខុមាលភាពសង្គមដែលលើសពីកម្រិតដែលច្បាប់បានអនុញ្ញាត
- ចំនួនប្រាក់បង់ចូលបេឡាសោធនដែលលើសពី១០% នៃប្រាក់បៀវត្សប្រចាំខែគ្មានបូកអត្ថប្រយោជន៍បន្ថែមរបស់និយោជិត
- ចំណាយសម្រាប់ការទទួលភ្ញៀវ ការកម្សាន្ត ការសម្រាកលំហែ ឬការប្រើប្រាស់មធ្យោបាយណាមួយដែលទាក់ទិននឹងសកម្មភាពទាំងនេះដែលមិនមែនជាចំណែកណាមួយនៃទំនាក់ទំនងបម្រើការងារ
- ការផ្តល់ឱ្យចំណែកណាមួយនៃភាគហ៊ុន ឬទុនក្រុមហ៊ុន។

- *សារាចរលេខ០១១សហវ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែមចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦*

ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងការប្រកបការងារប្រចាំថ្ងៃ របស់និយោជិតសហគ្រាសទាំងអស់ប្រាក់ឧបត្ថម្ភមួយចំនួនដែលនិយោជិតទទួលបានពីការបំពេញការងារ ត្រូវបានអនុគ្រោះដោយមិនគិតបញ្ចូលទៅក្នុងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែម ប្រាក់ឧបត្ថម្ភទាំងនោះរួមមាន៖

- សោហ៊ុយធ្វើដំណើរពីទីកន្លែងស្នាក់នៅទៅទីកន្លែងធ្វើការ និងពីទីកន្លែងធ្វើការទៅកន្លែងស្នាក់នៅ ព្រមទាំងការឧបត្ថម្ភថ្លៃស្នាក់នៅឬ ការផ្តល់កន្លែងស្នាក់នៅក្នុងបរិវេណទីកន្លែងធ្វើការស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។
- ប្រាក់ថ្លៃបាយដែលផ្តល់ឱ្យនិយោជិតទាំងអស់ដោយគ្មានបែងចែកតាមតួនាទីឬ មុខងារ។
- មូលនិធិបេឡាសន្តិសុខសង្គម ឬមូលនិធិសុខមាលភាពសង្គមក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់។
- ប្រាក់ធានារ៉ាប់រងសុខភាព ឬបុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាពដែលផ្តល់ឲ្យនិយោជិតដោយគ្មានការបែងចែកតាមតួនាទី ឬមុខងារ។
- ប្រាក់ឧបត្ថម្ភទារក ឬ ចំណាយទារកដ្ឋានដែលមានចែងក្នុងបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។
- ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ឬប្រាក់បំណាច់នៃការបញ្ឈប់លែងឱ្យធ្វើការ ក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ស្តីពីការងារ។

ដើម្បីទទួលបានការអនុគ្រោះខាងលើនិយោជកត្រូវដាក់ជូនអគ្គនាយកដ្ឋានពន្ធដារនូវឯកសារដែលជាគោលនយោបាយឧបត្ថម្ភដល់កម្មករនិយោជិតរបស់ខ្លួនសម្រាប់រយៈពេលកំណត់នីមួយៗ។

### ៤.១៣ អាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក

- ប្រកាសលេខ ០១២ សហវ.ប្រក ចុះថ្ងៃទី១៤, ខែមករា ឆ្នាំ២០២០ ស្តីពីការកែសម្រួលការកំណត់មូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក

មូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួន ដែលផលិតក្នុងស្រុក ដូចជា៖ ស្រាបៀរ ស្រា បារី និងបារីស៊ីហ្គាគ្រប់ប្រភេទ ភេសជ្ជៈគ្មានជាតិសុរា ដូចមានចែងក្នុងប្រការ០៤ នៃប្រកាសនេះ និងមុខទំនិញជាប់អាករពិសេសដទៃទៀត ត្រូវកំណត់ស្មើនឹង ៩០% (កៅសិបភាគរយ) នៃតម្លៃផ្គត់ផ្គង់ដែលបានកត់ត្រាក្នុងវិក្កយបត្រឱ្យទៅអតិថិជនដោយមិនរួមបញ្ចូលអាករលើតម្លៃបន្ថែម អាករសម្រាប់បំភ្លឺសាធារណៈ និងអាករពិសេសខ្លួនឯង។
អាករពិសេស ត្រូវដល់ពេលកំណត់ និងត្រូវបង់នៅពេលផ្គត់ផ្គង់។
វិធាននៃការផ្គត់ផ្គង់ ត្រូវបានអនុវត្តដូចគ្នានឹងវិធាននៃការផ្គត់ផ្គង់សម្រាប់អាករលើតម្លៃបន្ថែមដូចមានចែងក្នុងមាត្រា៦២ នៃច្បាប់ស្តីពីសារពើពន្ធ។

### ៤.១៤ ការប្រកាសបិទអាជីវកម្ម

ដើម្បីអនុលោមទៅតាមច្បាប់ និងនីតិវិធីជាធរមាន ម្ចាស់អាជីវកម្ម ត្រូវបំពេញកាតព្វកិច្ចទៅតាមដំណាក់កាលដូចតទៅ៖

១). ជំហ៊ានដំបូង ត្រូវរៀបចំសំណុំឯកសារ ស្នើសុំបិទសហគ្រាស ជាស្ថាពរទៅអគ្គនាយកដ្ឋានពន្ធដារ និងធ្វើការបង់ពន្ធប្រថាប់ត្រាបិទក្រុមហ៊ុនដោយត្រូវបំពេញទម្រង់ពាក្យស្នើសុំបញ្ឈប់អាជីវកម្មជាស្ថាពរទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

២). ការធ្វើសវនកម្មសហគ្រាស៖ ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីអង្គភាពពន្ធដារទទួលបានឯកសារស្នើសុំបិទសហគ្រាសរួចមកម្ចាស់សហគ្រាសនឹងទទួលបានលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្ម ម្ចាស់សហគ្រាសត្រូវចូលខ្លួនមកបំភ្លឺជាមួយសវនករដោយត្រូវសហការផ្តល់ឯកសារ និងឆ្លើយតបនឹងមន្ទិលសង្ស័យនានារបស់សវនករ អនុលោមទៅតាមច្បាប់ និងនីតិវិធីនានាពាក់ព័ន្ធនឹងពន្ធដារ។

**ការកំណត់ពន្ធឡើងវិញ៖** បន្ទាប់ពីការធ្វើសវនកម្មសហគ្រាសរួចរាល់ អគ្គនាយកដ្ឋានពន្ធដារ នឹងធ្វើការកំណត់ចំនួនទឹកប្រាក់ដែលម្ចាស់សហគ្រាសត្រូវបង់បន្ថែម ដោយមូលហេតុសហគ្រាសពុំបានបង់ពន្ធត្រឹមត្រូវនាគ្រាកន្លងមក។
ជាថ្មីម្តងទៀត សហគ្រាសត្រូវបង់ចំនួនទឹកប្រាក់ ដែលបានកំណត់ខាងលើនេះ នៅតាមបណ្តាសាខាធនាគារដៃគូនានា តាមកាលកំណត់។ បើអ្នកជាប់ពន្ធ មិនយល់ស្របនឹងការកំណត់ពន្ធនេះទេ អ្នកជាប់ពន្ធ ត្រូវដាក់ពាក្យបណ្តឹងតវ៉ាទៅអគ្គនាយកពន្ធដារក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការទទួលបានការជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញពីអគ្គនាយកដ្ឋានពន្ធដារ។

៣) ជាកាតព្វកិច្ចចុងក្រោយបង្អស់ សហគ្រាសត្រូវជូនដំណឹង និងបំពេញបែបបទស្នើសុំបិទសហគ្រាសទៅក្រសួងពាណិជ្ជកម្មដោយភ្ជាប់ជាមួយនូវឯកសារទាំងអស់ពិសេស គឺឯកសារជម្រះបំណុលពន្ធដែលទទួលបានពីអង្គភាពពន្ធដារ។ប្រសិនបើម្ចាស់អាជីកវកម្ម មិនបានបំពេញតាមជំហ៊ានខាងលើ ម្ចាស់អាជីវកម្មនៅតែមានកាតព្វកិច្ចបង់ពន្ធសារពើពន្ធ និងត្រូវរងពិន័យទោសទណ្ឌ។



# ៤.១៥ កាតព្វកិច្ចអនុលោមតាមសារពើពន្ធ សម្រាប់អ្នកជាប់ពន្ធតូច

## កាតព្វកិច្ចចុះបញ្ជីពន្ធដារ

ផ្អែកលើផលរបរប្រចាំឆ្នាំដូចខាងក្រោមនេះ អ្នកជាប់ពន្ធតូចត្រូវមានកាតព្វកិច្ចចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ និងត្រូវបង់ថ្លៃសេវាចុះបញ្ជីចំនួន ២០ ០០០ (ពីរម៉ឺន) រៀល។

បន្ទាប់ពីបានដាក់លិខិតស្នើសុំចុះបញ្ជីនិងបង់សេវាសាធារណៈរួចរាល់ហើយ អ្នកជាប់ពន្ធនឹងទទួលបានឯកសារដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និង/ឬ
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ និង/ឬ
- ប័ណ្ណពន្ធប៉ាតង និង/ឬ
- សេចក្តីជូនដំណឹងស្តីពីកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ




## ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

- ប្រកាសលេខ០០៩ សហវ ប្រក ស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

- អ្នកជាប់ពន្ធតូច គឺជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានផលរបរដូចខាងក្រោម៖
- ផលរបរប្រចាំឆ្នាំចាប់ពី២៥០ លានរៀល ដល់ ១ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម ពាណិជ្ជកម្ម និងវិស័យសេវាកម្ម ឬ
- ផលរបរប្រចាំឆ្នាំចាប់ពី២៥០ លានរៀល ដល់ ១ ៦០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ
- មានផលរបរ ឬ ផលរបរដែលរំពឹងទុកក្នុងរយៈពេល៣ខែក្នុងឆ្នាំប្រតិទិន ចាប់ពី ៦០ លានរៀល ឬ
- ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬ ស្នង់ថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវា។

- ប្រកាសលេខ១៨២០សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកំណត់វិធាន និងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច

អ្នកជាប់ពន្ធតូច តម្រូវកាន់បញ្ជីគណនេយ្យសាមញ្ញ ៣បញ្ជី ដូចខាងក្រោម៖

- បញ្ជីទិញប្រចាំថ្ងៃ ត្រូវកត់ត្រាជាប្រចាំថ្ងៃនូវរាល់ការចំណាយរួមមាន ទ្រព្យអចលកម្ម ការទិញទំនិញសម្រាប់លក់ ឬសម្រាប់ផ្គត់ផ្គង់សេវា វត្ថុធាតុដើម បុគ្គលិក កម្មករ ទឹកភ្លើង ការជួលអចលនទ្រព្យជាដើម។
- បញ្ជីលក់ប្រចាំថ្ងៃ ដែលកត់ត្រាពីប្រតិបត្តិការលើការផ្គត់ផ្គង់ទំនិញឬសេវា។
- បញ្ជីស្តុកទំនិញ គឺជាការកត់ត្រាពីស្តុកទំនិញដើមគ្រា ទំនិញដែលបានទិញក្នុងគ្រា និងស្តុកទំនិញចុងក្រោយដែលសហគ្រាសបានធ្វើការផ្គត់ផ្គង់ទំនិញ។

សម្រាប់សហគ្រាសដែលធ្វើការផ្គត់ផ្គង់ទាំងទំនិញ និងសេវាដែលចំនួនប៉ាន់ស្មាននៃផលរបរដែលបានពីការផ្គត់ផ្គង់ទំនិញ ស្មើឬតិចជាង១០% នៃចំនួនផ្គត់ផ្គង់សរុប មិនតម្រូវឱ្យកាន់បញ្ជីស្តុកទំនិញបានឡើយ។

## ពន្ធកាត់ទុក

អ្នកជាប់ពន្ធតូច មិនអាចជាភ្នាក់ងារកាត់ទុក លើកលែងតែកាតព្វកិច្ចបង់ពន្ធកាត់ទុក១០% លើការជួលអចលនទ្រព្យ ដូចដែលមានចែងក្នុងមាត្រា ២៥ថ្មី និង ២៦ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

## ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

- អនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២

ប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលមិនបានចាត់ទុកជានីតិបុគ្គលត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រាពន្ធកំណើនតាមថ្នាក់ ចំពោះដូចខាងក្រោម៖

| ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ (រៀល): | អត្រាពន្ធ |
|---|---|
| ពី ០ ដល់ ១៨ ០០០ ០០០ | ០% |
| ពី ១៨ ០០០ ០០១ ដល់ ២៤ ០០០ ០០០ | ៥% |
| ពី ២៤ ០០០ ០០០ ដល់ ១០២ ០០០ ០០០ | ១០% |
| ពី ១០២ ០០០ ០០១ ដល់ ១៥០ ០០០ ០០០ | ១៥% |
| លើសពី ១៥០ ០០០ ០០០ | ២០% |

### ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

ត្រូវបានកំណត់តាមអត្រា ១% នៃផលរបរប្រចាំខែ រួមបញ្ចូលទាំងពន្ធអាករគ្រប់ប្រភេទ លើកលែងតែអាករលើតម្លៃបន្ថែមដែលជាមូលដ្ឋានបង់ពន្ធប្រចាំខែ នឹងត្រូវបង់ពន្ធព្រមទាំងដាក់លិខិតប្រកាសពន្ធប្រចាំខែ ចាប់ពីថ្ងៃទី១ដល់ថ្ងៃទី២០ នៃខែបន្ទាប់ នៅអគ្គនាយកដ្ឋានពន្ធដារ ឬដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធ GDT Tax Pre-filing App។

### ពន្ធអប្បបរមា

ពន្ធអប្បបរមាត្រូវបានកំណត់តាមអត្រា១% នៃផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករគ្រប់ប្រភេទ លើកលែងតែអាករលើតម្លៃបន្ថែម ដែលតម្រូវឱ្យបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។
ប្រាក់រំដោះពន្ធលើប្រាក់ចំណេញដែលបានបង់ជារៀងរាល់ខែក្នុងឆ្នាំជាប់ពន្ធត្រូវក្លាយជាពន្ធអប្បបរមាប្រចាំឆ្នាំដោយស្វ័យប្រវត្តិ។

### ការយោងការខាតបង់:

អ្នកជាប់ពន្ធតូច មិនត្រូវបានអនុញ្ញាតឱ្យយោងការខាតបង់ក្នុងឆ្នាំជាប់ពន្ធណាមួយទៅឆ្នាំបន្តបន្ទាប់ឡើយ។

### អាករលើតម្លៃបន្ថែម

អ្នកជាប់ពន្ធតូច ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលចំនួន៨០% សម្រាប់កាត់កងនឹងអាករលើធាតុចេញ ទោះបីជាមាន ឬគ្មានវិក័យបត្របញ្ជាក់អំពីអាករលើធាតុចូលក៏ដោយ។
អ្នកជាប់ពន្ធ មិនអាចគិតឥណទានអាករលើធាតុចូលជា មាស ពេជ្រ ត្បូងមានតម្លៃ និងសេវាប្តូរប្រាក់បានទេ។
មូលដ្ឋានគិតអាករលើតម្លៃបន្ថែម សម្រាប់អ្នកជាប់ពន្ធតូច ស្មើនឹង

= តម្លៃលក់ /១.១ x ២០%

ការគណនាអាករលើតម្លៃបន្ថែមសម្រាប់អ្នកជាប់ពន្ធតូច ស្មើនឹង = មូលដ្ឋានគិតអាករលើតម្លៃបន្ថែម x ១០%

- ប្រកាសលេខ១៨២០សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកំណត់វិធាន និងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច

ការអនុញ្ញាតឥណទានអាករលើធាតុចូល មិនត្រូវបានអនុវត្តសម្រាប់អ្នកជាប់ពន្ធតូចចំពោះផលរបរដែលជាទឹកប្រាក់លម្អៀងនៃថ្លៃទិញ និងថ្លៃលក់ចំពោះការផ្គត់ផ្គង់ទំនិញ ឬសេវាដូចជា មាស ពេជ្រ ត្បូងថ្មមានតម្លៃ និងសេវាប្តូរប្រាក់នោះទេ។

## តម្លៃសេវា (គិតជារៀល):

| ប្រភេទសេវា | អ្នកជាប់ពន្ធតូច | អ្នកជាប់ពន្ធមធ្យម | អ្នកជាប់ពន្ធធំ | |
|---|---|---|---|---|
| | អ្នកជាប់ពន្ធតូច (ផលរបរប្រចាំឆ្នាំ ចាប់ពី USD ៦១ ៥00 ដល់ USD ២៤៥ 000) | អ្នកជាប់ពន្ធមធ្យម (ផលរបរប្រចាំឆ្នាំ ចាប់ពី USD២៤៥,000 ដល់ US$១,៤ លាន) | ផលរបរចាប់ពី USD ១,៥លាន ដល់ USD២,៥លាន | ផលរបរលើសពី USD ២,៥ លាន |
| ការចុះបញ្ជីពន្ធដារ | ២០ ០០០ | ៤០០ ០០០ | ៤០០ ០០០ | ៤០០ ០០០ |
| ប៉ាតង់ក្នុងមួយសកម្មភាពអាជីវកម្ម | ៤០០ ០០០* | ១ ២០០ ០០០* | ៣ ០០០ ០០០* | ៥ ០០០ ០០០* |
| ការបន្តសុពលភាពប័ណ្ណប៉ាតង់ | ៤០០ ០០០* | ១ ២០០ ០០០* | ៣ ០០០ ០០០* | ៥ ០០០ ០០០* |
| ការកែប្រែព័ត៌មានក្រុមហ៊ុន | ១០ ០០០ | ២០០ ០០០ | ២០០ ០០០ | ២០០ ០០០ |
| ការចុះបញ្ជីសាខាក្រុមហ៊ុន/ការបន្តសុពលភាព | ១០ ០០០ | ២០០ ០០០ | ២០០ ០០០ | ២០០ ០០០ |

*ការដាក់ពាក្យស្នើសុំចុះបញ្ជីពន្ធតាមថ្នាលចុះបញ្ជី registrationservices.gov.kh លើកដំបូង នឹងទទួលបានការបញ្ចុះតម្លៃ ៥០% នៃតម្លៃសេវាចុះបញ្ជីពន្ធដារ

### ៤.១៦ ការពិន័យ និងទោសទណ្ឌ ចំពោះការដាក់លិខិតប្រកាស និងបង់ពន្ធយឺតយ៉ាវ

- ច្បាប់ស្តីពីសារពើពន្ធកម្ពុជា ឆ្នាំ១៩៩៧ និងប្រកាសលេខ២៧០ ស្តីពីសវនកម្មពន្ធដារ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩

ក្នុងករណីអ្នកជាប់ពន្ធមិនបានដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធបានត្រឹមត្រូវទេនោះ នឹងត្រូវអនុវត្តការផាកពិន័យចំពោះអំពើរាំងស្ទះលើបទបញ្ញត្តិស្តីពីពន្ធដារស្របតាមមាត្រា១២៨ និង១៣៣នៃច្បាប់ស្តីពីសារពើពន្ធ។

ការកំណត់ពន្ធឡើងវិញ ពន្ធបន្ថែម និងការប្រាក់ ត្រូវបានកំណត់ដូចខាងក្រោម៖

១. ក្នុងករណីដែលប្រាក់ពន្ធដែលបានកំណត់ មានចំនួនតិចជាង ឬស្មើ១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់ អ្នកជាប់ពន្ធត្រូវបានចាត់ទុកថា បានធ្វេសប្រហែស និងត្រូវទទួលរងពន្ធបន្ថែម១០%នៃប្រាក់ពន្ធដែលបានបង់ខ្វះបូកបន្ថែមការប្រាក់១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

២. ក្នុងករណីដែលប្រាក់ពន្ធដែលបានកំណត់ មានចំនួនលើសពី១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់ អ្នកជាប់ពន្ធត្រូវបានចាត់ទុកថា បានធ្វេសប្រហែសធ្ងន់ធ្ងរ និងត្រូវទទួលរងពន្ធបន្ថែម ២៥% នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

៣. ក្នុងករណីដែលអ្នកជាប់ពន្ធគ្មានបញ្ជិកាគណនេយ្យ ឬកាន់បញ្ជីគណនេយ្យក្លែងបន្លំ ឬមិនសហការផ្តល់ឯកសារនានាទាក់ទិននឹងការធ្វើសវនកម្ម អ្នកជាប់ពន្ធត្រូវបានចាត់ទុកថា បានគេចវេសពន្ធ និងត្រូវទទួលរងពន្ធបន្ថែម៤០% នៃប្រាក់ពន្ធដែលបានបង់ខ្វះ បូកបន្ថែមការប្រាក់១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

៤. ចំពោះការគេចវេស ឬការរាំងការអនុវត្តពន្ធ ដែលត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ក្រៅពីការជាប់ពិន័យបង់ពន្ធបន្ថែម ជនល្មើសនឹងត្រូវប្រឈមការផាកពិន័យពី១០ ០០០ ០០០រៀល ទៅ ២០ ០០០ ០០០រៀល និង/ឬដាក់ពន្ធនាគារចាប់ពីមួយឆ្នាំទៅប្រាំឆ្នាំ ក្នុងករណីគេចវេស និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ រៀល ទៅ ១០ ០០០ ០០០ រៀល និង/ឬដាក់ពន្ធនាគារពី១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ ក្នុងករណីមានការរាំងការអនុវត្តពន្ធ។

## ៤.១៧ សវនកម្មពន្ធដារ

- ប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ស្តីពីសវនកម្មពន្ធដារ

សវនកម្មពន្ធដារគឺសំដៅ ដល់ការពិនិត្យបញ្ជាក់លើការពិនិត្យលើបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីបញ្ជាក់ថាការគណនា ការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធបានត្រឹមត្រូវតាមច្បាប់ពន្ធដារ។

សវនកម្មពន្ធដារមាន បីប្រភេទ ត្រូវជាបីកម្រិត៖

១. **សវនកម្មលើលិខិតស្នាម ៖** សវនកម្មលើលិខិតស្នាមត្រូវបានធ្វើឡើងនៅកន្លែងរដ្ឋបាលសារពើពន្ធ។ សវនកម្មលើលិខិតស្នាមគឺជាការពិនិត្យវិនិច្ឆ័យលើលិខិតប្រកាសសារពើពន្ធរៀបចំឡើងដើម្បីផ្ទៀងផ្ទាត់នៃព័ត៌មានដែលត្រូវបានឆ្លើយប្រកាសដោយផ្ទុវផ្តងគ្នា នឹងលិខិតប្រកាសសារពើពន្ធ ឬព័ត៌មានផ្សេងៗដែលស្នើដោយរដ្ឋបាលសារពើពន្ធ។

២. **សវនកម្មមានកម្រិត ៖** ជាការធ្វើសវនកម្មរយៈពេលខ្លីនិងភ្លាមៗ ទៅលើប្រភេទពន្ធអាករមួយចំនួន ជាអាទិ៍មានប្រភេទអាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករសម្រាប់បំភ្លឺសាធារណៈ អាករលើតម្លៃបន្ថែម រួមទាំងការបង្វិលសងនិងពន្ធអាករផ្សេងទៀត វៀរលែងតែពន្ធលើប្រាក់ចំណូល រួមទាំងការទស្សនកិច្ចដល់កន្លែងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃលិខិតប្រកាសសារពើពន្ធរបស់អ្នកជាប់ពន្ធ។ សវនកម្មនេះ អាចធ្វើឡើងចំពោះតែរយៈពេលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធចរន្ត (N) និងឆ្នាំជាប់ពន្ធមុនឆ្នាំជាប់ពន្ធចរន្ត(N-១)។

៣. **សវនកម្មសារពើពន្ធលម្អិត៖** ជាការធ្វើសវនកម្មទៅលើពន្ធអាករគ្រប់ប្រភេទ និងវាយតម្លៃទៅលើការកាន់កាប់បញ្ជីការគណនេយ្យរបស់សហគ្រាស ដោយត្រូវធ្វើការពិនិត្យជាក់ស្តែងលើប្រតិបត្តិការអាជីវកម្ម ផ្ទៀងផ្ទាត់ទៅនឹងបញ្ជីការគណនេយ្យ និង របាយការណ៍ហិរញ្ញវត្ថុ ដើម្បីជានាថាសហគ្រាសបានរៀបចំរបាយការណ៍គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុបានត្រឹមត្រូវ និងបានបំពេញភារកិច្ចបង់ពន្ធបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ សវនកម្មនេះអាចធ្វើឡើងក្នុងវង្វង់៣(បី)ឆ្នាំជាប់ពន្ធថយក្រោយ(N-3) ប៉ុណ្ណោះ។

មុនពេលចាប់ផ្តើមធ្វើសវនកម្ម រដ្ឋបាលសារពើពន្ធត្រូវជូនដំណឹងស្តីពីការធ្វើសវនកម្មដល់អ្នកជាប់ពន្ធឬ តំណាងអ្នកជាប់ពន្ធជាមុន។ សវនកម្មអាចត្រូវបានចាប់ផ្តើម១០ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីការប្រគល់លិខិតជូនដំណឹង។ ទោះយ៉ាងនេះក្តី សម្រាប់គោលដៅនៃ ការស៊ើបអង្កេតដោយមានលិខិតបញ្ជាបេសកកម្ម រដ្ឋបាលសារពើពន្ធអាចចុះធ្វើសវនកម្មដោយមិនបាច់ជូនដំណឹងមុនដល់អ្នកជាប់ពន្ធ។

ក្រោយពីទទួលបានលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្ម អ្នកជាប់ពន្ធត្រូវត្រៀមឯកសារពាក់ព័ន្ធនឹងអាជីវកម្មទាំងអស់ ដើម្បីទុកផ្តល់ឱ្យសវនករពន្ធដារក្នុងករណីមានការស្នើសុំ។ ឯកសារតម្រូវសម្រាប់ការធ្វើសវនកម្មរួមមាន៖

**១. ព័ត៌មានសហគ្រាស៖**

- របនាសម្ព័ន្ធគ្រប់គ្រង
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
- លក្ខន្តិកៈ
- វិញ្ញាបនបត្រផ្សេងៗ សម្រាប់ធ្វើអាជីវកម្មពីអាជ្ញាធរផ្សេងៗ ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទេសចរណ៍ជាដើម។

**២. ឯកសារគណនេយ្យ៖**

- របាយការណ៍ហិរញ្ញវត្ថុ
- តារាងលម្អិតគណនេយ្យនីមួយៗនៃទ្រព្យសកម្ម
- តារាងលម្អិតគណនេយ្យនីមួយៗនៃទុនម្ចាស់ទ្រព្យ និងបំណុល
- តារាងលម្អិតគណនេយ្យនីមួយៗនៃរបាយការណ៍លទ្ធផល (ចំណេញ/ ខាត)
- សក្ខីបត្រដើមនៃ ឯកសារផ្សេងៗ៖ តារាងបើកប្រាក់បៀវត្សប្រចាំខែ កិច្ចសន្យាការងាររបស់បុគ្គលិកបរទេស និងថ្នាក់គ្រប់គ្រង កិច្ចសន្យាជួល និងលក់ផ្សេងៗ លិខិតប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ ទិនានុប្បវត្តិទិញ លក់ប្រចាំខែ តារាងកែតម្រូវការគណនាប្រាក់ពន្ធ វិក្កយបត្រទិញ លក់ ជាដើម។
- ក្នុងពេលធ្វើសវនកម្ម បើពិនិត្យឃើញថាមានឯកសារមួយចំនួន ដែលមានការចាំបាច់សម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់ សវនករអាចស្នើសុំអ្នកជាប់ពន្ធឱ្យផ្តល់ឯកសារទាំងនោះ។ អ្នកជាប់ពន្ធ ត្រូវផ្តល់ឯកសារដែលបានស្នើសុំ យ៉ាងយឺតបំផុត០៧ ថ្ងៃក្រោយការស្នើសុំ។ ការខកខានមិនបានផ្តល់ឯកសារស្នើសុំ សវនករអាចធ្វើការកំណត់ពន្ធដោយផ្អែកលើព័ត៌មានដែលសវនករពន្ធដារមាន ស្របតាមច្បាប់ស្តីពីពន្ធដារ។

**សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ៖**

ក្នុងអំឡុងពេលធ្វើសវនកម្ម អ្នកជាប់ពន្ធមានសិទ្ធិ និងកាតព្វកិច្ច ដូចខាងក្រោម៖
- សិទ្ធិជ្រើសរើសតំណាងស្របច្បាប់ ដោយមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរ
- សិទ្ធិទទួលបានការពន្យល់អំពីច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារនានា
- សិទ្ធិទទួលបានការពន្យល់ពីហេតុផល និងមូលដ្ឋាននៃការកំណត់ពន្ធឡើងវិញ
- ត្រូវផ្តល់ឯកសារតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ
- ត្រូវបង្ហាញខ្លួនតាមកាលបរិច្ឆេទ និងទីកន្លែងដែលមានបញ្ជាក់ក្នុងលិខិតរបស់រដ្ឋបាលសារពើពន្ធ។
- ពន្ធបន្ថែម និងការប្រាក់

១. ក្នុងករណីដែលប្រាក់ពន្ធដែលបានកំណត់មានចំនួនតិចជាង ឬស្មើ១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់ អ្នកជាប់ពន្ធ ត្រូវបានចាត់ទុកថា បានធ្វេសប្រហែស និងត្រូវទទួលរងពន្ធបន្ថែម១០%នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

២. ក្នុងករណីដែលប្រាក់ពន្ធដែលបានកំណត់មានចំនួនលើសពី១០% នៃប្រាក់ពន្ធដែលត្រូវបង់តាមច្បាប់កំណត់អ្នកជាប់ពន្ធ ត្រូវបានចាត់ទុកថា បានធ្វេសប្រហែសធ្ងន់ធ្ងរ និងត្រូវទទួលរងពន្ធបន្ថែម២៥% នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធ នៅខ្វះមិនទាន់បានបង់។

៣. ក្នុងករណីដែលអ្នកជាប់ពន្ធគ្មានបញ្ជិការគណនេយ្យ ឬកាន់បញ្ជីគណនេយ្យក្លែងបន្លំ ឬមិនសហការផ្តល់ឯកសារនានាទាក់ទងនឹងការធ្វើសវនកម្ម អ្នកជាប់ពន្ធ ត្រូវបានចាត់ទុកថា បានគេចវេសពន្ធ និងត្រូវទទួលរងពន្ធបន្ថែម ៤០% នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥% ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់ពន្ធនៅខ្វះមិនទាន់បានបង់។

ក្រៅពីពន្ធបន្ថែមនិងការប្រាក់ដូចមានចែងខាងលើនេះ អ្នកជាប់ពន្ធ ត្រូវទទួលរងទោសទណ្ឌដទៃទៀត ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**៤.១៧.១ កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុ ឱ្យរងសវនកម្មឯករាជ្យ និងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យរួចមកនិយ័តករគណនេយ្យ និងសវនកម្ម**

- ព្រះរាជក្រមលេខ នស/រកម/១៤១៦/០០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម
- អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម
- ប្រកាសលេខ៥៦៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្ដីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ
- សេចក្ដីជូនដំណឹងរបស់និយ័តករគណនេយ្យ និងសវនកម្មលេខ០២២ ន.គ.ស ស.ជ.ណ ស្ដីពីការរំលឹកអំពីការអនុវត្តកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ឱ្យរងសវនកម្មឯករាជ្យ និងការដាក់ជញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យរួច មកនិយ័តករគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១
- សេចក្ដីជូនដំណឹងរបស់និយ័តករគណនេយ្យ និងសវនកម្មលេខ០០២ ន.គ.ស ស.ជ.ណ ស្ដីពីការអនុវត្តកាតព្វកិច្ចនៃការដាក់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មកនិយ័តករគណនេយ្យ និងសវនកម្ម សម្រាប់សហគ្រាសដែលមិនរងសវនកម្មឯករាជ្យ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២
- សេចក្ដីជូនដំណឹងរបស់និយ័តករគណនេយ្យ និងសវនកម្មលេខ០០១ ន.គ.ស ស.ជ.ណ ស្ដីពីការដាក់លិខិតជូនដំណឹងសម្រាប់ការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រមកនិយ័តករគណនេយ្យ និងសវនកម្មចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិខាងលើ សហគ្រាសទាំងឡាយណាដែលស្ថិតនៅក្នុងចំណុច១ ដល់៤ ខាងក្រោមមានកាតព្វកិច្ចត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំឱ្យរងសវនកម្មសឯករាជ្យជាកំហិត៖

១. សហគ្រាសសាធារណៈ

២. សហគ្រាសទទួលខុសត្រូវជាសាធារណៈ

៣. គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

៤. សហគ្រាសដែលមិនស្ថិតក្នុងចំណុច ១ ២ និង៣ ខាងលើ ប៉ុន្តែបានបំពេញលក្ខណៈវិនិច្ឆ័យទាំងពីរ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យចំនួន ៣ខាងក្រោម ត្រូវមានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មសឯករាជ្យ៖

**លក្ខណៈវិនិច្ឆ័យទី១៖** មានទឹកប្រាក់ផលរបរប្រចាំការិយបរិច្ឆេទគណនេយ្យចាប់ពី ៤ ០០០ ០០០ ០០០ (បួនប៊ីលាន) រៀល ឡើងទៅ។

**លក្ខណៈវិនិច្ឆ័យទី២៖** មានទ្រព្យសកម្មសរុបចាប់ពី ៣ ០០០ ០០០ ០០០(បីប៊ីលាន) រៀល ឡើងទៅ គិតត្រឹមថ្ងៃបិទការិយបរិច្ឆេទគណនេយ្យ។

**លក្ខណៈវិនិច្ឆ័យទី៣៖** មានចំនួនកម្មករនិយោជិតបម្រើការងារចាប់ពី១០០(មួយរយ) នាក់ឡើងទៅ ដោយយោងទៅតាមចំនួនកម្មករនិយោជិតមធ្យមភាគ ដែលមានក្នុងឆ្នាំ។

យោងតាមសេចក្ដីជូនដំណឹងរបស់និយ័តករគណនេយ្យ និងសវនកម្មលេខ០០២ ន.គ.ស ស.ជ.ណ សហគ្រាសដែលមិនជាប់លក្ខខណ្ឌក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យមានកាតព្វកិច្ចត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមកនិយ័តករគណនេយ្យ និងសវនកម្មចាប់ពីការិយបរិច្ឆេទគណនេយ្យ២០២១តទៅ។
ក្នុងការអនុវត្តកាតព្វកិច្ចខាងលើ សហគ្រាសត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម៖

១. សហគ្រាស ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយអនុលោមតាមស្តង់ដារគណនេយ្យជាធរមាន ឱ្យបានរួចរាល់ក្នុងរយៈពេល៣ (បី)ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនីមួយៗ និងត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុនោះមក ន.គ.ស មិនឱ្យហួសរយៈពេល៣(បី)ខែ និង១៥(ដប់ប្រាំ) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនីមួយៗ។

២. សហគ្រាសត្រូវប្រើប្រព័ន្ធ អនឡាញ (E-filing system) របស់ន.គ.ស ដើម្បីដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនោះ មកនិយ័តករគណនេយ្យ និងសវនកម្ម និងត្រូវបង់កម្រៃសេវាសាធារណៈ សម្រាប់ការទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ០១១ អសហ ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្ដីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យ និងសវនកម្ម។

ការខកខាន ឬយឺតយ៉ាវមិនបានអនុវត្តកាតព្វកិច្ចតាមការកំណត់ខាងលើ សហគ្រាសត្រូវរងទោសទណ្ឌដូចមានចែងក្នុងអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម។

យោងតាមសេចក្ដីជូនដំណឹងរបស់និយ័តករគណនេយ្យ និងសវនកម្មលេខ០០១ ន.គ.ស ស.ជ.ណ សហគ្រាសត្រូវប្រើប្រាស់ប្រព័ន្ធអនឡាញ (E-filing system) ដើម្បីដាក់លិខិតជូនដំណឹងសម្រាប់ការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យ កុំព្យូទ័រ មកនិយ័តករគណនេយ្យ និងសវនកម្ម តាមគំរូលិខិតដែលបានផ្ដល់ជូនក្នុងប្រព័ន្ធស្រាប់។

ការខកខានក្នុងការអនុលោមតាមលក្ខខណ្ឌណាមួយដែលបានរៀបរាប់ខាងលើ នឹងត្រូវទទួលរងនូវពិន័យអន្តរការណ៍ដែលមានចែងក្នុងអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម។ ការប្រព្រឹត្តល្មើសវិធានដូចមានចែងក្នុងប្រកាសនេះ នឹងត្រូវទទួលរងពិន័យអន្តរការណ៍ចាប់ពី ៨០០ ០០០ រៀល រហូតដល់ ២០ លានរៀល អាស្រ័យតាមប្រភេទក្រុមហ៊ុន (អ្នកជាប់ពន្ធធំ អ្នកជាប់ពន្ធមធ្យម ឬ អង្គភាពមិនស្វែងរកប្រាក់ចំណេញ) និងប្រភេទនៃបទល្មើស។

### ៤.១៧.២ ការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត

- មាត្រា១១៧ នៃច្បាប់ស្ដីពីសារពើពន្ធ
- ប្រកាសលេខ ២១៧ សហវ.ប្រក ស្ដីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តការលើកទឹកចិត្ត ចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត ចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដែលស្នើសុំធ្វើការកែតម្រូវលិខិតប្រកាសពន្ធ។ប្រកាសនេះមានសុពលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលស្នើសុំកែធ្វើការកែតម្រូវលិខិតប្រកាសពន្ធក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ឬការភ្លាំងភ្លាត់ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបានធ្វើនៅក្នុងលិខិតប្រកាសពន្ធពីមុន។

អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដែលស្នើសុំកែតម្រូវដោយស្ម័គ្រចិត្តនូវកំហុសអចេតនា ក្នុងការកត់ត្រាបញ្ជិកាគណនេយ្យ និងការប្រកាសបង់ពន្ធ ដែលបណ្ដាលមកពីការយល់ដឹងកាតព្វកិច្ចសារពើពន្ធនៅមានកម្រិត ការធ្វេសប្រហែស ការភ័ន្តច្រឡំ ឬការភ្លាំងភ្លាត់ ត្រូវទទួលនូវការលើកទឹកចិត្តដូចខាងក្រោម៖

**១. ការកែតម្រូវមុនពេលមានការចុះធ្វើសវនកម្មពន្ធដារ**

ចំពោះការិយបរិច្ឆេទដែលមិនទាន់ទទួលរងការចុះធ្វើសវនកម្មពន្ធដារ អ្នកជាប់ពន្ធដែលស្ម័គ្រចិត្តចូលខ្លួនមកកែតម្រូវបញ្ជីគណនេយ្យ លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធដែលបានបង់ខ្វះឡើងវិញ អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវទទួលរងពន្ធបន្ថែមចំនួន ១០% និងទទួលបានការអនុគ្រោះបន្ថយការប្រាក់យឺតយ៉ាវដូចខាងក្រោម៖

ក. អនុគ្រោះបន្ថយចំនួន៥០% ចំពោះការប្រាក់យឺតយ៉ាវ ក្នុងករណីដែលការកែតម្រូវនេះធ្វើឡើងក្នុងអំឡុងពេលមិនលើសពី០៦ខែ ក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធ។

ខ. អនុគ្រោះបន្ថយចំនួន២០% ចំពោះការប្រាក់យឺតយ៉ាវ ក្នុងករណីដែលការកែតម្រូវនេះ ធ្វើឡើងលើសពី០៦ខែ ក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធ។

**២. ការកែតម្រូវក្នុងអំឡុងពេលទទួលរងការចុះធ្វើសវនកម្មពន្ធដារ**

ប្រសិនបើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ធ្វើការកែតម្រូវលិខិតប្រកាសពន្ធ នៅក្នុងអំឡុងពេលសវនកម្ម គិតចាប់ពីពេលបានទទួលលិខិតជូនដំណឹងស្ដីពីការចុះធ្វើសវនកម្ម អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវទទួលរងពន្ធបន្ថែមចំនួន១០% និងការប្រាក់យឺតយ៉ាវ១.៥% តាមមាត្រា១៣១ នៃច្បាប់ស្ដីពីសារពើពន្ធ។ អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវទទួលរងពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ តាមនីតិវិធីនិងលទ្ធផលនៃការធ្វើសវនកម្មពន្ធដារ តាមមាត្រា១៣០ ១៣១ ១៣២ និងមាត្រា១៣៣ នៃច្បាប់ស្ដីពីសារពើពន្ធ។ ក្នុងករណីនេះ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ដែលបានបង់រួចមិនអាចកាត់កងជាមួយនឹងពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវដែលជាលទ្ធផលនៃការធ្វើសវនកម្មឡើយ វៀរលែងតែអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកនោះត្រូវបានទទួលរងការធ្វើសវនកម្មលើកទី១ប៉ុណ្ណោះ។

នីតិវិធីនៃការកែតម្រូវលិខិតប្រកាសពន្ធត្រូវកំណត់ដោយសេចក្ដីណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ។

## ៤.១៨ ការដាក់តាំងឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារ នៅទីកន្លែងធ្វើសកម្មភាពសេដ្ឋកិច្ច

- សេចក្តីណែនាំលេខ២៧១៨៥ អពដ ស្តីពីការដាក់តាំង ឬព្យួរបង្ហាញឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារនៅទីកន្លែងធ្វើសកម្មភាពសេដ្ឋកិច្ច ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២

យោងតាមសេចក្តីណែនាំខាងលើ ម្ចាស់សហគ្រាស នាយក និងបណ្ណាធិការ ត្រូវបំពេញកាតព្វកិច្ចដាក់តាំង ឬព្យួរបង្ហាញឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារ ដែលមានសុពលភាព នៅទីកន្លែងធ្វើសកម្មភាពសេដ្ឋកិច្ច ដូចខាងក្រោម៖

**១. ទីចាត់ការសហគ្រាស**

- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណពន្ធប៉ាតង់

**២. សាខាសហគ្រាស**

- លិខិតបញ្ជាក់សាខាសហគ្រាស ឬ/និង
- ប័ណ្ណពន្ធប៉ាតង់

ករណីម្ចាស់សហគ្រាសមិនអនុវត្តតាមការណែនាំនេះ នឹងត្រូវបានចាត់ទុកថាបានប្រព្រឹត្តអំពើរាំងស្ទះចំពោះការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ និងត្រូវទទួលរងទោសទណ្ឌស្របតាមមាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២៧១៨៥ អពដ

L202210260538TD2770

ថ្ងៃ[illegible] ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០២២

**សេចក្តីណែនាំ**
**ស្តីពី**
**ការដាក់តាំង ឬព្យួរបង្ហាញឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារ នៅទីកន្លែងធ្វើសកម្មភាពសេដ្ឋកិច្ច**

អនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ មាត្រា ៧ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម និងប្រការ ៧ នៃប្រកាសលេខ ១៩៣ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ និងក្នុងគោលបំណងបញ្ជាក់អំពីសិទ្ធិនិងកាតព្វកិច្ចជាភ្នាក់ងារកាត់ទុក និងប្រមូលអាករលើតម្លៃបន្ថែម ពីអតិថិជន សម្រាប់ប្រកាសបង់ពន្ធមករដ្ឋបាលសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំដល់លោក-លោកស្រីម្ចាស់សហគ្រាស នាយក និងបណ្ណាធិការ ឱ្យបំពេញកាតព្វកិច្ចដាក់តាំង ឬព្យួរបង្ហាញឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារដែលមានសុពលភាព នៅទីកន្លែងធ្វើសកម្មភាពសេដ្ឋកិច្ចនីមួយៗ ដូចខាងក្រោម÷

១. ទីចាត់ការសហគ្រាស
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណពន្ធប៉ាតង់។

២. សាខាសហគ្រាស
- លិខិតបញ្ជាក់សាខាសហគ្រាស ឬ/និង
- ប័ណ្ណពន្ធប៉ាតង់។

ករណីលោក-លោកស្រីម្ចាស់សហគ្រាស នាយក និងបណ្ណាធិការ មិនអនុវត្តតាមការណែនាំនេះ នឹងត្រូវបានចាត់ទុកថាប្រព្រឹត្តអំពើរាំងស្ទះចំពោះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងត្រូវទទួលរងទោសទណ្ឌស្របតាមមាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រីម្ចាស់សហគ្រាស នាយក និងបណ្ណាធិការទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំខាងលើ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

# ៩ អនុលោមតាពជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- **ប្រកាសលេខ៣៥២ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស (Foreign Workers Centralized Management System) ដើម្បីគ្រប់គ្រងការប្រើប្រាស់ហត្ថពលកម្មជនបរទេសនៅកម្ពុជាតាមប្រព័ន្ធស្វ័យប្រវត្តិកម្មតាមរយៈគេហទំព័រhttps://fwcms.mvlt.gov.khសម្រាប់ឱ្យអនុវត្តចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ តទៅ។

ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ជំនួសឱ្យការដាក់ពាក្យដោយផ្ទាល់ដៃ ដែលអាចឱ្យសហគ្រាសស្នើសុំកម្រងសេវាសាធារណៈពាក់ព័ន្ធនឹងការប្រើប្រាស់ហត្ថពលកម្មបរទេសដូចខាងក្រោម៖

១. ការស្នើសុំលិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មជនបរទេស(កូតា)
២. ការស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស
៣. ការស្នើសុំចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស

សហគ្រាសទាំងអស់ ដែលមានប្រើប្រាស់ហត្ថពលកម្មជនបរទេសត្រូវតែដាក់ពាក្យសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស តាមរយៈគេហទំព័រ FWCMS។

ដើម្បីស្នើសុំប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម លោកអ្នកអាចធ្វើការចុះឈ្មោះ ប្រើប្រាស់ប្រព័ន្ធបានក្នុងនាមជាសហគ្រាស ឬក្នុងនាមជានិយោជិត ដោយចូលទៅកាន់គេហទំព័រដូចខាងក្រោម៖

- សម្រាប់ការគ្រប់គ្រងហត្ថពលកម្មបរទេស សហគ្រាសត្រូវស្នើសុំចុះឈ្មោះបង្កើតគណនីអនទ្បាញជាមុនតាមរយៈគេហទំព័រ fwcms.mlvt.gov.kh ។
- សម្រាប់សេវាសាធារណៈពាក់ព័ន្ធជនបរទេស lacms.mlvt.gov.kh
  សូមចូលទៅកាន់តំណភ្ជាប់ fwcms.mlvt.gov.kh សម្រាប់ការណែនាំទាក់ទងនឹងការចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ។
- **ប្រកាសលេខ៤៣០/២០ក.ប/ប្រ.ក.ខ.ល. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធនឹងវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ឱ្យដំណើរការសេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន១៧សេវា តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ដោយបានចេញប្រកាសលេខ ៤៣០/២០ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម Labour Centralized Management System (LACMS) ដែលមានគេហៈទំព័រ lacms.mlvt.gov.kh ដែលប្រព័ន្ធនេះអាចឱ្យសហគ្រាសស្នើសុំផ្តល់កម្រងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដូចខាងក្រោម៖

១.ការចុះបញ្ជិកាសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស
២.ការចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំសហគ្រាស
៣.ការចុះបញ្ជិកាសៀវភៅបើកប្រាក់/ផ្តល់លិខិតអនុញ្ញាតបើកប្រាក់តាមប្រព័ន្ធកុំព្យូទ័រ
៤.ការចុះទិដ្ឋាការបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស
៥.ការបញ្ជាក់វិញ្ញាបនបត្រពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ
៦.ការផ្តល់សៀវភៅការងារ និងប័ណ្ណសម្គាល់កម្មករនិយោជិតខ្មែរ
៧.បច្ចុប្បន្នភាពទិដ្ឋាការ "ចូល" លើសៀវភៅការងារ
៨.បច្ចុប្បន្នភាពទិដ្ឋាការ "ចេញ" លើសៀវភៅការងារ
៩.ការផ្តល់ទុតិយតាសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ
១០.ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក
១១.ការផ្តល់ទិដ្ឋាការប្រើប្រាស់កម្មករនិយោជិតវ័យក្មេង
១២.ការចុះបញ្ជិកាសៀវភៅបញ្ជីចុះនាមក្មេង
១៣.ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស ធ្វើការបន្ថែមម៉ោង
១៤.ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាសធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍
១៥.ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាសធ្វើការនៅថ្ងៃឈប់សម្រាកបុណ្យដែលមានប្រាក់ឈ្នួល
១៦.ការផ្តល់លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ
១៧.ការហ្វឹកហ្វឺនកូនជាង/កម្មសិក្សា

## ៥.១ ការចុះបញ្ជិកាសេចក្តីជូនដំណឹងប្រកាសបើកសហគ្រាស

- ប្រកាសលេខ ២៨៨សកបយ. ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីសេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន

ម្ចាស់ឬនាយកសហគ្រាសត្រូវសុំចុះបញ្ជិកាសេចក្តីប្រកាសបើកសហគ្រាសជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មុនកាលបរិច្ឆេទបើកសហគ្រាសជាស្ថាពរ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ដើម្បីស្នើសុំការចុះបញ្ជិកាសេចក្តីជូនដំណឹងប្រកាសបើកសហគ្រាស ម្ចាស់សហគ្រាស ត្រូវចូលទៅកាន់គេហទំព័រ lacms.mlvt.gov.kh រួចចុចលើសេវាលេខរៀងទី១ នៃទំព័រ។

## ៥.២ ការចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

- មាត្រា២០ នៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ២៦៨ សកបយ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ស្តីពីសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

គ្រប់និយោជក ត្រូវបង្កើត និងរក្សាទុកឱ្យបានត្រឹមត្រូវនូវសៀវភៅសហគ្រាស ដែលបានចុះហត្ថលេខាដោយសង្ខេបដោយអធិការការងារ។ គំរូនៃសៀវភៅសហគ្រាស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ។

## ៥.៣ ការចុះបញ្ជិកាសៀវភៅបើកប្រាក់/ផ្តល់លិខិតអនុញ្ញាតបើកប្រាក់តាមប្រព័ន្ធកុំព្យូទ័រ

- មាត្រា ៣៩ នៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ២៦៩សកបយ. ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០១ ស្តីពីការបង្កើតសៀវភៅបើកប្រាក់

រាល់និយោជកនៃសហគ្រាស គ្រឹះស្ថាន ត្រូវរក្សាជានិច្ចនូវសៀវភៅបើកប្រាក់ ដែលទម្រង់ នឹងកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។ មុនពេលប្រើប្រាស់ សៀវភៅបើកប្រាក់ ត្រូវមានចុះលេខគ្រប់ទំព័រ និងចុះហត្ថលេខាសង្ខេបដោយអធិការការងារ។

## ៥.៤ ការស្នើសុំចុះទិដ្ឋាការបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស

- មាត្រា២២នៃច្បាប់ស្តីពីការងារ
- សេចក្តីជូនដំណឹងលេខ១៤ សកបយ. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន

មាត្រា២២នៃច្បាប់ស្តីពីការងារ តម្រូវឱ្យសហគ្រាសនីមួយៗ ដែលមានកម្មករនិយោជិតចាប់ពី៨នាក់ឡើងទៅត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងដែលកំណត់អំពីលក្ខខណ្ឌនៃការទទួលឱ្យធ្វើការ ការគិតនិងការបើកប្រាក់ឈ្នួល និងកម្រៃបន្ទាប់បន្សំ តាវកាលិកជាវត្ថុ ពេលម៉ោងធ្វើការ ពេលសម្រាក និងការឈប់សម្រាក ការឱ្យដំណឹងមុន វិធានការអនាម័យ និងសន្តិសុខកម្មករនិយោជិត កាតព្វកិច្ចកម្មករនិយោជិត និងទោសវិន័យចំពោះកម្មករនិយោជិត។

មាត្រា២៤នៃច្បាប់ស្តីពីការងារ ការរៀបចំបទបញ្ជាផ្ទៃក្នុង ត្រូវពិគ្រោះជាមួយប្រតិភូបុគ្គលិក ក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីថ្ងៃបើកសហគ្រាស គ្រឹះស្ថាន។ ម្ចាស់សហគ្រាស ត្រូវដាក់ពាក្យស្នើសុំចុះទិដ្ឋាការបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ដើម្បីទទួលបានការឯកភាពដោយមន្ត្រីអធិការកិច្ចការងារ។

## ៥.៥ ការបញ្ជាក់វិញ្ញាបនបត្រពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ

- ប្រកាសលេខ៤២៩/២០ កប ប្រ.ក.ខ.ល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការពិនិត្យកាយសម្បទានិយោជិតខ្មែរ

កម្មករនិយោជិត ដែលប្រកបមុខរបរណាមួយក្នុងសហគ្រាស ដូចមានចែងក្នុងច្បាប់ស្តីពីការងារ ត្រូវឆ្លងការពិនិត្យកាយសម្បទា មុនពេលប្រកបមុខរបរ។ កម្មករនិយោជិត ត្រូវទៅពិនិត្យកាយសម្បទានៅនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬទៅពិនិត្យសុខភាពនៅមូលដ្ឋានសុខាភិបាលណាមួយដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងជាដៃគូរបស់ នាយកដ្ឋានពេទ្យការងារ។

កម្មករនិយោជិត ត្រូវមកពិនិត្យកាយសម្បទារៀងរាល់២(ពីរ)ឆ្នាំម្តង លើកលែងតែមុខរបរ ឬមុខជំនាញវិជ្ជាជីវៈដែលតម្រូវឱ្យពិនិត្យកាយសម្បទាជាពិសេស។ការចំណាយក្នុងការពិនិត្យកាយសម្បទាឬពិនិត្យសុខភាព និងការស្នើសុំបញ្ជាក់វិញ្ញាបនបត្រពិនិត្យកាយសម្បទា របស់កម្មករនិយោជិត ជាបន្ទុករបស់និយោជក។

ដើម្បីស្នើសុំវិញ្ញាបនបត្រពិនិត្យកាយសម្បទាកម្មករនិយោជិតម្ចាស់សហគ្រាសត្រូវចូលទៅកាន់គេហទំព័រ lacms.mlvt.gov.kh រួចចុចលើសេវាលេខរៀងទី៥ នៃទំព័រ។

ដើម្បីស្នើសុំវិញ្ញាបនបត្រពិនិត្យកាយសម្បទានិយោជិតបរទេសម្ចាស់សហគ្រាសត្រូវចូលទៅកាន់គេហទំព័រ fwcms.mlvt.gov.kh។

### ៥.៦ ការផ្ដល់សៀវភៅការងារ និងប័ណ្ណសម្គាល់កម្មករនិយោជិតខ្មែរ

- យោងមាត្រា៣២ និង៣៤ នៃច្បាប់ស្ដីពីការងារ
- ប្រកាសលេខ១៩៧ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្ដីសៀវភៅការងារកម្មករនិយោជិតខ្មែរ

កម្មករនិយោជិតខ្មែរទាំងអស់ ដែលធ្វើការយកឈ្នួលពីនិយោជកណាមួយ ត្រូវតែមានសៀវភៅការងារជាចាំបាច់។ សៀវភៅការងារនេះគឺសម្រាប់សម្គាល់អត្តសញ្ញាណសាមីខ្លួនក្នុងវិស័យការងារ ដែលមានកត់ត្រាអំពីប្រភេទការងារដែលបានចុះកិច្ចសន្យាធ្វើ ថិរវេលានៃកិច្ចសន្យា ប្រាក់ឈ្នួលដែលបានព្រមព្រៀងគ្នា និងរបៀបនៃការបើកប្រាក់ឈ្នួលជាដើម ដែលជាប្រវត្តិការងារបញ្ជាក់អំពី បទពិសោធន៍ការងាររបស់កម្មករនិយោជិតម្នាក់ៗ អាចឱ្យពួកគាត់ទទួលបានប្រាក់ឈ្នួលសមរម្យជាងមុននៅពេលផ្លាស់ប្ដូរការងារថ្មី។

ការស្នើសុំសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ គឺត្រូវធ្វើឡើងតាមរយៈប្រព័ន្ធ(LACMS) នៅសេវាលេខរៀងទី៦ ដោយត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- វិញ្ញាបនបត្រពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ
- វិញ្ញាបនបត្រមុខរបរកម្មករនិយោជិតខ្មែរ
- រូបថតទំហំ 4x6 (ផ្ទៃស គ្មានស្រមោល និងថតថ្មី ៦ខែចុងក្រោយ ឬថតភ្លាមៗតាមប្រព័ន្ធក៏បាន)។

ដើម្បីស្នើសុំការផ្ដល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ ម្ចាស់សហគ្រាស ត្រូវចូលទៅកាន់គេហទំព័រ lacms.mlvt.gov.kh រួចចុចលើសេវាលេខរៀងទី០៦ នៃទំព័រ។

### ៥.៧ បច្ចុប្បន្នភាពទិដ្ឋាការ "ចូល" ឬ "ចេញ" លើសៀវភៅការងារ

- យោងមាត្រា២១ និង៣៧ នៃច្បាប់ស្ដីពីការងារ
- ប្រកាសលេខ១៩៧ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្ដីសៀវភៅការងារកម្មករនិយោជិតខ្មែរ និង
- សេចក្ដីជូនដំណឹងលេខ២៧ សកបយ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីសេចក្ដីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក (កម្មករ និយោជិត)។

នៅពេលមានកម្មករនិយោជិតចូលធ្វើការងារ ឬឈប់ពីការងារពីរោងចក្រ សហគ្រាសណាមួយ ម្ចាស់ ឬនាយក ត្រូវយកសៀវភៅការងាររបស់កម្មករនិយោជិតទៅចុះទិដ្ឋាការចូល ឬចេញ ក្នុងរយៈពេល ៧ថ្ងៃ ហើយក៏ត្រូវធ្វើសេចក្ដីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃដែលសាមីកម្មករនិយោជិតបានចូលធ្វើការ ឬឈប់ពីការងារ។

ការស្នើសុំបច្ចុប្បន្នភាពទិដ្ឋាការ "ចូល" ឬ "ចេញ" លើសៀវភៅការងារគឺត្រូវធ្វើឡើងតាមរយៈប្រព័ន្ធ(LACMS) នៅសេវាលេខរៀងទី៧ និងទី៨ ដោយត្រូវមានឯកសារដូចខាងក្រោម៖

- វិញ្ញាបនបត្រពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ (បច្ចុប្បន្នភាពទិដ្ឋាការ "ចូល")
- វិញ្ញាបនបត្រមុខរបរកម្មករនិយោជិតខ្មែរ (បច្ចុប្បន្នភាពទិដ្ឋាការ "ចូល")។

### ៥.៨ ការផ្ដល់ទុតិយតាសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ

- យោងមាត្រា៣៨នៃច្បាប់ស្ដីពីការងារ
- ប្រកាសលេខ១៩៧ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្ដីសៀវភៅការងារកម្មករនិយោជិតខ្មែរ

នៅពេលបាត់ ឬអស់សន្លឹកចុះទិដ្ឋាការក្នុងសៀវភៅការងារ នោះសាមីកម្មករនិយោជិត អាចស្នើសុំទុតិយតាសៀវភៅការងារនេះបាន តាមរយៈប្រព័ន្ធ(LACMS) នៅសេវាលេខរៀងទី៩។

### ៥.៩ ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក

- ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក
- ប្រកាសលេខ ៣០២ កប/ប្រ.ក.គ.ក.ប ស្ដីពីប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨

១). គ្រប់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានប្រើកម្មករនិយោជិតចាប់ពី៨(ប្រាំបី)នាក់ឡើងទៅ ត្រូវបង្កើតឱ្យមានប្រតិភូបុគ្គលិកដើម្បីជាតំណាងតែមួយគត់នៅក្នុងសហគ្រាសគ្រឹះស្ថាននោះ តាមរយៈការបោះឆ្នោតជ្រើសរើស។ ប្រតិភូបុគ្គលិកពេញសិទ្ធិម្នាក់ត្រូវមានប្រតិភូបុគ្គលិកជំនួយម្នាក់។

២). ចំពោះសហគ្រាស គ្រឹះស្ថានដែលមានសាខាច្រើន ហើយសាខានីមួយៗមាននិយោជិតចាប់ពី៨នាក់ឡើងទៅ ត្រូវធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកពេញសិទ្ធិ និងប្រតិភូបុគ្គលិកជំនួយ តាមសាខានីមួយៗដាច់ដោយឡែកពីគ្នា។ ក្នុងរយៈពេលប្រាំបីថ្ងៃ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក និយោជកត្រូវរៀបចំកំណត់ហេតុដាក់ជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្នើសុំឱ្យក្រសួងចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក។

ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរបំផុត៦(ប្រាំមួយ)ខែ ក្រោយពេលបើកសហគ្រាស គ្រឹះស្ថាន។ ក្នុងករណីបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិថ្មី ការបោះឆ្នោតត្រូវប្រព្រឹត្តទៅក្នុងរយៈពេល១៥ថ្ងៃ មុនពេលបញ្ចប់អាណត្តិប្រតិភូបុគ្គលិក។ ដើម្បីស្នើសុំការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ម្ចាស់ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន ត្រូវចូលទៅកាន់គេហទំព័រ lacms.mlvt.gov.kh រួចចុចលើសេវាលេខរៀងទី១០ នៃទំព័រ។

## ៥.១០ ការប្រើប្រាស់កម្មករនិយោជិតវ័យក្មេង

មាត្រា១៧៧ នៃច្បាប់ស្តីពីការងារ (អាយុអប្បបរមាអាចចូលធ្វើការជាកម្មករនិយោជិតត្រូវបានកំណត់ត្រឹមអាយុ១៥ឆ្នាំ)។ លក្ខខណ្ឌការងារសមរម្យ អាចអនុញ្ញាតឱ្យកម្មករនិយោជិតវ័យក្មេងធ្វើការងារបានលុះត្រាតែការងារទាំងនោះ មិនធ្វើឱ្យមានគ្រោះថ្នាក់ដល់ សុខភាព និងការរីកលូតលាស់នៃរាងកាយ ផ្លូវចិត្ត និងមិនប៉ះពាល់ដល់ ការចូលរៀននៅក្នុងសាលារៀន ឬការចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលនានារបស់ពួកគេឡើយ។

## ៥.១១ ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាសធ្វើការបន្ថែមម៉ោង /ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ /ថ្ងៃឈប់សម្រាកបុណ្យដែលមានប្រាក់ឈ្នួល

- ប្រកាសលេខ ៨០ សកបយ. ចុះថ្ងៃទី១ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា
- ប្រកាសលេខ ១០០ សកបយ. ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២ ស្តីពីការព្យួរការសំរាកប្រចាំសប្តាហ៍
- ប្រកាសលេខ៣៥៧/២១ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីបែបបទ និងនីតិវិធីនៃការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល

គោលបំណងនៃការស្នើសុំលិខិតអនុញ្ញាតឱ្យធ្វើការបន្ថែមម៉ោង/ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍/ថ្ងៃឈប់សម្រាកបុណ្យដែលមានប្រាក់ឈ្នួល គឺជានាបាននូវការធ្វើការបន្ថែមម៉ោងស្របតាមគោលការណ៍ស្ម័គ្រចិត្តនិងស្របតាមច្បាប់។ ការងារបន្ថែមម៉ោង ត្រូវបានអនុញ្ញាតអតិបរមា២ម៉ោងក្នុងមួយថ្ងៃ ។

លិខិតស្នើសុំធ្វើការបន្ថែមម៉ោង/ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍/ថ្ងៃឈប់សម្រាកបុណ្យដែលមានប្រាក់ឈ្នួលត្រូវបញ្ជូនទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេលយ៉ាងតិច៧ថ្ងៃ មុនការចាប់ផ្តើមធ្វើការបន្ថែមម៉ោងចំនួន០១ច្បាប់ និងលិខិតបញ្ជាក់អំពីយោបល់ឯកភាពរបស់ប្រតិភូពេញសិទ្ធិគ្រប់រូបរបស់សហគ្រាស គ្រឹះស្ថាន ឬការឯកភាពពីចំនួនពាក់កណ្តាលនៃកម្មករនិយោជិត បើសហគ្រាស គ្រឹះស្ថានមិនទាន់មានប្រតិភូបុគ្គលិកចំនួន០១ច្បាប់ ។

ដើម្បីស្នើសុំលិខិតអនុញ្ញាត ម្ចាស់សហគ្រាស ត្រូវចូលទៅកាន់គេហទំព័រ lacms.mlvt.gov.kh រួចចុចលើសេវាលេខរៀងទី១៣ ១៤ និង១៥ នៃទំព័រ។

## ៥.១២ ការហ្វឹកហ្វឺនកូនជាង/កម្មសិក្សា

- សេចក្តីណែនាំលេខ ០៤២/១៥ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការអនុវត្តប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង

សហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់កម្មករនិយោជិតច្រើនជាង ៦០នាក់ ត្រូវតែហ្វឹកហ្វឺនកូនជាងតាមការកំណត់ដូចខាងក្រោម៖

- ១០% ចំពោះ សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី ៦១ នាក់ ដល់ ២០០ នាក់
- ៨% ចំពោះ សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី ២០១ នាក់ដល់ ៥០០នាក់
- បន្ថែម ៤% រាល់ពេលដែលមានចំនួនកម្មករនិយោជិត ៥០០នាក់បន្ថែមទៀត ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិត ចាប់ពី៥០១នាក់ឡើង។
- ចំនួនអតិបរមានៃកូនជាង ត្រូវធ្វើការហ្វឹកហ្វឺនកំណត់ត្រឹម ១១០នាក់ ក្នុងមួយឆ្នាំ ចំពោះសហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ២ ៥០០នាក់ឡើង។

## ៥.១៣ កាតព្វកិច្ចរបស់ក្រុមហ៊ុន សហគ្រាស ក្នុងការរៀបចំបន្ទប់សម្រាប់បំបៅកូនមួយ និងទារកដ្ឋានមួយនៅក្នុងសហគ្រាស ឬនៅជិតនោះ

អ្នកគ្រប់គ្រងត្រូវរៀបចំឱ្យមានបន្ទប់សម្រាប់បំបៅកូនមួយ និងទារកដ្ឋានមួយនៅក្នុងសហគ្រាសឬនៅជិតនោះក្នុងករណីសហគ្រាស ប្រើស្ត្រីចាស់ក្តី ក្មេងក្តីចំនួនយ៉ាងតិច ១០០ (មួយរយ)នាក់។

ប្រសិនបើសហគ្រាសមិនអាចធ្វើការរៀបចំទារកដ្ឋានសម្រាប់ទទួលកុមារដែលមានអាយុលើសពី១៨ខែ នៅក្នុងបរិវេណសហគ្រាសបានទេ កម្មករនិយោជិតដែលជាស្ត្រីអាចយកកូនៗរបស់ពួកគេទៅផ្ញើនៅទារកដ្ឋានផ្សេងទៀត ដោយការចំណាយជាបន្ទុករបស់និយោជក។

## ៥.១៤ ការបង្កើតគិលានដ្ឋានសហគ្រាស

- ប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស
- សេចក្តីជូនដំណឹងលេខ០០៤/២០ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការប្រើប្រាស់គិលានដ្ឋានរួម និងមូលដ្ឋានសុខាភិបាលជំនួសការរៀបចំគិលានដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលស្ថិតក្នុងដែនអនុវត្តច្បាប់ការងារ និងជាប់កាតព្វកិច្ចក្នុងការអនុវត្តប្រកាសរួមលេខ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស ចំពោះសហគ្រាស គ្រឹះស្ថានដែលពុំមានលទ្ធភាពក្នុងការរៀបចំគិលានដ្ឋានសហគ្រាស នៅក្នុងគ្រឹះស្ថានរបស់ខ្លួនអាចប្រើប្រាស់គិលានដ្ឋានរួមឬមូលដ្ឋានសុខាភិបាលជំនួសឱ្យការរៀបចំគិលានដ្ឋានប្រចាំសហគ្រាស គ្រឹះស្ថានរបស់ខ្លួន តាមលក្ខខណ្ឌដូចខាងក្រោម៖

១). សហគ្រាស គ្រឹះស្ថានដែលស្ថិតនៅក្នុងទីតាំងប្រមូលផ្តុំ និងមានចម្ងាយពីគ្នាមិនលើសពី១(មួយ) គីឡូម៉ែត្រ ឬសហគ្រាស គ្រឹះស្ថានដែលនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស អាចបង្កើតគិលានដ្ឋានរួមគ្នាមួយ។ គិលានដ្ឋានរួមនីមួយៗមិនអាចប្រើប្រាស់លើសពីចំនួនកម្មករនិយោជិត ១០ ០០០ (មួយម៉ឺន)នាក់។

២). សហគ្រាស គ្រឹះស្ថាន ដែលមានបំណងប្រើប្រាស់មូលដ្ឋានសុខាភិបាលជំនួសការរៀបចំគិលានដ្ឋានប្រចាំសហគ្រាសត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

- មូលដ្ឋានសុខាភិបាលត្រូវមានការទទួលស្គាល់ដោយក្រសួងសុខាភិបាល និងមានចម្ងាយមិនលើសពី២(ពីរ)គីឡូម៉ែត្រពីសហគ្រាស គ្រឹះស្ថាន។
- ត្រូវជូនដំណឹងអំពីឈ្មោះ និង អាសយដ្ឋាននៃមូលដ្ឋានសុខាភិបាលទៅនាយកដ្ឋានពេទ្យការងារ។

៣). សហគ្រាស គ្រឹះស្ថាននីមួយៗ ដែលប្រើប្រាស់គិលានដ្ឋានរួម ឬមូលដ្ឋានសុខាភិបាលត្រូវរៀបចំឱ្យមានបន្ទប់វិរបួស និងមានគិលានុប្បដ្ឋាយិកាម្នាក់ ប្រចាំនៅក្នុង សហគ្រាស គ្រឹះស្ថានរបស់ខ្លួន។

៤). និយោជក ត្រូវរៀបចំឱ្យមានមធ្យោបាយសមស្រប ដើម្បីបញ្ជូនកម្មករនិយោជិតនៅពេលមានជំងឺ ឬគ្រោះថ្នាក់ការងារទៅគិលានដ្ឋានរួម ឬមូលដ្ឋានសុខាភិបាល។

## ៥.១៥ ការងារសម្រាប់ជនមានពិការភាព

- អនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ ស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ

នីតិបុគ្គល/រូបវន្តបុគ្គល ដែលមានចំនួនកម្មករនិយោជិតសរុបលើសពី១០០នាក់ ត្រូវមានយ៉ាងតិចណាស់ ១% (នៃចំនួនកម្មករសរុប) នៃជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងទៅតាមប្រភេទការងារដោយយោងតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

នីតិបុគ្គលដែលមិនបានបំពេញកាតព្វកិច្ចដើម្បីជ្រើសរើសជនមានពិការភាព ដូចដែលបានតម្រូវតាមអនុក្រឹត្យនេះ ត្រូវបង់វិភាគទានទៅមូលនិធិជនពិការក្នុងចំនួនទឹកប្រាក់៤០% នៃប្រាក់បៀវត្សអប្បបរមារបស់កម្មករនិយោជិត ក្នុងមួយខែសម្រាប់កម្មករនិយោជិតជាជនពិការម្នាក់។

## ៥.១៦ ការបង្កើតគណៈកម្មការអេដស៍

- ប្រកាសលេខ០៨៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងទប់ស្កាត់មេរោគអេដស៍ ជម្ងឺអេដស៍ នៅកន្លែងធ្វើការ

ប្រកាសនេះ មានគោលបំណងបំផុស លើកកម្ពស់ស្មារតី និងជំរុញដល់ការអប់រំ និងជួយកម្មករនិយោជិតអំពីការបង្ការនិងទប់ស្កាត់ការឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍ នៅកន្លែងធ្វើការ។

សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី៨ ដល់៥០នាក់ ត្រូវរៀបចំបង្កើតក្រុមការងារអេដស៍ និងតម្រូវឱ្យបង្កើតគណៈកម្មការអេដស៍នៅក្នុងសហគ្រាស ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករលើសពី៥១នាក់។

ដូចនេះគ្រប់សហគ្រាសទាំងអស់ដែលនៅទូទាំងប្រទេសកម្ពុជា ដែលមានកម្មករលើសពី ៨នាក់ត្រូវបង្កើតស្ថាប័នមួយដើម្បីគ្រប់គ្រងមេរោគអេដស៍ និងលើកកម្ពស់សិទ្ធិកម្មករដែលមានផ្ទុកមេរោគអេដស៍ ស្របតាមគោលការណ៍នៃក្រមប្រតិបត្តិរបស់អង្គការILO ស្តីពីមេរោគអេដស៍ ជម្ងឺអេដស៍ និងពិភពការងារ។

## ៥.១៧ ការប្រើប្រាស់ហត្ថពលកម្មបរទេស

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ឱ្យដំណើរការសេវាសាធារណៈពាក់ព័ន្ធការប្រើប្រាស់ហត្ថពលកម្មបរទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដោយបានចេញប្រកាសលេខ ៣៥២ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្ម តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម The Foreign Workers Centralized Management System (FWCMS) ដែលមានគេហៈទំព័រ fwcms.mlvt.gov.kh/។

### ៥.១៧.១ ការផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស

- យោងមាត្រា២៦៣ដល់២៦៥នៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ១៩៦ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេស។

រោងចក្រ សហគ្រាស ដែលមានតម្រូវការប្រើប្រាស់ហត្ថពលកម្មបរទេស ដែលជាអ្នកឯកទេស អ្នកបច្ចេកទេស ឬអ្នកមានជំនាញវិជ្ជាជីវៈ សម្រាប់ចូលបម្រើការងារនៅកន្លែងដែលរកហត្ថពលកម្មខ្មែរមិនបាន ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរសុំការអនុញ្ញាតជាមុនមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបានមុនដំណាច់ខែវិច្ឆិកានៃឆ្នាំមុនប្រើប្រាស់ តាមប្រព័ន្ធ (FWCMS) ដែលត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖

- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតឱ្យដំណើរការអង្គភាព
- ប័ណ្ណពន្ធប៉ាតង់
- សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចុងក្រោយ។

### ៥.១៧.២ ការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស

- យោងមាត្រា៦៧នៃច្បាប់ស្តីពីការងារ, ប្រកាសលេខ១៩៦ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេស
- ប្រកាសលេខ៤៣០/២០ ក.ប/ប្រ.ក.ខ.ល ស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- សេចក្តីណែនាំលេខ០៥០/១៩ ក.ប/ស.ណ.ន.គ.ប.ក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការកំណត់ប្រភេទកិច្ចសន្យាការងារ
- សេចក្តីណែនាំលេខ០៤៣/១៩ ក.ប/ស.ណ.ន.ម.ហ.ណ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជិកាកិច្ចសន្យាការងារជនបរទេស។

រោងចក្រ សហគ្រាស ដែលមានប្រើប្រាស់ជនបរទេស ត្រូវយកកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សររបស់ជនបរទេសម្នាក់ៗ មកចុះបញ្ជិកាដោយអធិការការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធ (FWCMS) ដែលត្រូវមានភ្ជាប់ឯកសារដូចខាងក្រោម៖

- ឯកសារលិខិតឆ្លងដែន
- ឯកសារកិច្ចសន្យាការងារ។

### ៥.១៧.៣ ការផ្តល់បណ្ណការងារ សៀវភៅការងាររបស់ជនបរទេស

- យោងមាត្រា២៦១និង២៦២នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីបណ្ណការងារ និងសៀវភៅការងារជនបរទេស។

គ្មានជនបរទេសណាម្នាក់ អាចប្រកបមុខរបរណាមួយដោយគ្មានបណ្ណការងារនិង សៀវភៅការងារដែលចេញឱ្យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការបង់អាករពន្យារសុពលភាពបណ្ណការងារ និងសៀវភៅការងារ ត្រូវធ្វើឱ្យហើយមុនដំណាច់ខែមីនា ឆ្នាំនីមួយៗ។ ក្នុងករណីដែលរកឃើញមានការខកខានមិនបានពន្យាសុពលភាពទៅតាមការកំណត់ខាងលើនេះរោងចក្រ សហគ្រាសដែលប្រើសាមីជនបរទេស ត្រូវចាត់ទុកថា បានរក្សាទុក ឬប្រើប្រាស់ជនបរទេសដោយមិនមានបណ្ណការងារ និងសៀវភៅការងារ។

ការស្នើសុំបណ្ណការងារ សៀវភៅការងាររបស់ជនបរទេសគឺត្រូវស្នើតាមរយៈប្រព័ន្ធគ្រប់គ្រង (FWCMS) ដែលត្រូវមានភ្ជាប់ឯកសារដូចខាងក្រោម៖

- លិខិតឆ្លងដែន
- ទិដ្ឋាការចូល និងទិដ្ឋាការស្នាក់នៅ
- កិច្ចសន្យាការងារដែលមានចុះបញ្ជិកា
- វិញ្ញាបនបត្រពិនិត្យកាយសម្បទា
- រូបថតអ្នកសាមីជនបរទេស
- លិខិតបញ្ជាក់ការស្នាក់នៅ (ប្រសិនបើមាន)។

### ៥.១៨ កាតព្វកិច្ចស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

- ប្រកាសលេខ៣៥៨/២១ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារនិងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- សេចក្តីជូនដំណឹងលេខ ០២២/២២ ក.ប/ស.ជ.ណ.អ.ធ.ក ចុះថ្ងៃ ទី២៧ ខែឧសភា ឆ្នាំ២០២២ ស្តីពីការអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

ម្ចាស់រោងចក្រ សហគ្រាស ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចស្វ័យប្រកាសអធិការកិច្ចការងារតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងចំនួន២លើកក្នុងមួយឆ្នាំ ដែលលើកទី១ ត្រូវប្រកាសមុនដំណាច់ខែមិថុនា និងលើកទី២ ត្រូវប្រកាសឱ្យបានមុនដំណាច់ខែធ្នូនៃឆ្នាំនីមួយៗតាមរយៈគេហទំព័រ៖ https://sicms.mlvt.gov.kh/ ដែលអនុវត្តចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ តទៅ។

ក្នុងសេចក្តីជូនដំណឹងខាងលើនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានភ្ជាប់នូវលិខិតដាក់កំហិតរបស់អធិការការងារ ដែលជាចំណុចអាទិភាព ដាច់ខាតទាំង៣១ ចំណុចដែលម្ចាស់ ឬនាយករោងចក្រសហគ្រាសត្រូវអនុវត្តឱ្យខានតែបាន ក្នុងករណីល្មើសនឹងចំណុចណាមួយ នឹងត្រូវរងការផាកពិន័យភ្លាមៗពីអធិការការងារ។

#### ចំណុចអាទិភាពដាច់ខាតទាំង ៣១ ចំណុច សម្រាប់ស្វ័យប្រកាសអធិការកិច្ចការងារ

**ក.បែបបទស្តីពីសហគ្រាស**

១-ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

**ខ.លក្ខខណ្ឌទូទៅនៃការងារ**

១-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់ឈ្នួលថ្ងៃបុណ្យនិងប្រាក់បំណាច់ធ្វើការថ្ងៃឈប់សម្រាកបុណ្យជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

២-ត្រូវផ្តល់ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៣-ត្រូវផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាមានថិរវេលាកំណត់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៤-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការនៅពេលយប់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៥-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៦-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងនៅពេលយប់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៧-មិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសថិរវេលាកំណត់

៨-ត្រូវមានលិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោងពីអធិការការងារ ឬមិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសចិរវេលាដែលបាន អនុញ្ញាត ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត

- ត្រូវមានលិខិតអនុញ្ញាតធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលពីអធិការការងារ ឬមិនត្រូវឱ្យកម្មករនិយោជិតធ្វើការនៅថ្ងៃបុណ្យលើសពីការអនុញ្ញាត ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត

៩-ត្រូវមានលិខិតអនុញ្ញាតព្យួរការឈប់ការសម្រាកប្រចាំសប្តាហ៍ពីអធិការការងារ ឬមិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសចិរវេលាដែលបានអនុញ្ញាត ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត

១០-មិនត្រូវមានការរើសអើងពេលជ្រើសរើសកម្មករនិយោជិតចូលធ្វើការ

១១-មិនត្រូវឱ្យកម្មករនិយោជិតធ្វើការងារដោយបង្ខំ

១២-ត្រូវផ្តល់រយៈពេលនៃការឈប់សម្រាកលំហែមាតុភាពឱ្យបានត្រឹមត្រូវ

- ត្រូវផ្តល់ប្រាក់ឈ្នួលគិតទាំងប្រាក់បន្ទាប់បន្សំនៅពេលឈប់សម្រាកលំហែមាតុភាពឱ្យបានត្រឹមត្រូវ

១៣-មិនត្រូវបញ្ឈប់កម្មករនិយោជិតជាស្ត្រីដែលមានផ្ទៃពោះ ឬឈប់សម្រាលកូន ឬបង្ខំឱ្យលាឈប់ពីការងារ

១៤-ត្រូវធ្វើលិខិតអនុញ្ញាតឱ្យប្រើប្រាស់ក្មេងដែលមានអាយុក្រោម១៨ឆ្នាំឱ្យបានត្រឹមត្រូវ

- មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំ ធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬប្រភេទការងារ និងមុខរបរដែល ប៉ះពាល់ដល់សុខភាព សន្តិសុខការងារ ឬសីលធម៌របស់ក្មេង
- មិនត្រូវឱ្យក្មេងអាយុចាប់ពី១៥ឆ្នាំដល់តិចជាង១៨ឆ្នាំធ្វើការនូវប្រភេទការងារប្រកបដោយគ្រោះថ្នាក់
- មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំធ្វើការលើសចិរវេលាកំណត់
- មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំធ្វើការលើសចិរវេលាកំណត់ក្នុង១សប្តាហ៍
- ត្រូវឱ្យកម្មករនិយោជិតវ័យក្មេងឈប់សម្រាកប្រចាំសប្តាហ៍ឱ្យបានត្រឹមត្រូវ

១៥-ត្រូវធ្វើលិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសប្រចាំឆ្នាំ

១៦-ត្រូវរៀបចំប័ណ្ណការងារនិងសៀវភៅការងារជូនកម្មករនិយោជិតខ្មែរឱ្យបានត្រឹមត្រូវ

**គ.លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ**

១-ត្រូវរៀបចំទីតាំងដាក់កាកសំណល់ធម្មតាឱ្យបានត្រឹមត្រូវ

២-ត្រូវរៀបចំទីតាំងស្តុកទុកកាកសំណល់សារជាតុគីមី ឬសារជាតុពុល នៅដាច់ដោយឡែក និងមានសុវត្ថិភាព

៣-ត្រូវរៀបចំប្រអប់សង្គ្រោះប្រចាំរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

៤-ត្រូវរៀបចំបន្ទប់រុំរបួសប្រចាំរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

៥-ត្រូវអនុវត្តនូវវិធានសុវត្ថិភាពការងារឱ្យបានត្រឹមត្រូវ ដើម្បីបង្ការគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ

៦-ត្រូវរៀបចំប្រព័ន្ធបញ្ចេញ បញ្ចូលខ្យល់នៅក្នុងអគារឱ្យសមស្របតាមបទដ្ឋានដែលបានកំណត់

៧-ត្រូវរៀបចំច្រកគ្រាអាសន្នទាំងអស់អាចចេញដោយសុវត្ថិភាព មានភាពធំទូលាយ គ្មានអ្វីមកបាំង និងមិន ចាក់សោរ

៨-ត្រូវបិទសញ្ញាការសុវត្ថិភាពនិងសុខភាពការងារឱ្យបានគ្រប់គ្រាន់នៅតាមប៉ុស្តិ៍ការងារ និងនៅតាមទីតាំងផ្សេង

៩-ត្រូវរៀបចំឡចំហាយ និងអនុវត្តការប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេសនិងសុវត្ថិភាពការងារ

១០-ត្រូវប្រើប្រាស់គ្រឿងម៉ាស៊ីន ឬគ្រឿងយន្តឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេស និងលក្ខខណ្ឌសុវត្ថិភាពនិងសុខភាព ការងារ

**ឃ.លក្ខខណ្ឌនៃរបបសន្តិសុខសង្គម**

១-ត្រូវរៀបចំចុះបញ្ជិកាវោងចក្រ សហគ្រាសនៅបេឡាជាតិសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ

២-ត្រូវរៀបចំចុះបញ្ជិកាកម្មករនិយោជិតនៅបេឡាជាតិសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ

៣-ត្រូវបង់ភាគទានឱ្យកម្មករនិយោជិតផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពឱ្យបានត្រឹមត្រូវ

**ង.លក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ**

១-ត្រូវរៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក

- ត្រូវអនុវត្តតាមប្រកាសស្តីពីប្រតិភូបុគ្គលិកនៅក្នុងរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ



## ៥.១៩ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន/ កម្មករនិយោជិត ជាមួយបេឡាជាតិរបបសន្តិសុខសង្គម

- ប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី១០ ខែវិច្ឆិកាឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស
- ប្រកាសលេខ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិរបបសន្តិសុខសង្គម

### ការចុះបញ្ជិការបេឡាជាតិរបបសន្តិសុខសង្គម

រាល់អាជីវកម្មដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំមូលនិធិបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតរបស់ខ្លួន រួមទាំងកម្មករនិយោជិតដែលទើបបានជ្រើសរើសក៏ដោយ។ ពាក្យស្នើសុំត្រូវដាក់នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងវិសាលភាពអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ច មកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតរបស់ខ្លួនក្នុង ប.ស.ស.។

ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការថ្មី ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ។

ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថាទម្រង់ "១.០១" ដែលមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសលេខ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយទម្រង់ "១.០១" នូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតតួបករណ៍គតិយុត្តសមមូលដទៃទៀត និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់និយោជក ឬអ្នកតំណាង។

### អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

ប.ស.ស. ត្រូវផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ បន្ទាប់ពីទទួលបានទម្រង់"បញ្ជិកា សហគ្រាស គ្រឹះស្ថាន"។

ប.ស.ស. ត្រូវផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនទៅសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិការួច។

និយោជកត្រូវដាក់តាំង "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន។

បន្ទាប់ពីទទួលបានទម្រង់ "សលាកប័ត្រព័ត៌មានសមាជិក ប.ស.ស." ត្រូវផ្តល់ប័ណ្ណសមាជិក ប.ស.ស. ដែលបញ្ជាក់ពីអត្តសញ្ញាណសមាជិក និងលេខអត្តសញ្ញាណប័ណ្ណសមាជិក ប.ស.ស. ជូនកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ។ ប័ណ្ណសមាជិក ប.ស.ស ត្រូវប្រគល់ជូនទៅកម្មករនិយោជិតតាមរយៈនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។

### កាតព្វកិច្ច និងអត្រានៃការបង់ភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីរបបសន្តិសុខសង្គម បានចុះបញ្ជិកាក្នុងប.ស.ស និងមានកម្មករនិយោជិតចាប់ពី ១ (មួយ) នាក់ឡើងទៅ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន ជូនដល់ ប.ស.ស។

### ៥.១៩.១.ផ្នែកហានិភ័យការងារ

ភាគទានផ្នែកហានិភ័យការងារ គឺជាកាតព្វកិច្ចដោយឡែករបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។ កម្មករនិយោជិតមិនតម្រូវឱ្យមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះទេ។ អត្រាភាគទានផ្នែកហានិភ័យការងារជាអត្រាឯកភាព ដែលត្រូវបានកំណត់ស្មើនឹង០,៨(សូន្យក្បៀសប្រាំបី)ភាគរយនៃប្រាក់ឈ្នួល ឬប្រាក់បៀវត្សជាប់ភាគទានប្រចាំខែរបស់កម្មករនិយោជិត អនុលោមតាមអនុក្រឹត្យលេខ១៤៤អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ប្រាក់ឈ្នួល ឬប្រាក់បៀវត្សជាប់ភាគទាន។

ប្រាក់ឈ្នួលជាប់ភាគទានអប្បបរមាស្មើនឹងចំនួន ៤០០ ០០០(បួនសែន) រៀល និងប្រាក់ឈ្នួលជាប់ភាគទានពិតានស្មើនឹងចំនួន ១ ២០០ ០០០ (មួយលានពីរសែន) រៀល។

### ៥.១៩.២.ផ្នែកថែទាំសុខភាព

អត្រាភាគទានផ្នែកថែទាំសុខភាពជាបន្ទុករបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ស្មើនឹង២,៦ (ពីរក្បៀសប្រាំមួយ) ភាគរយ នៃប្រាក់ឈ្នួល ឬប្រាក់បៀវត្សជាប់ភាគទានប្រចាំខែរបស់កម្មករនិយោជិត នឹងត្រូវកំណត់ដូចគ្នានិងភាគទានហានិភ័យការងារដែរ។

រាល់ការខកខានមិនបានបង់ភាគទានទៅប.ស.ស នឹងត្រូវរងការពិន័យដែលនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ពិន័យអន្តរការណ៍ ចន្លោះពី១០ (ដប់) ដង ទៅ៣០ (សាមសិប) ដង នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។

### ៥.១៩.៣ ផ្នែកប្រាក់សោធន

- អនុក្រឹត្យលេខ១៤៤ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ប្រាក់ឈ្នួល ឬប្រាក់បៀវត្សជាប់ភាគទាន
- អនុក្រឹត្យ លេខ៣២ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ប្រកាសរួមលេខ ១៦៥ ស្តីពីការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី២៨ខែមិថុនា ឆ្នាំ២០២២
- ប្រកាសលេខ១៦៨ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ ភាគទានសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោម បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២
- ប្រកាសលេខ១៦៩ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២
- ប្រកាសលេខ១៧០ ស្តីពីកាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្ត ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២។

### ៥.១៩.៤ ការចុះបញ្ជីសហគ្រាស /គ្រឹះស្ថាននៅក្នុងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីម្នាក់ឡើងទៅ ត្រូវមានកាតព្វកិច្ចចុះបញ្ជីក្នុងប.ស.ស ផ្នែកប្រាក់សោធន ក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ បន្ទាប់ពីមានសកម្មភាពអាជីវកម្ម។
និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន មានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិត ក្នុងប.ស.សយ៉ាងយូរ៣ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទ ចូលបម្រើការងារ។
ភាគទានផ្នែកប្រាក់សោធន ជាបន្ទុករួមគ្នារវាងនិយោជក ឬម្ចាស់ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។ សម្រាប់រយៈពេល៥ឆ្នាំដំបូង ភាគទាននេះត្រូវកំណត់ក្នុងអត្រាស្មើនឹង ៤% នៃប្រាក់ឈ្នួលជាប់ភាគទាន (២% ជាបន្ទុកនិយោជក និង២% ទៀតជាបន្ទុកកម្មករនិយោជិត)។

និយោជក ត្រូវមានកាតព្វកិច្ច ប្រមូលនិងបង់ប្រាក់ភាគទានរបបប្រាក់សោធនជារៀងរាល់ខែ សម្រាប់ចំណែករបស់ខ្លួន និងចំណែករបស់កម្មករនិយោជិតទៅគណនីប.ស.ស នៅធនាគារដៃគូ យ៉ាងយូរត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់។

**កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន**

យោងតាមប្រកាសលេខ១៧០/២២ ស្តីពីកាលបរិច្ឆេទដែលចូលជាធរមាននៃការចាប់ផ្តើមបង់ភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់ភាគទានជាកាតព្វកិច្ច និងតាមគោលការណ៍ស្ម័គ្រចិត្ត ដែលបានចុះនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ តម្រូវឱ្យនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវចាប់ផ្តើមបង់ភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្តចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ តទៅ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវមានកាតព្វកិច្ចប្រមូល និងបង់ភាគទានដែលជាចំណែករបស់ខ្លួន និងជាចំណែករបស់កម្មករនិយោជិតយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥(ដប់ប្រាំ) នៃខែបន្ទាប់ និងត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទាំងអស់ទៅប.ស.ស យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ (ម្ភៃ) នៃខែដដែល។

**ទោសពិន័យៈ**

សហគ្រាស គ្រឹះស្ថាន ដែលមិនបានអនុលោមជាមួយនឹងការចុះបញ្ជិកាកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថាន និងខកខានមិនបានបង់ភាគទាននៃរបបសន្តិសុខសង្គមតាមផ្នែកនីមួយៗ ឬបញ្ជូនព័ត៌មាននៃចំនួនកម្មករនិយោជិតមិនត្រឹមត្រូវ ត្រូវរងការផាកពិន័យជាប្រាក់ពី១០ ទៅ៣០ដងនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។ ការផាកពិន័យនេះ ត្រូវអនុវត្តស្មើនឹងចំនួនកម្មករ ដែលបានធ្វើផ្ទុយពីលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

យោងតាមប្រកាសអន្តរក្រសួងលេខ៣៣៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

| លេខរៀង | ប្រភេទសេវា | កម្មករនិយោជិតចាប់ពី១ ដល់ ៧នាក់ | កម្មករនិយោជិតចាប់ពី៨ ដល់ ១០០នាក់ | កម្មករនិយោជិតចាប់ពី១០០នាក់ |
|---|---|---|---|---|
| ១ | ការចុះបញ្ជិកាសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | ១២០ ០០០ | ១២០ ០០០ | ១២០ ០០០ |
| ២ | ការចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | ៦០ ០០០ | ៦០ ០០០ | ៨០ ០០០ |
| ៣ | ការចុះបញ្ជិកាសៀវភៅបើកប្រាក់/ ផ្តល់លិខិតអនុញ្ញាតបើកប្រាក់តាមប្រព័ន្ធកុំព្យូទ័រ | ៨០ ០០០ | ៨០ ០០០ | ៨០ ០០០ |
| ៤ | ការចុះទិដ្ឋាការបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | គ្មាន | ៦០០ ០០០ | ៦០០ ០០០ |
| ៥ | ការពិនិត្យកាយសម្បទាកម្មករ និយោជិតខ្មែរមុនចូលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន | ២០ ០០០ | ២០ ០០០ | ២០ ០០០ |
| ៦ | ការពិនិត្យកាយសម្បទា កម្មករនិយោជិតជនបរទេសមុនចូលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ |
| ៧ | ការផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាសគ្រឹះស្ថាន ធ្វើការបន្ថែមម៉ោង/ ធ្វើការនៅ ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ / ថ្ងៃបុណ្យដែលមានប្រាក់ឈ្នួល | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ |
| ៨ | ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក | គ្មាន | ៨០ ០០០ | ២៥០ ០០០ |
| ៩ | ការផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ | ២០ ០០០ | ២០ ០០០ | ២០ ០០០ |
| ១០ | ការផ្តល់ទុតិយតាសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ | ២០ ០០០ | ២០ ០០០ | ២០ ០០០ |
| ១១ | ការចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងលើចលនាបុគ្គលិក ចេញ/ចូល | ៤ ០០០ | ៤ ០០០ | ៤ ០០០ |
| ១២ | ការផ្តល់បណ្ណការងារ និងសៀវភៅការងារជនបរទេស | ៥២០ ០០០ | ៥២០ ០០០ | ៥២០ ០០០ |
| ១៣ | ការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស | ៤០ ០០០ | ៤០ ០០០ | ៤០ ០០០ |
| ១៤ | ការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស (កូតា) | ២០០ ០០០ | ២០០ ០០០ | ២០០ ០០០ |

# ៦ អនុលោមតាមភាពជាមួយក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង)

អនុលោមតាមប្រកាសរួមអន្តរក្រសួងលេខ ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្តីពីការអនុវត្តន៍ និងការរៀបចំសម្របសម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារចាប់ពីកសិដ្ឋានផលិត ដល់តុបរិភោគ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍

ក្រសួងសុខាភិបាល ត្រូវបំពេញតួនាទីជាស្ថាប័នទទួលខុសត្រូវនាំមុខតែមួយគត់ក្នុងការដឹកនាំសម្របសម្រួលជំរុញអនុវត្តឱ្យមានប្រសិទ្ធភាពនូវភារកិច្ចពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារនៅកន្លែងប្រើប្រាស់ចុងក្រោយ។

និយមន័យកន្លែងប្រើប្រាស់ចុងក្រោយ សំដៅដល់ការប្រើប្រាស់ចុងក្រោយរបស់អ្នកប្រើប្រាស់រួមមានភោជនីយដ្ឋានខ្នាតធំ អាហារដ្ឋានខ្នាតធំ ភោជនីយដ្ឋានខ្នាតតូច អាហារដ្ឋានខ្នាតតូច ស្តង់លក់ចំណីអាហារ កង់ទីន ហាងកាហ្វេ ហាងនំប៉័ង អាហារដ្ឋាននៅតាមសាលារៀន មន្ទីរពេទ្យ ស្ថាប័ន គ្រឹះស្ថានផ្សេងៗ និងតូបលក់ចំណីអាហារនៅតាមផ្លូវ។

**ភោជនីយដ្ឋានខ្នាតធំ** សំដៅដល់ភោជនីយដ្ឋានដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

១. ទីតាំងស្ថិតក្នុងសណ្ឋាគារ ផ្សារទំនើប មជ្ឈមណ្ឌលពាណិជ្ជកម្ម មជ្ឈមណ្ឌលកម្សាន្ត រមណីយដ្ឋាន កាស៊ីណូ រោងចក្រ សហគ្រាស គ្រឹះស្ថានបណ្តុះបណ្តាល អាកាសយានដ្ឋាន និងតំបន់សេដ្ឋកិច្ចពិសេស។

២. ភោជនីយដ្ឋានប្រណិតត្រូវមានលក្ខណៈសម្បត្តិណាមួយដូចចំណុចខាងក្រោម៖
- ទីតាំងសមស្រប
- បរិស្ថានល្អ
- ការរចនាមានលក្ខណៈប្រណិត
- បន្ទប់បរិភោគមានផាសុកភាព
- កន្លែងចម្អិនអាហារបំពាក់ដោយឧបករណ៍ សម្ភារៈទំនើប
- សម្ភារៈ សង្ហារឹមទំនើប
- បន្ទប់ទឹកមានចំនួនគ្រប់គ្រាន់ និងមានអនាម័យតាមស្តង់ដារ

៣. គ្រឹះស្ថានផលិតចំណីអាហារ និ ភេសជ្ជៈ ដែលមានទីតាំងសមស្រប និងបំពាក់ឧបករណ៍ សម្ភារៈទំនើប ឬមានពាណិជ្ជនាមតែមួយដែលមានពហុសាខា។

**អាហារដ្ឋានខ្នាតធំ៖** សំដៅដល់ប្រភេទអាហារដ្ឋានដែលមានទីតាំងនៅក្នុងរោងចក្រ សហគ្រាស មជ្ឈមណ្ឌលពាណិជ្ជកម្មមន្ទីរពេទ្យ មន្ទីរពហុព្យាបាល គ្រឹះស្ថានសិក្សា អាកាសយានដ្ឋាន។

**ភោជនីយដ្ឋានខ្នាតតូច៖** សំដៅដល់ប្រភេទភោជនីយដ្ឋានដែលមិនមានលក្ខណៈដូចភោជនីយដ្ឋានខ្នាតធំ។

**អាហារដ្ឋានខ្នាតតូច៖** សំដៅដល់ប្រភេទអាហារដ្ឋានដែលមិនមានលក្ខណៈដូចអាហារដ្ឋានខ្នាតធំ។

## ៦.១ កាតព្វកិច្ចដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់អនាម័យ

ប្រកាសលេខ ៤៣០៣ អបស/ឱអបស ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ស្តីពីបែបបទ និងលក្ខខណ្ឌសម្រាប់ផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំពោះចំណីអាហារនៅកន្លែងប្រើប្រាស់ចុងក្រោយ របស់ក្រសួងសុខាភិបាល

ភោជនីយដ្ឋាន និងអាហារដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ត្រូវតែមានវិញ្ញាបនបត្របញ្ជាក់អនាម័យ និងមានអ្នកទទួលខុសត្រូវផ្នែកអនាម័យ និងសុវត្ថិភាពចំណីអាហារ យ៉ាងតិចមួយរូប ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្តីពីអនាម័យ សុវត្ថិភាពចំណីអាហារដែលទទួលស្គាល់ពីក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត។

- ភោជនីយដ្ឋានខ្នាតធំ និងអាហារដ្ឋានខ្នាតធំ ត្រូវស្នើសុំវិញ្ញាបនបត្របញ្ជាក់អនាម័យ នៅនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងនៃក្រសួងសុខាភិបាល
- រីឯភោជនីយដ្ឋានខ្នាតតូច និងអាហារដ្ឋានខ្នាតតូច ត្រូវស្នើសុំវិញ្ញាបនបត្របញ្ជាក់អនាម័យ នៅមន្ទីរសុខាភិបាលរាជធានី ខេត្ត។

វិញ្ញាបនបត្របញ្ជាក់អនាម័យមានសុពលភាព រយៈពេល១ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខារបស់ថ្នាក់ដឹកនាំក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត (សម្រាប់ការផ្តល់ជាលើកដំបូង)។ លោកអ្នកអាចទាញយកពាក្យស្នើសុំតាមរយៈគេហទំព័ររបស់នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង www.ddfcambodia.com (មើលនៅទំព័រមុខ ជ្រើសរើសពាក្យថា ចំណីអាហារ(Food) បន្ទាប់មកនឹងឃើញពាក្យភោជនីយដ្ឋាន នោះពាក្យសុំអាចទាញយកមកប្រើបាន។)

ប្រតិបត្តិករធុរកិច្ចចំណីអាហារអាចដាក់ពាក្យសុំបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់អនាម័យជារៀងរាល់ឆ្នាំ ដោយត្រូវធ្វើឡើងក្នុងអំឡុងពេល៣០ថ្ងៃ មុនផុតកំណត់សុពលភាពរបស់វិញ្ញាបនបត្រនេះ ដើម្បីធានាថាការធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដំណើរការដោយមានវិញ្ញាបនបត្រស្របច្បាប់។

### ៦.២ កាតព្វកិច្ចដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ

- ប្រកាសលេខ ៤៣០៤ អបស/ ឪអបស ចុះថ្ងៃទី១០ តុលា ឆ្នាំ២០១៩ ស្តីពីបែបបទ និងលក្ខខណ្ឌសម្រាប់ផ្តល់វិញ្ញាបនបត្រ បញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ ចំពោះចំណីអាហារ នៅកន្លែងប្រើប្រាស់ចុងក្រោយរបស់ក្រសួងសុខាភិបាល

ភោជនីយដ្ឋានខ្នាតធំ និងអាហារដ្ឋានខ្នាតធំ ដែលជាភោជនីយដ្ឋានស្តង់ដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានកាតព្វកិច្ចស្នើសុំវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ និងត្រូវដាក់ពាក្យសុំនៅក្រសួងសុខាភិបាល នឹងពុំតម្រូវឱ្យស្នើសុំវិញ្ញាបនបត្របញ្ជាក់អនាម័យទៀតនោះទេ។ ប្រតិបត្តិករធុរកិច្ចចំណីអាហារ នឹងត្រូវផ្តល់ជូននូវវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អដោយផ្អែកតាមកម្រិតនៃភាពអនុលោមតាមតារាង លក្ខណៈវិនិច្ឆ័យ(Check List)ក្នុងការត្រួតពិនិត្យ វាយតម្លៃអនាម័យ សុវត្ថិភាពចំណីអាហារ ចំណាត់ថ្នាក់ដែលនឹងត្រូវផ្តល់ជូន និងទទួលស្គាល់ដោយក្រសួងសុខាភិបាលរួមមាន វិញ្ញាបនបត្រចំណាត់ថ្នាក់ " A " (ល្អប្រសើរ) វិញ្ញាបនបត្រចំណាត់ថ្នាក់ " B " (ល្អ) និងវិញ្ញាបនបត្រចំណាត់ថ្នាក់ " C " (ល្អបង្គួរ)។

វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អមានសុពលភាព២ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខារបស់ថ្នាក់ដឹកនាំក្រសួងសុខាភិបាល(សម្រាប់ការផ្តល់ជាលើកដំបូង)។
ប្រតិបត្តិករធុរកិច្ចចំណីអាហារ អាចដាក់ពាក្យសុំបន្តសុពលភាពវិញ្ញាបនបត្រនេះជារៀងរាល់២ឆ្នាំម្តង ដោយត្រូវធ្វើឡើងក្នុងអំឡុងពេល៣០ថ្ងៃ នៃថ្ងៃធ្វើការ មុនផុតកំណត់សុពលភាពរបស់វិញ្ញាបនបត្រនេះ ដើម្បីជានាថាការធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដំណើរការដោយមានវិញ្ញាបនបត្រស្របច្បាប់។

- ប្រកាសរួមលេខ១៣៥៦ សហវ.ប្រក ចុះថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល

យោងតាមឧបសម្ព័ន្ធ១ នៃប្រកាសរួមលេខ១៣៥៦ សហវ.ប្រក ចុះថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១៦ ការស្នើសុំបន្តសុពលភាពចំពោះសេវាដែលបានកំណត់សុពលភាពដែលមានចែងក្នុងឧបសម្ព័ន្ធនេះ ក្រសួងសុខាភិបាលកំណត់យកតម្លៃសេវា ៧០% នៃតម្លៃសេវា ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។ សុពលភាពបន្តមាន រយៈពេលស្មើនឹងសុពលភាពផ្តល់ជូនលើកដំបូងដែរ។

| ប្រភេទសេវា | តម្លៃសេវាសាធារណៈ (ជារៀល) | | |
|---|---|---|---|
| វិញ្ញាបនបត្របញ្ជាក់អនាម័យ | ៦០០ ០០០ | | |
| វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ | ៦០០ ០០០ | | |
| ស្លាកសញ្ញា (Logo) បញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ (ចំណាត់ថ្នាក់ល្អប្រសើរ ល្អ និង ល្អបង្គួរ) | ចំណាត់ថ្នាក់ A (ល្អប្រសើរ) | ចំណាត់ថ្នាក់ B (ល្អ) | ចំណាត់ថ្នាក់ C (ល្អបង្គួរ) |
| | ៨០០ ០០០ | ៦០០ ០០០ | ៤០០ ០០០ |

# ៧ អនុលោមតាមភាពជាមួយក្រសួងទេសចរណ៍

## ៧.១ ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍

១. ប្រព័ន្ធថ្នាលបច្ចេកវិទ្យាព័ត៌មាន៖ mot.registrationservices.gov.kh (សម្រាប់អាជីវកម្មថ្មី)
២. ប្រព័ន្ធផ្តល់អាជ្ញាបណ្ណទេសចរណ៍អនឡាញ៖ cambodiatourismindustry.org

- ព្រះរាជក្រម លេខ នស/ រកម/ ០៦០៩/០០៧ ច្បាប់ស្តីពីទេសចរណ៍ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០០៩ តម្រូវឱ្យអាជីវកម្មទេសចរណ៍ទាំងអស់ត្រូវចុះឈ្មោះ ដើម្បីទទួលបានអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍។
- មាត្រា៣២ នៃច្បាប់ស្តីពីទេសចរណ៍
- ប្រកាសអន្តរក្រសួងលេខ ១៦០ សហវ ស្តីពីតម្លៃសេវាសាធារណៈរបស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០
- សេចក្តីជូនដំណឹងលេខ ០១២ សជណ ស្តីពីការអនុវត្តការចុះបញ្ជីស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣

អនុលោមតាមមាត្រា៣២ នៃច្បាប់ស្តីពីទេសចរណ៍ គ្មានបុគ្គលណាម្នាក់ អាចប្រកបអាជីវកម្មទេសចរណ៍បានទេ ប្រសិនបើបុគ្គលនោះមិនទទួលបានការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ពីក្រសួងទេសចរណ៍ ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងករណីដែលអាជីវកម្មច្រើនប្រភេទ ត្រូវបានប្រតិបត្តិដោយបុគ្គលតែម្នាក់ចេញពីទីតាំងតែមួយប្រភេទ អាជីវកម្មនីមួយៗត្រូវតែមានអាជ្ញាបណ្ណផ្សេងៗគ្នា ប្រៀបដូចជាអាជីវកម្មផ្សេងគ្នាដែលប្រតិបត្តិចេញពីទីតាំងផ្សេងគ្នាយ៉ាងដូច្នោះដែរ។

ក្នុងករណី ដែលបុគ្គលម្នាក់មានអាជីវកម្មទេសចរណ៍មួយប្រភេទ ហើយមានសាខាច្រើនកន្លែង សាខានីមួយៗនោះត្រូវតែមាន អាជ្ញាបណ្ណទេសចរណ៍។

ម្ចាស់អាជីវកម្ម ត្រូវដាក់តាំងបង្ហាញអាជ្ញាបណ្ណទេសចរណ៍នៅទីកន្លែងដែលងាយមើលឃើញក្នុងបរិវេណធ្វើអាជីវកម្មរបស់អ្នកទទួលអាជ្ញាបណ្ណ។

ម្ចាស់អាជ្ញាបណ្ណ ត្រូវតែដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណឱ្យបាន៣០(សាមសិប)ថ្ងៃយ៉ាងតិច មុនថ្ងៃផុតកំណត់សុពលភាព អាជ្ញាបណ្ណ ដោយភ្ជាប់មកជាមួយនូវប្រាក់កម្រៃបន្តសុពលភាពអាជ្ញាបណ្ណ។

យោងតាមសេចក្តីជូនដំណឹងលេខ០១២ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ គ្រប់ប្រតិបត្តិករទេសចរណ៍ត្រូវស្នើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់អាជីវកម្មថ្មី ឬបន្តសុពលភាពអាជ្ញាបណ្ណទេសចរណ៍តាមរយៈប្រព័ន្ធបច្ចេកវិទ្យា ដូចខាងក្រោម៖

១. សម្រាប់អាជីវកម្មទេសចរណ៍ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍មុនថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ត្រូវដាក់ពាក្យ ស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណទេសចរណ៍តាមរយៈ គេហទំព័រ www.cambodiatourismindustry.org.

២. ដោយឡែកសម្រាប់អាជីវកម្មទេសចរណ៍ រួមមានសេវាស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាន ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDx ចាប់ពីថ្ងៃទី០១ ខែកញ្ញាឆ្នាំ២០២១ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មីឬបន្តតាមរយៈគេហទំព័រ mot.registrationservices.gov.kh.

### ចំពោះការស្នើសុំថ្មី ប្រតិបត្តិករទេសចរណ៍ត្រូវភ្ជាប់ជាមួយនូវឯកសារតម្រូវដូចជា៖

- លិខិតអនុញ្ញាតសាងសង់ ឬជួសជុលចេញដោយក្រសួង ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
- លិខិតបញ្ជាក់ពីប្រព័ន្ធគ្រប់គ្រងអគ្គិភ័យ និងប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព ចេញដោយក្រសួងមហាផ្ទៃ ឬស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ ឬវិញ្ញាបនបត្របញ្ជាក់អនាម័យ
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
- វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- រូបថតរបស់អ្នកគ្រប់គ្រង (៤x៦)។

**ឯកសារតម្រូវសម្រាប់ការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណទេសចរណ៍**

- អាជ្ញាបណ្ណទេសចរណ៍ឆ្នាំចាស់
- កិច្ចសន្យាគោរពអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានារបស់រដ្ឋ
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ
- រូបថត របស់អ្នកគ្រប់គ្រង (៤x៦)

ការអនុវត្តការបង់កម្រៃសេវាសាធារណៈរបស់ក្រសួងទេសចរណ៍ ត្រូវបានធ្វើឡើងតាមប្រព័ន្ធធនាគារទាំងស្រុង តាមរយៈធនាគារវីង (Wing Bank) ឬ ធនាគារ ABA (ABA Bank)។

- **សារាចរណែនាំរបស់ក្រសួងទេសចរណ៍ លេខ០០៨ ស្តីពីការអនុវត្តកម្រៃសេវាបូកបន្ថែម លើការចំណាយរបស់អតិថិជន (Service Charge) ដោយមូលដ្ឋានអាជីវកម្មទេសចរណ៍ ចុះថ្ងៃទី៩ ឧសភា ២០១៨**

មូលដ្ឋានអាជីវកម្មទេសចរណ៍ដែលអនុវត្តកម្រៃសេវាបូកបន្ថែម (Service Charge) ត្រូវអនុលោមតាមលក្ខខណ្ឌចំនួន៤ ដូចខាងក្រោម៖

**ទី១៖** អាជីវកម្មសេវាកម្មទេសចរណ៍ ត្រូវមានអាជ្ញាបណ្ណទេសចរណ៍ដែលមានសុពលភាព

**ទី២៖** អាជីវកម្មសេវាកម្មទេសចរណ៍ត្រូវមានវិញ្ញាបនបត្របញ្ជាក់កម្រិតគុណភាពសេវាកម្មទេសចរណ៍ដែលចេញដោយក្រសួងទេសចរណ៍ ដូចជា ចំណាត់ថ្នាក់ភោជនីយដ្ឋាន និងអាហារដ្ឋាន...

**ទី៣៖** អាជីវកម្មសេវាកម្មទេសចរណ៍ ត្រូវចូលរួមប្រឡងប្រណាំងធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍។ អាជីវកម្មសេវាកម្មទេសចរណ៍ត្រូវជាប់ជ័យលាភីនៃចលនាប្រឡងប្រណាំង «បដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍» ។

**ទី៤៖** ដើម្បីបង្ហាញពីតម្លាភាព អាជីវកម្មត្រូវបិទបង្ហាញដើម្បីឱ្យភ្ញៀវមើលឃើញនៅច្រកចូលទីតាំងអាជីវកម្ម នូវស្ទីកគ័រដែលអាចយកប្រាក់សេវាបន្ថែម និងត្រូវតាំងបង្ហាញស្លាកសញ្ញាជ័យលាភីពានរង្វាន់ "បដិសណ្ឋារកិច្ចល្អ ក្នុងវិស័យទេសចរណ៍"។

ប្រតិបត្តិករទេសចរណ៍ដែលមិនអនុវត្តតាមការណែនាំខាងលើនេះ នឹងត្រូវទទួលពិន័យអន្តរការណ៍ជាទឹកប្រាក់ចំនួន៣០០,០០០ (សាមសិបម៉ឺន)រៀល សម្រាប់មួយករណីល្មើស។

## ៧.២ ចំណាត់ថ្នាក់ភោជនីយដ្ឋាននិង អាហារដ្ឋាន

- សេចក្តីណែនាំលេខ០១៧ណន ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ស្តីពីការដាក់ពាក្យស្នើសុំវាយតម្លៃចំណាត់ថ្នាក់ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍

ក្រសួងទេសចរណ៍បានដាក់ចេញនូវប្រព័ន្ធចំណាត់ថ្នាក់ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ដើម្បីចូលរួមចំណែកបន្ថែមមួយកម្រិតទៀតដល់ការជម្រុញលើកកម្ពស់គុណភាពសេវាកម្មក្នុងភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍ឱ្យកាន់តែល្អប្រសើរឡើង ឆ្លើយតបនឹងតម្រូវការភ្ញៀវទេសចរណ៍ និងស្របពេលសមាហរណកម្មអាស៊ាន។

ម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ទាំងអស់ ត្រូវតែដាក់ពាក្យស្នើសុំវាយតម្លៃចំណាត់ថ្នាក់ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ដោយផ្ទាល់នៅក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្តឬតាមប្រព័ន្ធអនឡាញ។

ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មី ឬបន្តត្រូវភ្ជាប់ដោយស្វ័យប្រវត្តិជាមួយការដាក់ពាក្យស្នើសុំវាយតម្លៃចំណាត់ថ្នាក់ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍។

វិញ្ញាបនបត្រចំណាត់ថ្នាក់ភោជនីយដ្ឋាន មានសុពលភាពរយៈពេល២ឆ្នាំ។

## ៧.៣ ការដាក់តាំងស្លាកយីហោអាជីវកម្មដ្ឋានទេសចរណ៍

- ប្រកាសអន្តរក្រសួងលេខ ២៥៧ ព.ណ ចបព.ប្រក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការប្រើប្រាស់នាមករណ៍ សហគ្រាស ក្រុមហ៊ុន នៅលើលិខិត ឯកសារ ស្លាកសញ្ញាសម្រាប់តាំងបង្ហាញ ឬផ្សព្វផ្សាយពាណិជ្ជកម្មជាសាធារណៈរបស់ក្រសួងទេសចរណ៍ និងក្រសួងពាណិជ្ជកម្ម
- សារាចរណែនាំលេខ ០០៤ សរណន. ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ស្តីពីការដាក់តាំងស្លាកយីហោអាជីវកម្មដ្ឋានទេសចរណ៍

ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍ ថែរក្សាទំនៀមទម្លាប់ ប្រពៃណី ស្នាដៃ ស្ថាបត្យកម្ម អក្សរសាស្ត្រ ក្បាច់ចម្លាក់ សិល្បៈវប្បធម៌ដ៏ល្អផូរផង់ដែលជាអត្តសញ្ញាណជាតិ និងជាមរតកដ៏មានតម្លៃរបស់ជាតិយើង ក្រសួងទេសចរណ៍បានចេញសារាចរណែនាំដល់ប្រតិបត្តិករទេសចរណ៍ជាម្ចាស់អាជីវកម្មដ្ឋានទេសចរណ៍ទាំងអស់ ត្រូវអនុវត្តដូចខាងក្រោម៖

១. ត្រូវដាក់តាំងស្លាកយីហោអក្សរខ្មែរ

២. ស្លាកយីហោអាជីវកម្មដ្ឋានទេសចរណ៍ត្រូវសរសេរអក្សរអង់គ្លេស បន្ទាប់ពីអក្សរខ្មែរនៅផ្នែកខាងក្រោម និងត្រូវមានទំហំអក្សរមួយភាគពីរ (១/២) នៃទំហំអក្សរខ្មែរ។

៣. ប្រសិនបើម្ចាស់អាជីវកម្មទេសចរណ៍ មានបំណងប្រើប្រាស់អក្សរបរទេសទី៣ អាចដាក់បាននៅផ្នែកខាងក្រោមបន្ទាប់ទៀត ដោយ មានទំហំអក្សរមួយភាគពីរ (១/២) នៃទំហំអក្សរខ្មែរដែរ។

៤. ខ្លឹមសារដូចបានណែនាំខាងលើ នឹងត្រូវអនុវត្តជាកាតព្វកិច្ចចំពោះម្ចាស់អាជីវកម្មទេសចរណ៍ទាំងអស់ នឹងជាលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍។ ការបកប្រែន័យរបស់នាមករណ៍ពីភាសាមួយទៅភាសាមួយទៀត ត្រូវបានហាមឃាត់ដោយច្បាប់។

### ៧.៤ ការរៀបចំដាក់តាំងបង្ហាញបញ្ជីរាយនាមសេវាកម្មរបស់អាជីវកម្មសេវាកម្មទេសចរណ៍ ដោយមានភ្ជាប់ជាមួយតម្លៃ

- សារាចរណែនាំលេខ ០០២ សរណន. ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីការរៀបចំដាក់តាំងបង្ហាញបញ្ជីរាយនាមសេវាកម្មរបស់អាជីវកម្មសេវាកម្មទេសចរណ៍ ដោយមានភ្ជាប់ជាមួយតម្លៃ

អនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍បានចេញសារាចរណែនាំដល់គ្រប់អាជីវកម្មដ្ឋានសេវាកម្មទេសចរណ៍ទាំងអស់ ជាពិសេសសេវាកម្មម្ហូបអាហារ នូវចំណុចត្រូវអនុវត្តមួយចំនួនដូចខាងក្រោម៖

១). គ្រប់អាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់ ត្រូវរៀបចំឱ្យមានជាបញ្ជីរាយនាមសេវាកម្ម ដោយមានភ្ជាប់ជាមួយតម្លៃត្រូវសរសេរជាភាសាខ្មែរនៅខាងមុខ ឬនៅពីលើ និងភាសាអង់គ្លេស នៅបន្ទាប់ ឬបន្ទាត់ខាងក្រោម និងភាសាបរទេសទីបីនៅបន្ទាប់ទៀត អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃអតិថិជនរបស់អាជីវកម្ម។

- ប្រភេទនៃសេវាកម្មទេសចរណ៍នីមួយៗ គួរមានបង្ហាញជារូបភាព ឬការបរិយាយសេវាកម្ម។
- ត្រូវមានដាក់តាំងបង្ហាញនៅបរិវេណខាងមុខទីតាំងអាជីវកម្ម ឬកន្លែងងាយមើលឃើញ ។
- ត្រូវមានបញ្ជាក់ពីសេវាកម្មដែលភ្ជាប់ជាមួយ និងព័ត៌មានផ្សេងៗបន្ថែមទៀត ដែលចាំបាច់សម្រាប់ជាមូលដ្ឋានពិចារណាជ្រើសរើសដោយភ្ញៀវ។
- ត្រូវមានបញ្ជាក់តម្លៃឱ្យបានជាក់លាក់ និងការប្រើប្រាស់តម្លៃតាមជម្រើសបន្ថែមផ្សេងៗដែលមាន។
- ត្រូវផ្តល់ជូនភ្ញៀវទេសចរមុនពេលពួកគេសម្រេចចិត្តប្រើប្រាស់ ឬទទួលយកសេវាកម្មទេសចរណ៍។

២). ចំពោះសេវាកម្មម្ហូបអាហារ តូបលក់ម្ហូបអាហារ តូបលក់អាហារចល័ត ដែលប្រកបអាជីវកម្មជាលក្ខណៈតូចតាច ឬការគ្រប់គ្រងលក្ខណៈគ្រួសារ ក៏ត្រូវអនុវត្តតាមការណែនាំដូចបានបញ្ជាក់ជូនខាងលើ ឬយ៉ាងហោចត្រូវមានដាក់តាំងបង្ហាញជារូបភាព ឬទម្រង់ងាយស្រួលផ្សេងៗ អំពីម្ហូបអាហារ ដែលមានជូនភ្ញៀវពិសាដោយមានបញ្ជាក់តម្លៃជាក់លាក់។

៣). ការដាក់ឈ្មោះសេវាកម្ម និងឈ្មោះមុខម្ហូបនីមួយៗ ត្រូវគោរពតាមអត្តសញ្ញាណជាតិ សាសនា វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ។

៤). ចំពោះអាជីវកម្មសេវាកម្មទេសចរណ៍ ដែលពុំអនុវត្តតាមការណែនាំ គឺជាកម្មវត្ថុនៃការដកហូតអាជ្ញាបណ្ណ ទេសចរណ៍ស្របតាមបទដ្ឋានគតិយុត្តជាធរមាន។

## ៧.៥ ស្តង់ដារចលនាប្រឡងប្រណាំងធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍

- អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ១២៣២អនក្រ បក ចុះថ្ងៃទី១៤ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតរង្វាន់ពិសេសសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- ប្រកាសលេខ១៧៩ ស្តីពីលក្ខណៈវិនិច្ឆ័យ និងនីតិវិធីនៃការប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី និងប្រភេទរង្វាន់សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ (ស្តង់ដា) របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី ១៥ កញ្ញា ឆ្នាំ២០១៥
- សេចក្តីជូនដំណឹងស្តីពីការប្រឡងប្រណាំង "រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍" លើកទី៣ ឆ្នាំ២០១៨

គ្រប់សហគ្រាស ឬបុគ្គលទាំងអស់ ដែលធ្វើអាជីវកម្មរបស់ខ្លួនក្នុងវិស័យទេសចរណ៍ និងវិស័យគាំទ្រ អាចចូលរួមក្នុងកម្មវិធីប្រឡងប្រណាំងពានរង្វាន់ "រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍" និងអាចដាក់ពាក្យចូលរួមដោយស្ម័គ្រចិត្តតាមរយៈការចុះឈ្មោះនៅអគ្គនាយកដ្ឋានទេសចរណ៍ឬអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។
ចលនាប្រឡងប្រណាំងធុរកិច្ចបៃតងនេះ ជាផ្នែកមួយចូលរួមដល់ការអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាលក្នុងការជំរុញការអនុវត្តគោលការណ៍ «ទំនួលខុសត្រូវសង្គម» (Corporate Social Responsibility) របស់វិស័យឯកជនពិសេសផ្តោតលើ ការបញ្ចូលទស្សនាទាននៃ «ភាពស្អាត និងបៃតង» ទៅក្នុងគំរូអាជីវកម្មរបស់ខ្លួន ការចូលរួមការងារសង្គម ការងារបរិស្ថាន ការងារស្ម័គ្រចិត្ត និងចូលរួមលើកកម្ពស់ការងារសមរម្យ (Decent jobs) ដល់បុគ្គលិក និយោជិតជាដើម។ ពានរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ គឺជាពានរង្វាន់ដែលផ្តល់ជូនដល់អាជីវកម្មអេកូ ដែលបានរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ តាមរយៈការធ្វើធុរកិច្ចដែលមានការយកចិត្តទុកដាក់ពីផលប៉ះពាល់បរិស្ថាន ការលើកកម្ពស់សុខុមាលភាពសង្គម ការថែរក្សា ការលើកស្ទួយវប្បធម៌ និងការរួមចំណែកដើម្បីឱ្យ"កម្ពុជាស្អាត កម្ពុជាបៃតង"។

រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍មាន០៧ប្រភេទរង្វាន់ គឺ៖
ទី១៖ រង្វាន់ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងថែរក្សាអនាម័យ និងបរិស្ថាន
ទី២៖ រង្វាន់ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍ ៣Rs
ទី៣៖ រង្វាន់ធុរកិច្ចដែលមានស្នាដៃឆ្នើមខាង សុខុមាលភាពសង្គម និងបេតិកភណ្ឌវប្បធម៌
ទី៤៖ រង្វាន់ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងផ្នែកកន្លែងធ្វើការ ដែលមានភាពល្អប្រសើរ
ទី៥៖ រង្វាន់សហគ្រិនដែលមានស្នាដៃឆ្នើម
ទី៦៖ រង្វាន់ធុរកិច្ចដែលមានស្នាដៃឆ្នើម ខាងថែរក្សាឆ្នេរស្អាត
ទី៧៖ រង្វាន់ធុរកិច្ចដែលមានស្នាដៃឆ្នើមខាងប្រើប្រាស់ផលិតផលខ្មែរ។

"រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍" សំដៅជម្រុញលើកទឹកចិត្តដល់ធុរកិច្ចបៃតងនៅកម្ពុជា ដែលពិតជាមានសារៈសំខាន់ និងចាំបាច់ជាមូលដ្ឋានសមស្របនឹងនិន្នាការបច្ចុប្បន្ន។
រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ជារង្វាន់ពិសេសសម្រាប់ផ្តល់ឱ្យសហគ្រាស ឬប្រតិបត្តិករទេសចរណ៍ ឬសហគមន៍ ឬបុគ្គលដែលទទួលបានរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ចាប់ពី០២ (ពីរ) ប្រភេទឡើងទៅ មានស្នាដៃឆ្នើមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច បរិស្ថាន សង្គម វប្បធម៌ និងការចូលរួមដល់ "កម្ពុជាស្អាត កម្ពុជាបៃតង" ។





| ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាន នៅក្រសួងទេសចរណ៍ | | | |
|---|---|---|---|
| ចំនួនកៅអី | ១០១ - ២០០ | ២០១ - ៣០០ | ចាប់ពី៣០០កៅអីឡើងទៅ |
| តម្លៃសេវាសាធារណៈ | ៨០០.០០០ | ១.៣០០.០០០ | ១.៦០០.០០០ |

| ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាន នៅការិយាល័យច្រកចេញចូលតែមួយ | | |
|---|---|---|
| ចំនួនកៅអី | ទីកន្លែងដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ | តម្លៃសេវាសាធារណៈ |
| ១ ដល់ ៥០ កៅអី (ម្ចាស់អាជីវកម្មជាជនជាតិខ្មែរ) | ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលខណ្ឌ ដែលទីតាំងអាជីវកម្មស្ថិតនៅ | ៣០០ ០០០ |
| ១ ដល់ ៥០ កៅអី (ម្ចាស់អាជីវកម្មជាជនជាតិបរទេស) | ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលរាជធានី ខេត្តដែលទីតាំងអាជីវកម្មស្ថិតនៅ | ៣០០ ០០០ |
| ពី ៥០ ដល់ ១០០ កៅអី (ម្ចាស់អាជីវកម្មជាជនជាតិខ្មែរ) | ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលរាជធានី ខេត្តដែលទីតាំងអាជីវកម្ម ស្ថិតនៅ | ៦០០ ០០០ |
| ពី ៥០ ដល់ ១០០ កៅអី (ម្ចាស់អាជីវកម្មជា ជនជាតិបរទេស) | ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលរាជធានី ខេត្តដែលទីតាំងអាជីវកម្ម ស្ថិតនៅ | ៦០០ ០០០ |

| ចំណាត់ថ្នាក់ភោជនីយដ្ឋាន(សុពលភាព រយៈពេល២ឆ្នាំ) | | | | | |
|---|---|---|---|---|---|
| តម្លៃសេវា | ផ្កាយ១ | ផ្កាយ២ | ផ្កាយ៣ | ផ្កាយ៤ | ផ្កាយ៥ |
| | ៨០.០០០ | ១០០.០០០ | ២០០.០០០ | ៣០០.០០០ | ៤០០.០០០ |

# ៨ អនុលោមតាពជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ( ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬ ការិយាល័យច្រកចេញចូលតែមួយ )

## ៨.១ ប័ណ្ណអនុញ្ញាតវិស័យវប្បធម៌ និងវិចិត្រសិល្បះ (លើកផ្ទាំងយីហោអាជីវកម្ម)

ដើម្បីទទួលបានប័ណ្ណអនុញ្ញាតវិស័យវប្បធម៌ និងវិចិត្រសិល្បៈ (លើកផ្ទាំងយីហោអាជីវកម្ម) សម្រាប់ផ្ទាំងយីហោគ្រប់ប្រភេទទំហំចាប់ពី២ម៉ែត្រការ៉េ ដល់ ៤ម៉ែត្រការ៉េ ម្ចាស់អាជីវកម្ម តម្រូវឱ្យដាក់ពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលខណ្ឌដែលទីតាំងអាជីវកម្មស្ថិតនៅ។

សូមភ្ជាប់ជាមួយទម្រង់ពាក្យស្នើសុំនូវឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដូចខាងក្រោមនេះ(ចំនួន ៣ច្បាប់ថតចម្លងនៃ ឯកសារនីមួយៗ)៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ថតចម្លង ចំនួន១ច្បាប់
- ប្លង់បង្ហាញទីតាំងអាជីវកម្ម ចំនួន១ច្បាប់
- រូបថតទំហំ 4x6 ចំនួន៣សន្លឹក
- បង្កាន់ដៃបង់ប្រាក់ ចំនួន១ច្បាប់

# ៩ អនុលោមតាពជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ

## ៩.១ ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់អំពីគុណភាព ប្រសិទ្ធិភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចេញដោយអគ្គស្នងការដ្ឋាននគរបាលជាតិ

**ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា**
មានអនុក្រឹត្យចំនួន ពីរ(២) ពាក់ព័ន្ធការងារបង្ការ និងពន្លត់អគ្គិភ័យ ៖

- អនុក្រឹត្យលេខ ១៣១អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ និងវិធានការនានាស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ
- អនុក្រឹត្យលេខ ៨៧អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

**កាតព្វកិច្ចរបស់ម្ចាស់សំណង់ និងម្ចាស់គោលដៅត្រូវ ៖**
១- ដាក់ពាក្យស្នើសុំត្រួតពិនិត្យ និងបញ្ជាក់ទទួលស្គាល់គំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
២- ដាក់ពាក្យស្នើសុំត្រួតពិនិត្យ និងលិខិតបញ្ជាក់បញ្ចប់ការរៀបចំប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
៣- ដាក់ពាក្យស្នើសុំត្រួតពិនិត្យ និងចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ (សុពលភាព រយៈពេល ២(ពីរ) ឆ្នាំ)

**សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ស្ថិតក្រោមសមត្ថកិច្ចរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ៖**
ក. សំណង់ និងគោលដៅទាំងឡាយណាដែលមានផ្ទៃក្រឡាកម្រាលចាប់ពី ៣,០០០ (បីពាន់) ម៉ែត្រក្រឡា និង/ឬ មានកម្ពស់ចាប់ពី ៥ (ប្រាំ) ជាន់ឡើង ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និង/ឬ ផ្ទុកចំនួនមនុស្សចាប់ពី២០០ (ពីររយ) និង/ឬចំនួនបន្ទប់ចាប់ពី ២៥ (ម្ភៃប្រាំ) បន្ទប់ និង/ឬចំណតរថយន្តចាប់ពី ១០០(មួយរយ)គ្រឿង។
ខ. ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិតកែច្នៃសារធាតុងាយផ្ទុះ ងាយឆេះគ្រប់ប្រភេទ ចំណុះចាប់ពី ១០,០០០ (មួយម៉ឺន)លីត្រ និង/ឬ ៥,០០០ (ប្រាំពាន់) គីឡូក្រាមឡើង។
គ. សំណង់សំខាន់ៗក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋានទេសចរណ៍ និងសាសនា។



សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ស្ថិតក្រោមសមត្ថកិច្ចរបស់អគ្គស្នងការដ្ឋាននគរបាលរាជធានី ខេត្តៈ

ក. សំណង់ និងគោលដៅទាំងឡាយណាដែលមានផ្ទៃក្រឡាកម្រាលក្រោម ៣,០០០ (បីពាន់) ម៉ែត្រក្រឡា និង/ឬ មានកម្ពស់ ចាប់ពី ៤ (បួន) ជាន់ចុះ ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និង/ឬ ផ្ទុកចំនួនមនុស្សក្រោម ២០០ (ពីររយ) និង/ឬចំនួនបន្ទប់ក្រោម ២៥ (ម្ភៃប្រាំ)បន្ទប់ និង/ឬចំណតរថយន្តក្រោម ១០០(មួយរយ)គ្រឿង។

ខ. ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិត កែច្នៃសារធាតុងាយឆេះ ងាយឆេះគ្រប់ប្រភេទ ចំណុះក្រោម ១០,០០០ (មួយម៉ឺន)លីត្រ និង/ឬ ៥,០០០(ប្រាំពាន់) គីឡូក្រាម។

## ៩.២ កាតព្វកិច្ចរបស់ម្ចាស់សំណង់ ឬម្ចាស់គោលដៅ

- ម្ចាស់សំណង់ ឬម្ចាស់គោលដៅ ត្រូវមានគំនូសប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ និងមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មុនដំណើរការសាងសង់។
- គំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវបានសិក្សា និងគូរដោយអ្នកជំនាញមានវិជ្ជាជីវៈ និងមានការទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច។
- ម្ចាស់សំណង់ ឬម្ចាស់គោលដៅ ចាំបាច់ត្រូវទទួលបានលិខិតបញ្ជាក់បញ្ចប់ការរៀបចំប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការនគរបាលរាជធានី ខេត្ត។

បែបបទ និងនីតិវិធីនៃការស្នើសុំរបស់ម្ចាស់សំណង់ និងម្ចាស់គោលដៅ ដូចមានចែងក្នុងមាត្រា១៦នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ៩.៣ ទោសប្បញ្ញត្តិ

ក. នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលជាម្ចាស់សំណង់ ឬម្ចាស់គោលដៅ មិនគោរពអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងអនុក្រឹត្យ នេះត្រូវៈ

- ព្រមានជាលាយលក្ខណ៍អក្សរ
- ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០,០០០,០០០ (ដប់លាន) រៀល
- ក្នុងករណីនៅតែមិនព្រមអនុវត្ត ត្រូវប្តឹងទៅតុលាការសុំផ្អាកការសាងសង់ជាបណ្តោះអាសន្ន។

ខ. ម្ចាស់សំណង់ និងម្ចាស់គោលដៅ មិនបានអនុវត្តស្របតាមប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ដែលមានក្នុងគំនូរប្លង់សាងសង់រួម ត្រូវព្រមានជាលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ត្រូវពិន័យជាប្រាក់ចាប់ពី ២,០០០,០០០ (ពីរលាន) រៀល ទៅ ៥,០០០,០០០ (ប្រាំលាន)រៀល និងតម្រូវឱ្យធ្វើការកែតម្រូវឱ្យស្របតាមប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យជាមុនសិន។

គ. ម្ចាស់សំណង់ និងម្ចាស់គោលដៅ ដែលដំណើការសាងសង់គ្មានប្លង់បង្ការ និងពន្លត់អគ្គិភ័យ និងមិនមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវផ្អាកសកម្មភាពជាបណ្តោះអាសន្ន និងត្រូវពិន័យជាប្រាក់មិនលើសពី ១០,០០០,០០០ (ដប់លាន) រៀល។

ក្នុងករណីមិនរៀងចាល ត្រូវពិន័យជាប្រាក់ទ្វេរដង។

# ១០ អនុលោមតាពជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ១០.១ ការចុះឈ្មោះប្រើប្រាស់ឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធើណិត

- អនុក្រឹត្យលេខ ២៨៧ អនក្រ.បក របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ស្តីពី ការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធើណិត
- សេចក្តីជូនដំណឹងលេខ០៨៣៧ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម ស្តីពីការតម្រូវឱ្យប្រើប្រាស់ឈ្មោះដែនជាតិ .com.kh និងការផ្តល់អាសយដ្ឋានអេឡិចត្រូនិកឈ្មោះដែនជាតិនៅពេលក្រោយប្រកាសប្រតិវេទន៍ប្រចាំឆ្នាំ

សេចក្តីជូនដំណឹងនេះ ត្រូវបានដាក់ចេញដោយស្របតាម អនុក្រឹត្យលេខ ២៨៧ អនក្រ.បក ស្តីពីការកំណត់អំពីគោលការណ៍ វិធាន យន្តការនៃការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិដើម្បីលើកកម្ពស់អត្តសញ្ញាណ តម្លៃ និងអត្ថិភាពនៃដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធើណិត ព្រមទាំងជំរុញការប្រើប្រាស់ឈ្មោះដែនជាតិក្នុងការចូលរួមផ្តល់សេវាសាធារណៈដោយគ្មានការរើសអើង និងប្រកបដោយតម្លាភាព។

ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ តទៅ ក្រុមហ៊ុនទាំងអស់ដែលបានចុះបញ្ជីក្រោមក្រសួងពាណិជ្ជកម្ម ត្រូវប្រើឈ្មោះដែនខ្មែរកម្រិត ២ ".com.kh" ហើយត្រូវផ្តល់អាសយដ្ឋានអេឡិចត្រូនិកជាមួយឈ្មោះដែនជាតិ នៅពេលដាក់ពាក្យប្រកាសប្រតិវេទន៍ប្រចាំឆ្នាំនៅក្រសួងពាណិជ្ជកម្ម។

ក្រុមហ៊ុនដែលមិនទាន់បានប្រើប្រាស់ឈ្មោះដែនជាតិ ".com.kh" ត្រូវប្រញាប់ចុះឈ្មោះប្រើប្រាស់ឈ្មោះដែនជាតិ .com.kh នេះនៅការិយាល័យនិយ័តករទូរគមនាគមន៍កម្ពុជាដោយផ្ទាល់ ឬតាមរយៈ Email: info@trc.gov.kh។

ដើម្បីទទួលបានឈ្មោះដែនជាតិ ក្រុមហ៊ុនត្រូវដាក់សំណើទៅនិយ័តករទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍ និងត្រូវបង់សេវាចុះបញ្ជីជាលើកដំបូងចំនួន ៤០ ០០០ រៀល។ ឈ្មោះដែនជាតិមានសុពលភាព រយៈពេលមួយឆ្នាំ ដោយចាប់ផ្តើមមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការចុះឈ្មោះ។ ម្ចាស់ដែនតម្រូវឱ្យបន្តសុពលភាពឈ្មោះដែនរបស់ពួកគេជារៀងរាល់ឆ្នាំដោយបង់ថ្លៃសេវាសាធារណៈចំនួន ១៣២.០០០ រៀល ដោយបញ្ចូលទាំងអាករលើតម្លៃបន្ថែម១០%។

យោងតាមមាត្រា៧ នៃអនុក្រឹត្យលេខ២៨៧ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅលើអ៊ីនធើណិតចូលជាធរមាន នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ក្រុមហ៊ុននៅតែអាចប្រើឈ្មោះដែនផ្សេងទៀត បន្ថែមលើឈ្មោះដែនជាតិសម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។

ការស្នើសុំឈ្មោះដែនជាតិប្រភេទ .com.kh សម្រាប់សហគ្រាសពាណិជ្ជកម្ម និងសហគ្រាសសាធារណៈ ត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោម៖

- សេចក្តីចម្លងអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ដែលមានការបញ្ជាក់នីត្យានុកូលកម្ម
- សេចក្តីចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលមានការបញ្ជាក់នីត្យានុកូលកម្ម
- សម្រង់ព័ត៌មានក្រុមហ៊ុន។

## ១០.២ នីតិវិធីស្ដីពី ដំណើរការស្នើសុំចុះឈ្មោះដែនជាតិ .kh តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (សម្រាប់សហគ្រាសពាណិជ្ជកម្ម ឬសហគ្រាសសាធារណៈ)






១. ចូលទៅគេហទំព័រ www.domain.gov.kh
២. បង្កើតគណនីសម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចុះឈ្មោះដែនជាតិ
៣. បំពេញព័ត៌មានផ្ទាល់ខ្លួន
៤. ស្វែងរកឈ្មោះដែនជាតិដែលអ្នកចង់ទិញ
៥. បញ្ជាទិញឈ្មោះដែនជាតិ
៦. បញ្ចូលព័ត៌មាននិងភ្ជាប់ឯកសារពាក់ព័ន្ធឱ្យបានត្រឹមត្រូវ
៧. អ្នកស្នើសុំនឹងទទួលបានការជូនដំណឹង បន្ទាប់ពីនិយ័តករទូរគមនាគមន៍កម្ពុជា បានអនុម័តលើសំណុំសុំចុះឈ្មោះដែនជាតិហើយអ្នកស្នើសុំអាចបង់ថ្លៃប្រើប្រាស់ឈ្មោះដែនជាតិប្រចាំឆ្នាំ តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មចុះឈ្មោះដែនជាតិ
៨. ក្រោយពីបង់ថ្លៃប្រើប្រាស់ឈ្មោះដែនជាតិប្រចាំឆ្នាំ ឈ្មោះដែនជាតិដែលបានស្នើសុំនឹងត្រូវបានភ្ជាប់ដំណើរការ។

## ១០.៣ ដំណើរការក្នុងការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ/អាជ្ញាបណ្ណសេវាអនឡាញ

ជាដំបូង លោកអ្នកត្រូវចូលទៅកាន់គេហទំព័រ www.service.mptc.gov.kh បន្ទាប់មកត្រូវស្កេនQR Code ដោយប្រើកម្មវិធីទូរស័ព្ទ CamDigiKey និងជ្រើសរើសប្រភេទសំណើ៖

- លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ សេវាអនឡាញ
- បំពេញព័ត៌មាន និងបញ្ជូនឯកសារភ្ជាប់ទាំងអស់
- ធ្វើការទូទាត់ថ្លៃរដ្ឋបាលតាមប្រព័ន្ធអ៊ីនធើណិត
- រង់ចាំក្រុមការងារពិនិត្យលើសំណើ និងជូនដំណឹងអំពីស្ថានភាពសំណើតាមរយៈសារ SMS
- ទទួលបានការជូនដំណឹងតាមរយៈសារSMS ដើម្បីធ្វើការទូទាត់ថ្លៃស្នើសុំ (លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ)
- ទទួលបានវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណជាទម្រង់ឌីជីថល



# ១១ អនុលោមតាពជាមួយក្រសួង /មន្ទីរបរិស្ថាន
## (ការបំពេញកាតព្វកិច្ចចុះកិច្ចសន្យាការពារបរិស្ថាន)

- ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ អនុម័តនៅថ្ងៃទី ២៤ ធ្នូ ឆ្នាំ១៩៩៦
- ប្រកាសលេខ ០២១ ប្រ.ក ប.ស្ត ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍
- ប្រកាសអន្តរក្រសួងលេខ១០៧០ របស់ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ ដោយក្រសួងបរិស្ថាន ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៩

យោងតាមប្រកាសលេខ០២១ប្រ.ក ប.ស្ត ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ បានបែងចែកចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យមានកិច្ចសន្យាការពារបរិស្ថាន ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ។

- ប្រភេទគម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យរៀបចំកិច្ចសន្យាការពារបរិស្ថាន គឺសំដៅដល់គម្រោងដែលមានការប៉ះពាល់តិចតួចដល់បរិស្ថាននិងសង្គម។
- ប្រភេទគម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គឺសំដៅដល់គម្រោងដែលមានការប៉ះពាល់មធ្យមដល់បរិស្ថាននិងសង្គម។
- ប្រភេទគម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ គឺសំដៅដល់គម្រោងដែលមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម។

យោងតាមប្រកាសអន្តរក្រសួងលេខ១០៧០ ខាងលើ ការចុះកិច្ចសន្យាការពារបរិស្ថាន និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានបែងចែកតាមសមត្ថកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដូចខាងក្រោម៖

### ១១.១ សមត្ថកិច្ចនៅរដ្ឋបាលថ្នាក់ជាតិ (ឧបសម្ព័ន្ធ១ នៃប្រកាសអន្តរក្រសួងលេខ១០៧០ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩)

#### ១១.១.១ កិច្ចសន្យាការពារបរិស្ថាន

- ភោជនីយដ្ឋានដែលមានចំនួនកៅអីចាប់ពី១០០ដល់៣០០កៅអី ត្រូវមានកាតព្វកិច្ចចុះកិច្ចសន្យាការពារបរិស្ថាននៅមន្ទីរបរិស្ថានរាជធានី-ខេត្ត ដោយត្រូវបង់កម្រៃចុះកិច្ចសន្យាការពារបរិស្ថានចំនួន ៣,០០០,០០០ (បីលាន) រៀល និងត្រូវបង់វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានប្រចាំឆ្នាំតាមគោលការណ៍ស្ម័គ្រចិត្តរបស់ម្ចាស់គម្រោង។ កិច្ចសន្យាការពារបរិស្ថាន មានសុពលភាពតាមកាលនៃគម្រោង។

#### ១១.១.២ ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- សម្រាប់ភោជនីយដ្ឋានដែលមានចំនួនកៅអីចាប់ពី៣០០កៅអីឡើងទៅ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង នៅក្រសួងបរិស្ថាន។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង មានសុពលភាពតាមកាលនៃគម្រោង។

- សម្រាប់ភោជនីយដ្ឋាន និងអាហារដ្ឋានបណ្តែតទឹក ដែលមានចំនួនកៅអីចាប់ពី៣០០កៅអីឡើងទៅ រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនៅក្រសួងបរិស្ថាន។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង មានសុពលភាពតាមកាលនៃគម្រោង។

| តម្លៃសេវាសាធារណៈស្ថិតក្រោមសមត្ថកិច្ចនៃក្រសួងបរិស្ថាន | | |
|---|---|---|
| លេខរៀង | ប្រភេទសេវា | តម្លៃឯកតានៃសេវា (រៀល) |
| សេវាពាក់ព័ន្ធនឹងការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និងការតាមដានឃ្លាំមើលការអនុវត្តគម្រោង | | |
| ១ | ភោជនីយដ្ឋាន អាហារដ្ឋាន (ចំនួន ≥ ៣០០ កៅអី) | ៥,០០០,០០០ |
| ២ | ភោជនីយដ្ឋាន អាហារដ្ឋានបណ្តែតទឹក (ចំនួន ≥ ៣០០ កៅអី) | ៨,០០០,០០០ |
| ៣ | អាជីវកម្មខារ៉ាអូខេ រង្គសាល និងឌីស្កូតែក (ក្រឡាផ្ទៃ ≥ ៨,០០០ ម៉ែត្រការ៉េ) | ១០,០០០,០០០ |
| សេវាកិច្ចសន្យាការពារបរិស្ថានដែលតម្រូវឱ្យម្ចាស់គម្រោងអនុវត្ត | | |
| ១ | ភោជនីយដ្ឋាន អាហារដ្ឋាន (ចំនួន > ១០០ - ៣០០ កៅអី) | ៣,០០០,០០០ |
| ការចុះបញ្ជីការផ្តល់ការអនុញ្ញាតផ្សេងៗ និងមូលនិធិទាយជ្ជទានបរិស្ថាន | | |
| ១ | វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំ សម្រាប់ការស្តារបរិស្ថានឡើងវិញ ដែលបានពីការស្ម័គ្រចិត្តរបស់ម្ចាស់គម្រោងដែលត្រូវធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន | តាមការស្ម័គ្រចិត្តរបស់ម្ចាស់គម្រោង |

### ១១.២ សមត្ថកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧបសម្ព័ន្ធ២ នៃប្រកាសអន្តរក្រសួងលេខ១០៧០ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩)

#### ១១.២.១ កិច្ចសន្យាការពារបរិស្ថាន

- ភោជនីយដ្ឋាន និងអាហារដ្ឋានដែលមានចំនួនកៅអីចាប់ពី១០០ ដល់៥០០កៅអី ត្រូវមានកាតព្វកិច្ចចុះកិច្ចសន្យាការពារបរិស្ថាននៅមន្ទីរបរិស្ថានរាជធានី-ខេត្ត។ កិច្ចសន្យាការពារបរិស្ថាន មានសុពលភាពតាមកាលនៃគម្រោង។

#### ១១.២.២ ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន(ទុនវិនិយោគក្រោមពីរលានដុល្លារអាមេរិក)

- សម្រាប់ភោជនីយដ្ឋានដែលមានចំនួនកៅអីចាប់ពី៣០០កៅអីឡើងទៅ ត្រូវមានកាតព្វកិច្ចរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្រសួងបរិស្ថាន។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសុពលភាពតាមកាលនៃគម្រោង។

| តម្លៃសេវាសាធារណៈស្ថិតក្រោមសមត្ថកិច្ចមន្ទីរបរិស្ថានរាជធានី-ខេត្ត | | |
|---|---|---|
| លេខរៀង | ប្រភេទសេវា | តម្លៃឯកតានៃសេវា(រៀល) |
| សេវាពាក់ព័ន្ធនឹងការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និងការតាមដានឃ្លាំមើលការអនុវត្តគម្រោង (ទុនវិនិយោគក្រោម ពីរលានដុល្លារអាមេរិក) | | |
| ១ | ភោជនីយដ្ឋាន អាហារដ្ឋាន (ចំនួន ៣០០ កៅអី) | ៣,០០០,០០០ |
| សេវាកិច្ចសន្យាការពារបរិស្ថាន ដែលតម្រូវឱ្យម្ចាស់គម្រោងអនុវត្ត | | |
| ១ | ភោជនីយដ្ឋាន អាហារដ្ឋាន (ចំនួន ១០០ - ៥០០ កៅអី) | ១,០០០,០០០ |
| ២ | អាជីវកម្មបៀហ្គាឌិន ក្លឹបកម្សាន្ត ខារ៉ាអូខេ រង្គសាល និងឌីស្កូតែក (ទំហំ ៣,០០០ ម៉ែត្រការ៉េ) | ១,០០០,០០០ |
| **វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថាន** | | |
| ១ | វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំ សម្រាប់ការស្តារបរិស្ថានឡើងវិញ ដែលបានពីការស្ម័គ្រចិត្តរបស់ម្ចាស់គម្រោងដែលត្រូវធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន | តាមការស្ម័គ្រចិត្តរបស់ម្ចាស់គម្រោង |







# ១២ អនុលោមភាពជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## ១២.១ កាតព្វកិច្ចក្នុងការស្នើសុំបង្កើតសិប្បកម្ម

ប្រសិនបើអ្នកដំណើរការភោជនីយដ្ឋាន ដែលភោជនីយដ្ឋានរបស់អ្នកផលិតឈើស សាច់ក្រក ឬមុខម្ហូបណាមួយ ដូចនេះ តាមច្បាប់ អ្នកត្រូវដាក់ពាក្យស្នើសុំអនុញ្ញាតបង្កើតសិប្បកម្មពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងត្រូវបង់ក្រៃសេវាសាធារណៈចំនួន ១៥០,០០០ (ដប់ប្រាំម៉ឺន) រៀល។

ម្ចាស់សហគ្រាស ត្រូវបំពេញទម្រង់បែបបទនិងភ្ជាប់ឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន
- ប្លង់បង្ហាញទីតាំង ប្លង់រួម ប្លង់អគារ ប្លង់ទីតាំងគ្រឿងចក្រនិងបរិក្ខារ
- បញ្ជីសារពើពន្ធនៃវត្ថុធាតុដើមសំខាន់ៗ
- គំនូសបំព្រួញបច្ចេកទេសខ្សែសង្វាក់ផលិតកម្ម
- លិខិតផ្ទេរសិទ្ធិ
- កិច្ចសន្យាជួលទីតាំង
- លក្ខន្តិកៈក្រុមហ៊ុន (ករណីចុះបញ្ជីជាក្រុមហ៊ុន)
- លិខិតអង្កេតសុវិធាន អសុវិធាន

ដំណើរការនៃការដាក់ពាក្យស្នើសុំនេះ មានរយៈពេល ៤០ (សែសិប) ថ្ងៃ នៃថ្ងៃធ្វើការ។ អំឡុងពេលដាក់ពាក្យស្នើសុំ មន្ត្រីទទួលបន្ទុកនិងជូនដំណឹងពីពេលវេលាដែលនឹងត្រូវចុះត្រួតពិនិត្យទីតាំង។ បន្ទាប់ពីត្រួតពិនិត្យរួចរាល់ សហគ្រាសនឹងទទួលបានប្រកាសស្តីពីការបង្កើតសិប្បកម្ម។

ក្រោយទទួលបានប្រកាសស្តីពីការបង្កើតសិប្បកម្ម សហគ្រាស ត្រូវយកផលិតផលទៅធ្វើការវិភាគនៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ ដើម្បីពិនិត្យប៉ារ៉ាម៉ែត្រ ផ្នែកគិមីសាស្ត្រចំណីអាហារ និង ផ្នែកមីក្រូជីវសាស្ត្រចំណីអាហារ ដែលមាននៅក្នុងផលិតផល ស្របតាមស្តង់ដារកម្ពុជា (លក្ខណៈវិនិច្ឆ័យនៃការវិភាគប្រែប្រួលតាមផលិតផល)។

## ១២.២ កាតព្វកិច្ចក្នុងការស្នើសុំអនុញ្ញាតដំណើរការសិប្បកម្ម

ជំហ៊ានបន្ទាប់ ម្ចាស់អាជីវកម្ម ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្មនៅច្រកចេញចូលតែមួយ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងត្រូវភ្ជាប់ឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្ម
- វិញ្ញាបនបត្រវិភាគផលិតផលចេញពីមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍
- លិខិតផ្ទេរសិទ្ធិ
- ទិន្នន័យពីបរិមាណ និងតម្លៃសរុបផលិតផល ប្រចាំខែ

អំឡុងពេលដាក់ពាក្យស្នើសុំ សហគ្រាសត្រូវបង់កម្រៃសេវាសាធារណៈចំនួន ៧៥,០០០ (ប្រាំពីរម៉ឺនប្រាំពាន់) រៀល។ បន្ទាប់ពីបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ សហគ្រាស នឹងទទួលបានវិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្មក្នុងរយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ។ វិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្មនេះ មានសុពលភាព ៣ (បី) ឆ្នាំ។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីដាក់លក់ផលិតផលរបស់យើងដោយស្របច្បាប់ ផលិតផលនីមួយៗ ត្រូវឆ្លងកាត់ការធ្វើតេស្តផលិតផលម្តងទៀត ដើម្បីស្នើសុំអាជ្ញាបណ្ណប្រើសញ្ញាចុះបញ្ជីផលិតផលនៅវិទ្យាស្ថានស្តង់ដារកម្ពុជា។

## ១២.៣ កាតព្វកិច្ចក្នុងការស្នើសុំអាជ្ញាបណ្ណប្រើសញ្ញាចុះបញ្ជីផលិតផល ចេញដោយវិទ្យាស្ថានស្តង់ដារកម្ពុជា

បន្ទាប់ពីទទួលបានប្រកាសស្តីពីការបង្កើតសិប្បកម្ម និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្មពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សហគ្រាសត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីផលិតផលនៅវិទ្យាស្ថានស្តង់ដារកម្ពុជា។ មុនពេលដាក់ពាក្យស្នើសុំ ជាដំបូងម្ចាស់អាជីវកម្ម ត្រូវយកផលិតផលដែលបានវេចខ្ចប់មានឈ្មោះផលិតផលត្រឹមត្រូវចំនួន១គីឡូក្រាមក្នុងផលិតផលនីមួយៗដើម្បីធ្វើការវិភាគផ្នែកគីមីអាហារ និងផ្នែកមីក្រូជីវសាស្ត្រអាហារ(អាស្រ័យលើប្រភេទផលិតផលដែលបានស្នើសុំ)។ បន្ទាប់ពីទទួលបានការអនុញ្ញាតលើការវិភាគផលិតផល ម្ចាស់អាជីវកម្ម ត្រូវបំពេញពាក្យស្នើសុំអាជ្ញាបណ្ណប្រើសញ្ញាចុះបញ្ជីផលិតផលដើម្បីទទួលបានអាជ្ញាបណ្ណ និងស្លាកសញ្ញា ដែលមានលេខ“ច.ប.ផ”។ ម្ចាស់អាជីវកម្ម អាចប្រើប្រាស់គំរូស្លាកសញ្ញានៃផលិតផលចំណីអាហារដែលបានផ្តល់ឱ្យជាមួយអាជ្ញាបណ្ណប្រើសញ្ញាចុះបញ្ជីផលិតផលដោយរៀបចំសំបកវេចខ្ចប់ដោយខ្លួនឯង តែត្រូវប្រាកដថាសំបកវេចខ្ចប់នោះ បានរៀបចំត្រឹមត្រូវស្របតាមលក្ខខណ្ឌ។

ព័ត៌មានចាំបាច់ក្នុងការធ្វើស្លាកសម្រាប់ផលិតផលចំណីអាហារដែលបានវេចខ្ចប់ដូចខាងក្រោម៖

- ឈ្មោះផលិតផល
- សញ្ញាសម្គាល់ផលិតផល (ម៉ាក)
- ប្រភពផលិតផល
- បរិមាណសុទ្ធ និងទម្ងន់
- ឈ្មោះ អាសយដ្ឋានផលិត
- កាលបរិច្ឆេទផលិតផល
- របៀបប្រើប្រាស់
- លេខឡូតិ៍នៃផលិតផល
- បញ្ជីឈ្មោះគ្រឿងផ្សំ

អក្សរដែលត្រូវសរសេរនៅលើសំបកវេចខ្ចប់ ត្រូវតែជាភាសាខ្មែរសម្រាប់ផលិតផលក្នុងស្រុក។ ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រើសញ្ញាចុះបញ្ជីផលិតផល ត្រូវបង់កម្រៃសេវាចំនួន៣០០,០០០ (សាមសិបម៉ឺន) រៀលក្នុងមួយមុខផលិតផល។ អាជ្ញាបណ្ណប្រើសញ្ញាចុះបញ្ជីផលិតផលមានសុពលភាពរយៈពេល៣ឆ្នាំ។

**ចំណាំ៖** ក្នុងរយៈពេល ៣ខែ ទៅ៦ខែ ម្ចាស់អាជីវកម្មត្រូវយកផលិតផលដែលបានចុះបញ្ជីទៅធ្វើការវិភាគ។

# ១៣ អធិការកិច្ចដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច

បន្ទាប់ពីចុះបញ្ជីអាជីវកម្មបានជោគជ័យ ក្នុងនាមជាម្ចាស់អាជីវកម្មវាជាទំនួលខុសត្រូវរបស់អ្នកក្នុងការធានាឱ្យបានថាអាជីវកម្មរបស់អ្នកគោរពតាមគ្រប់លក្ខខណ្ឌតម្រូវនានា ស្របតាមច្បាប់ និងបទបញ្ញត្តិជាធរមាន ជៀសវាងការប្រឈមនឹងការផាកពិន័យផ្សេងៗ។ ម៉្យាងវិញទៀត នៅអំឡុងពេលដំណើរការអាជីវកម្មរបស់អ្នក អ្នកនឹងមានការចុះអធិការកិច្ចពី ក្រសួង- ស្ថាប័នមានសមត្ថកិច្ច ដែលនឹងត្រួតពិនិត្យលើការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងអាជីវកម្មភោជនីយដ្ឋានរបស់អ្នក។



### តើម្ចាស់អាជីវកម្មភោជនីយដ្ឋាន គួររំពឹងថានឹងមានអធិការកិច្ចអ្វីខ្លះ?

នៅពេលដំណើរការអាជីវកម្មរបស់អ្នក អ្នកគួរតែរំពឹងថានឹងមានអធិការកិច្ចដូចខាងក្រោម៖

(១) អធិការកិច្ចគុណភាពផលិតផលដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

(២) អធិការកិច្ចលើការអនុវត្តអនាម័យល្អសម្រាប់ភោជនីយដ្ឋាន និងអាហារដ្ឋាន ដោយក្រសួងសុខាភិបាល

(៣) អធិការកិច្ចពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអធិការកិច្ចហត្ថពលកម្មបរទេស ក្រុមចម្រុះអធិការកិច្ចពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃ

(៤) អធិការកិច្ចបរិស្ថានដោយក្រសួងបរិស្ថាន

(៥) អធិការកិច្ចសុវត្ថិភាពអគ្គីភ័យ ដោយក្រសួងមហាផ្ទៃ

### (១) អធិការកិច្ចគុណភាពផលិតផលដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- អនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចស្តង់ដារកម្ពុជា

ការធ្វើអធិការកិច្ចនៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម អាចប្រព្រឹត្តទៅតាមកាលកំណត់ឬ មិនមានកាលកំណត់តាមការចាំបាច់ ស្របតាមច្បាប់និងបទបញ្ញត្តិជាធរមាន។

ការចុះអធិការកិច្ចនៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្មតាមកាលកំណត់ត្រូវអនុវត្តជាលក្ខណៈប្រចាំយ៉ាងតិច១ (មួយ)ដង ក្នុង១ (មួយ)ឆ្នាំ។

ក្នុងករណីដែលផលិតផល ឬសេវាកម្ម មានលក្ខណៈងាយទទួលរងហានិភ័យខ្ពស់ ឬមានការប៉ះពាល់ដល់គុណភាព សុវត្ថិភាព សុខភាពមនុស្ស សត្វ រុក្ខជាតិ ឬបញ្ហាសន្តិសុខជាតិ ការចុះត្រួតពិនិត្យនៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្មទាំងនោះ ត្រូវអនុវត្តឱ្យកាន់តែញឹកញាប់។

ការធ្វើអធិការកិច្ចនៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម អាចធ្វើអធិការកិច្ចដោយមានការជូនដំណឹងជាមុន ឬមិនមានការជូនដំណឹងជាមុន។

ក្នុងពេលចុះបំពេញការងារត្រួតពិនិត្យ មន្ត្រីអធិការកិច្ចត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ត្រូវបង្ហាញលិខិតបញ្ជាបេសកកម្មជូនដល់ម្ចាស់អាជីវកម្ម ឬអ្នកតំណាង
- ត្រូវមានកិច្ចប្រជុំជាមួយម្ចាស់អាជីវកម្ម ឬអ្នកតំណាង ដើម្បីពន្យល់អំពីគោលបំណងនៃការធ្វើអធិការកិច្ច និងស្នើសុំកិច្ចសហការ
- តម្រូវឱ្យម្ចាស់អាជីវកម្មបង្ហាញនូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ ឬទិដ្ឋាការ ឬឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួន
- ត្រូវប្រើប្រាស់កំណត់ហេតុសម្រាប់ធ្វើអធិការកិច្ច ដើម្បីជាមូលដ្ឋានក្នុងការសួរព័ត៌មានលើដំណើរការប្រព្រឹត្តទៅនៃអាជីវកម្ម និងតម្រូវឱ្យម្ចាស់អាជីវកម្មឆ្លើយប្រាប់ពីព័ត៌មានទូទៅ និងព័ត៌មានអំពីផលិតផល ឬដំណើរការផលិតកម្ម ឬសេវាកម្ម

- ត្រូវធ្វើការអង្កេតអំពីរបៀបរបបនៃការអនុវត្តការងាររបស់បុគ្គលិក កម្មករ និងធ្វើការសាកសួរព័ត៌មាន
- ត្រូវត្រួតពិនិត្យលើការអនុវត្តស្តង់ដារ បទបញ្ញត្តិបច្ចេកទេស និងនីតិវិធីនៃការវាយតម្លៃអនុលោមភាពលើផលិតផល ឬដំណើរការផលិតកម្ម ឬសេវាកម្ម ដោយដកយកសំណាកផលិតផលសម្រាប់ធ្វើតេស្តនៅនឹងកន្លែង និង/ឬ នៅមន្ទីរពិសោធន៍ ថតរូបអំពីសកម្មភាពជាក់ស្តែង និងប្រមូល ឬថតចម្លងឯកសារពាក់ព័ន្ធដែលចាំបាច់
- ត្រូវបង្ហាញ និងពន្យល់ដល់ម្ចាស់អាជីវកម្ម ឬអ្នកតំណាង អំពីការរកឃើញនូវចំណុចដែលពុំមានភាពអនុលោមតាមស្តង់ដារ បទបញ្ញត្តិបច្ចេកទេស និងនីតិវិធីនៃការវាយតម្លៃភាពអនុលោម
- កំណត់ហេតុ និងសំណុំបែបបទផ្សេងទៀត ត្រូវអាន ពិនិត្យខ្លឹមសារ និងចុះហត្ថលេខាឬផ្តិតស្នាមម្រាមដៃដោយមន្ត្រីអធិការកិច្ច និងម្ចាស់អាជីវកម្ម ឬអ្នកតំណាង។ ក្នុងករណីដែលម្ចាស់អាជីវកម្ម ឬអ្នកតំណាងមិនព្រមចុះហត្ថលេខាលើកំណត់ហេតុ និងសំណុំបែបបទផ្សេងទៀត មន្ត្រីអធិការកិច្ច ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខានោះ។
- ម្ចាស់អាជីវកម្ម ឬអ្នកតំណាង ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីអធិការកិច្ច ដើម្បីបំពេញភារកិច្ច ត្រួតពិនិត្យ ឬធ្វើអធិការកិច្ច។ ក្នុងករណីម្ចាស់អាជីវកម្ម ឬអ្នកតំណាង ឬបុគ្គលណាមួយរារាំងការចូលក្នុងទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ឬរារាំងរំខានក្នុងពេលបំពេញភារកិច្ចរបស់មន្ត្រីអធិការកិច្ច ឬពុំបានអនុវត្តតាមការតម្រូវរបស់មន្ត្រីអធិការកិច្ច ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

### (២) អធិការកិច្ចអនាម័យប្រតិបត្តិការដោយក្រសួងសុខាភិបាល

ការចុះធ្វើអធិការកិច្ច ដើម្បីផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ ត្រូវអនុវត្តនៅក្នុងករណីដូចខាងក្រោម៖

- នៅពេលមានការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អដំបូងឬបន្ទាប់ពីពេលបើកភោជនីយដ្ឋាន អាហារដ្ឋាន
- នៅពេលដាក់ពាក្យស្នើសុំបន្តសុពលភាព ជារៀងរាល់ឆ្នាំនូវវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ
- ការចុះត្រួតពិនិត្យដោយមិនបានព្រាងទុករបស់ក្រសួងសុខាភិបាល

ដោយអនុវត្តតាមច្បាប់ និងបទបញ្ញត្តិនានាដែលមានជាធរមាន និងតាមស្តង់ដារទូទៅនៃសុវត្ថិភាពចំណីអាហារសម្រាប់បរិវេណនីមួយៗ ភ្នាក់ងារត្រួតពិនិត្យចំណីអាហារអាចចូលទៅក្នុងភោជនីយដ្ឋាន ឬអាហារដ្ឋាន និងក្នុងគោលបំណងដើម្បីផ្តល់ បន្ត ព្យួរ ឬដកវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ ភ្នាក់ងារត្រួតពិនិត្យចំណីអាហារអាច៖

- ត្រួតពិនិត្យ ឬឆែកឆេរគ្រឹះស្ថានណាមួយ និងត្រួតពិនិត្យចំណីអាហារ ប្រដាប់ប្រដារប្រើប្រាស់ ផលិតផល សម្ភារៈ វត្ថុ ឬសារធាតុដែលកំពុងប្រើប្រាស់ ឬសង្ស័យថានឹងប្រើប្រាស់ ឬទុកបម្រុងសម្រាប់ប្រើប្រាស់ពាក់ព័ន្ធជាមួយការរក្សាទុក ការប្រើ ការរៀបចំទុក ការបម្រើ និងការលក់ដូរចំណីអាហារ
- ទាមទារឱ្យផ្តល់ព័ត៌មានពីប្រតិបត្តិករធុរកិច្ចចំណីអាហារ ឬតំណាង នៃគ្រឹះស្ថាន ភោជនីយដ្ឋាន ឬអាហារដ្ឋាន ដែលទាក់ទងទៅនឹងចំណីអាហារ ប្រដាប់ប្រដារប្រើប្រាស់ ផលិតផល សម្ភារៈ វត្ថុ ឬសារធាតុនានានោះ
- ថ្លឹង វាប់ វាស់ កត់សម្គាល់ បើក និងទទួលយកសំណាកនៅក្នុងលក្ខណៈកំណត់មួយនៃចំណីអាហារ ផលិតផល សម្ភារៈ វត្ថុ សារធាតុ របស់ខ្ចប់ ឬសម្រាប់វេចខ្ចប់
- ពិនិត្យសៀវភៅ ឬឯកសារផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍អនាម័យចំណីអាហារ ដែលបានរកឃើញនៅក្នុងគ្រឹះស្ថានដែលទាក់ទងទៅនឹង ឬសង្ស័យថា ទាក់ទងទៅនឹងចំណីអាហារ និងទាមទារពីប្រតិបត្តិករ ធុរកិច្ចចំណីអាហារ ឬអ្នកតំណាងឱ្យធ្វើការបកស្រាយលើការសរសេរចូលទៅក្នុងសៀវភៅ ឬឯកសារទាំងនោះ
- ត្រួតពិនិត្យលើប្រតិបត្តិការ ឬដំណើរការដែលបានអនុវត្តនៅក្នុងគ្រឹះស្ថាននោះ និងទាមទារព័ត៌មានដែលពាក់ព័ន្ធទៅប្រតិបត្តិការ ឬដំណើរការនោះពីប្រតិបត្តិករធុរកិច្ចចំណីអាហារ ឬអ្នកតំណាង ឬពីអ្នកដែលធ្វើប្រតិបត្តិការ ឬដំណើរការនោះ
- ពិនិត្យលទ្ធផលណាមួយដែលបានបង្ហាញដោយឧបករណ៍វាស់វែងដែលបានដាក់តម្លើងនៅក្នុងបរិវេណ ឬដោយឧបករណ៍នានារបស់ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ
- ថតយករូបភាពនានាដែលចាំបាច់ទាក់ទងនឹងសកម្មភាពចុះអធិការកិច្ច។

នៅពេលដែលចុះធ្វើអធិការកិច្ច ប្រតិបត្តិករធុរកិច្ចចំណីអាហារ ឬអ្នកតំណាង ឬបុគ្គលណាមួយដែលមានវត្តមាននៅក្នុងគ្រឹះស្ថាន ភោជនីយដ្ឋាន ឬអាហារដ្ឋាន៖

- ត្រូវនៅអមជាមួយភ្នាក់ងារត្រួតពិនិត្យចំណីអាហារ
- ត្រូវផ្តល់ឱ្យនូវព័ត៌មាន និងឯកសារនានាតាមសំណូមពររបស់ភ្នាក់ងារត្រួតពិនិត្យចំណីអាហារដែលពាក់ព័ន្ធទៅនឹងការដាក់តម្លើង ប្រដាប់ប្រដារប្រើប្រាស់ សម្ភារៈ ទម្រង់ ឬបញ្ហាផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យ។

(៣). អធិការកិច្ចពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអធិការកិច្ចហត្ថពលកម្មបរទេស ក្រុមចម្រុះអធិការកិច្ចពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃ

- ប្រកាសលេខ៣៥៨/២១ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារនិងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- -សេចក្តីសម្រេច លេខ៨៩សសរ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស
- -ប្រកាសរួមលេខ៧១៩ ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អធិការការងារនឹងធ្វើអធិការកិច្ចការងារសាមញ្ញតែមួយលើកក្នុងមួយឆ្នាំនៅតាមរោងចក្រ សហគ្រាស លើកលែងតែអធិការកិច្ចការងារពិសេស តាមដានការដាក់កំហិត តាមបណ្តឹង ឬទទួលបានព័ត៌មានអំពីការរំលោភច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសមានភារកិច្ចធ្វើ អធិការកិច្ចហត្ថពលកម្មបរទេស ដោយប្រើប្រាស់លិខិតបង្គាប់ការរួមចេញដោយអគ្គនាយកដ្ឋានការងារ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍។

អធិការកិច្ចការងារធ្វើឡើងជាទៀងទាត់ ដោយមានការជូនដំណឹងជាមុនដល់ម្ចាស់ ឬនាយក សហគ្រាស គ្រឹះស្ថាន។ ក្នុងករណីចាំបាច់ក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសនឹងចុះធ្វើអធិការកិច្ចតាមបណ្តាសហគ្រាស គ្រឹះស្ថានទាំងអស់ដោយមិនបាច់ជូនដំណឹងជាមុន។

ម្ចាស់ ឬនាយក សហគ្រាសត្រូវសហការជាមួយក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសយ៉ាងដូចម្តេច?

អំឡុងពេលធ្វើអធិការកិច្ច ម្ចាស់ឬនាយក សហគ្រាស ត្រូវសហការជាមួយក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសក្នុងការបង្ហាញឯកសារចាំបាច់នានាដូចខាងក្រោម៖

| | |
|---|---|
| ១. លក្ខន្តិកៈក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន (ច្បាប់ដើម) | មួយច្បាប់ |
| ២. វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ឬលិខិតមានតម្លៃស្មើ | មួយច្បាប់ |
| ៣. សេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក (ច្បាប់ដើម) | មួយច្បាប់ |
| ៤. សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ចូល-ចេញ (ច្បាប់ដើម) | មួយច្បាប់ |
| ៥. លិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស (កូតា) (ច្បាប់ដើម) | មួយច្បាប់ |

៦. កិច្ចសន្យាការងាររបស់ជនបរទេសជាភាសាខ្មែរ ដែលបានចុះបញ្ជិកាដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់ជនបរទេស
៧. លិខិតឆ្លងដែនរបស់ជនបរទេស (ច្បាប់ដើម និងថតចម្លង) និងរូបថត៤x៦ ចំនួន ២ សន្លឹក គ្រប់ជនបរទេស
៨. ទិដ្ឋាការចូល និងទិដ្ឋាការពន្យារចុងក្រោយ ដែលអនុញ្ញាតឱ្យធ្វើការងាររបស់ជនបរទេស (ថតចម្លង)
៩. បណ្ណការងារ និងសៀវភៅការងារជនបរទេស គ្រប់ជនបរទេស
១០. សៀវភៅច្បាប់ស្តីពីការងារ និងសៀវភៅច្បាប់ស្តីពីអន្តោប្រវេសន៍

ម្ចាស់សហគ្រាស ក៏ត្រូវ៖

- ចូលរួម ក្នុងដំណើរការអធិការកិច្ចរហូតដល់ពេលបញ្ចប់
- ផ្តល់ឯកសារពាក់ព័ន្ធ តាមការស្នើសុំរបស់ក្រុមអធិការកិច្ច និងចូលរួមសហការជាមួយក្រុមអធិការកិច្ច
- សម្របសម្រួល និងផ្តល់កន្លែងដល់ក្រុមអធិការកិច្ច ក្នុងការបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន។

ក្រោយពេលអធិការកិច្ច ត្រូវពិនិត្យ និងចុះហត្ថលេខាលើរបាយការណ៍អធិការកិច្ចការងារ និងលិខិតដាក់កំហិត ដើម្បីចាត់វិធានការកែតម្រូវតាមការបង្គាប់ តាមការកំណត់ក្នុងរបាយការណ៍ និងការដាក់កំហិតរបស់អធិការកិច្ច និងអនុវត្តការផាកពិន័យ (ប្រសិនបើមាន)។

(៤). ការចុះត្រួតពិនិត្យគុណភាពបរិស្ថាន ពង្រឹងការអនុវត្តច្បាប់ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដោយមន្ទីរបរិស្ថាន

- ប្រកាសលេខ២៣០ប្រ កបស្ក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីប្រតិភូកម្មអំណាចក្នុងការធ្វើសេចក្តីសម្រេចក្នុងនាមក្រសួង ចំពោះគំរោងវិនិយោគជូនមន្ទីរបរិស្ថានខេត្ត ក្រុង
- ប្រកាសអន្តរក្រសួងលេខ ១០៧០ សហវ ប្រក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងបរិស្ថាន

មន្ត្រីអធិការកិច្ចនៃមន្ទីរបរិស្ថានមានភារកិច្ចធ្វើអធិការកិច្ចលើទីតាំងអាជីវកម្មក្នុងគោលបំណងចុះត្រួតពិនិត្យគុណភាពបរិស្ថាន ពង្រឹងការអនុវត្តច្បាប់ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត។

អធិការកិច្ចពីមន្ត្រីអធិការកិច្ចនៃមន្ទីរបរិស្ថាន ធ្វើឡើងម្តងក្នុងមួយឆ្នាំ ដោយមានការជូនដំណឹងជាមុនដល់ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថាន។

អំឡុងពេលធ្វើអធិការកិច្ច ម្ចាស់សហគ្រាស ត្រូវសហការជាមួយអធិការកិច្ចនៃក្រសួងបរិស្ថាន ក្នុងការបង្ហាញឯកសារចាំបាច់នានាដូចខាងក្រោម៖

១. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតមានតម្លៃស្មើ មួយច្បាប់
២. ប័ណ្ណពន្ធប៉ាតង់
៣. អាជ្ញាប័ណ្ណទេសចរណ៍
៤. លិខិតឆ្លងដែន/ អត្តសញ្ញាណប័ណ្ណរបស់ម្ចាស់អាជីវកម្ម (ថតចម្លង)

អំឡុងពេលធ្វើអធិការកិច្ច មន្ត្រីអធិការកិច្ច ធ្វើការត្រួតពិនិត្យលើបរិវេណទីតាំងអាជីវកម្ម អនាម័យបរិស្ថានជុំវិញទីតាំង ហើយម្ចាស់អាជីវកម្មត្រូវសហការផ្តល់ព័ត៌មានមួយចំនួន ដូចខាងក្រោមទៅមន្ត្រីអធិការកិច្ច៖
ទំហំបរិវេណទីតាំង ចំនួនកម្មករ និយោជិតជាស្ត្រី និងបុរស ចំនួនវេនបំពេញការងារ ចំនួនតុ កៅអី ការប្រើប្រាស់វត្ថុធាតុដើមដូចជា សាច់ បន្លែ ការគ្រប់គ្រងសំណល់រឹងសម្រាម ការទុកដាក់សម្រាម។ បន្ទាប់មក មន្ត្រីអធិការកិច្ច នឹងពិនិត្យមើលថាតើម្ចាស់ទីតាំងអាជីវកម្មនោះបានបំពេញកិច្ចសន្យាការពារបរិស្ថាន ជាមួយមន្ទីរបរិស្ថាន ហើយឬនៅ។ ប្រសិនបើនៅម្ចាស់អាជីវកម្មនឹងត្រូវតម្រូវឱ្យចុះកិច្ចសន្យាការពារបរិស្ថានជាមួយមន្ទីរបរិស្ថាន ជាកាតព្វកិច្ច។

### (៥). អធិការកិច្ចសុវត្ថិភាពអគ្គិភ័យ និងសន្តិសុខ ដោយនាយកដ្ឋាននគរបាលបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ នៃអគ្គស្នងការនគរបាលជាតិ

១- ដាក់ពាក្យស្នើសុំត្រួតពិនិត្យ និងបញ្ជាក់ទទួលស្គាល់គំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
២- ដាក់ពាក្យស្នើសុំត្រួតពិនិត្យ និងលិខិតបញ្ជាក់បញ្ចប់ការរៀបចំប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
៣- ដាក់ពាក្យស្នើសុំត្រួតពិនិត្យ និងចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ (សុពលភាព រយ:ពេល ២(ពីរ) ឆ្នាំ)

ដើម្បីទទួលបានព័ត៌មានលម្អិត ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចធ្វើការទំនាក់ទំនងទៅនាយកដ្ឋាននគរបាលបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ នៃអគ្គស្នងការនគរបាលជាតិ។

**ឥឡូវនេះ អ្នកបានដឹង ពី នីតិវិធីនៃការចុះបញ្ជីដើម្បីអាចប្រកបអាជីវកម្មភោជនីយដ្ឋាននៅកម្ពុជា ដោយស្របច្បាប់រួចហើយ។**
**ដូចនេះ លោកអ្នកអាចចាប់ផ្តើមចុះបញ្ជីអាជីវកម្មឥឡូវនេះ!**



# ឧបត្ថម្ភធំដោយ

# សហការឧបត្ថម្ភដោយ